GFA Consulting Group

# ក្រុមពិគ្រោះយោបល់ GFA GmbH

## - ការផ្តល់វិញ្ញាបនប័ត្រ GFA -

# បទដ្ឋានបណ្តោះអាសន្ន

# សម្រាប់វិញ្ញាបនប័ត្រព្រៃឈើ

# ក្នុងព្រះរាជាណាចក្រកម្ពុជា

លេខ ១.០ កាលបរិច្ឆេទ៖ ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០១២

*- ស្ថិតក្រោមការកែសម្រួលនៅឡើយ -*

<u>សំគាល់៖</u>

បទដ្ឋានទាំងនេះ ត្រូវបានបង្កើតឡើង ក្រោមកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអ្នកតំណាងមកពីសហជីព ផ្នែកវិទ្យាសាស្ត្រសង្គម វិទ្យាសាស្ត្រព្រៃឈើ ផែនការព្រៃឈើ ប្រមាញ់ កសិ-សេដ្ឋកិច្ច និងអេកូឡូស៊ី។ បទដ្ឋានទាំងនេះត្រូវបានរៀបចំជាពិសេសដោយផ្អែកលើគោលការណ៍ និងលក្ខខណ្ឌវិនិច្ឆ័យរបស់ FSC។ បន្ថែមលើនេះទៀត បទដ្ឋានទាំងនេះ ក៏មានរួមបញ្ចូលនូវគំនិត ឬផ្នែកមួយចំនួននៃឯកសារផ្សេងៗ និងការរីកចម្រើននានា តាមការចាំបាច់ មានដូចជា៖ អនុសាសន៍របស់ ITTO, លទ្ធផលនៃសន្និសីទ UNCED (UNCED-Conference) នៅទីក្រុង Rio *គោលការណ៍ណែនាំអំពីលក្ខខណ្ឌវិនិច្ឆ័យ និងកម្រិតប្រតិបត្តិនៃសន្និសីទថ្នាក់ក្រសួងស្តីពីការការពារព្រៃឈើនៅអឺរ៉ុប (Criteria and Operational Level Guidelines of the Ministerial Conference on the Protection of Forests in Europe)* ដែលត្រូវបានធ្វើឡើងនៅទីក្រុង Helsinki និងទីក្រុង Lisbon ព្រមទាំងអនុសាសន៍ផ្នែកបរិដ្ឋាន និងសង្គម ដែលត្រូវបានធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ។

# សេចក្តីផ្តើម

ការគ្រប់គ្រងព្រៃឈើប្រកបដោយការទទួលខុសត្រូវ (ដោយផ្អែកលើចំណេះដឹងដែលមានស្រាប់ក្នុងពេលបច្ចុប្បន្ន) រួមមានវិធានការដោយផ្ទាល់ និងដោយប្រយោលទាំងអស់ ក្នុងការការពារ ថែទាំ និងប្រើប្រាស់ព្រៃឈើ ដែលធានាបាននូវការអភិរក្សព្រៃឈើជាអចិន្ត្រៃយ៍។ ការគ្រប់គ្រងព្រៃឈើប្រកបដោយការទទួលខុសត្រូវ រក្សាបាននូវភាពបត់បែន និងភាពសម្បូរបែបនៃទម្រង់ជីវិតធម្មជាតិរបស់ខ្លួន ដែលជួយជម្រុញព្រៃឈើឲ្យមានការវិវត្ត និងផ្តល់អត្ថប្រយោជន៍ដល់មនុស្សតាមរយៈមុខងារផ្នែកអេកូឡូស៊ី សេដ្ឋកិច្ច សង្គម និងវប្បធម៌ជាអចិន្ត្រៃយ៍របស់ខ្លួន។

ការផ្តល់វិញ្ញាបនប័ត្រសម្រាប់ការគ្រប់គ្រងព្រៃឈើ មានន័យថា គឺជាការវាយតម្លៃគុណភាពនៃការគ្រប់គ្រងព្រៃជាក់ស្តែង ទាក់ទងនឹងការទទួលខុសត្រូវផ្នែកសេដ្ឋកិច្ច សង្គម និងបរិដ្ឋាន និងវាយតម្លៃចំណុចទាំងនេះ ធៀបនឹងបទដ្ឋានដែលត្រូវបានកំណត់ និងទទួលស្គាល់។

ហេតុនេះ បុរេល័ក្ខខ័ណ្ឌតម្រូវសម្រាប់ការវាយតម្លៃគុណភាពការគ្រប់គ្រងព្រៃឈើរួមមានការមានបទដ្ឋាន ដែលដើរតួនាទីជាមូលដ្ឋាន និងជាឧបករណ៍មួយសម្រាប់ប្រៀបធៀប និងការមានដំណើរការប្រកបដោយបទដ្ឋានដើម្បីធ្វើការវាយតម្លៃ។ ដំណើរការនេះ ចាំបាច់ត្រូវតែមានលក្ខណៈសត្យានុម័ត និងមានតម្លាភាពខ្ពស់បំផុតតាមដែលអាចធ្វើទៅបាន។

ការសម្រេចចិត្តស្តីពីលក្ខខណ្ឌវិនិច្ឆ័យនៃការវាយតម្លៃសម្រាប់ព្រៃឈើ ដែលមានការគ្រប់គ្រងបានល្អ គឺមានសារៈសំខាន់ណាស់។ លក្ខខណ្ឌវិនិច្ឆ័យទូទៅ ក៏ចាំបាច់ត្រូវតែយ៉ាងហោចណាស់សម្របទៅតាមតំបន់ព្រៃឈើធំៗផ្សេងគ្នានៅតំបន់ត្រូពិច អាកាសធាតុបង្គួរ និងអាកាសធាតុប៉ូលខាងជើង។ លក្ខខណ្ឌវិនិច្ឆ័យទាំងនេះ ចាំបាច់ត្រូវមានបំពេញបន្ថែមដោយសូចនាករបែបគុណភាព និងបរិមាណដែលអាចផ្ទៀងផ្ទាត់បាន ដែលចាំបាច់ត្រូវកំណត់នៅកម្រិតតំបន់ ឬកម្រិតមូលដ្ឋាន។ សូចនាករទាំងនេះ នឹងត្រូវបានប្រមូលចងក្រងនៅក្នុងបញ្ជីផ្ទៀងផ្ទាត់ដែលមានលក្ខណៈដោយឡែកទៅតាមប្រទេសនីមួយៗ ដើម្បីសម្របសម្រួលដល់ការធ្វើសវនកម្មការិយាល័យ និងការចុះត្រួតពិនិត្យនៅមូលដ្ឋាន។

ការវាយតម្លៃពេញលេញមួយទៅលើការគ្រប់គ្រងព្រៃឈើប្រកបដោយការទទួលខុសត្រូវ ក៏ចាំបាច់ត្រូវពិចារណាលើល័ក្ខខ័ណ្ឌដែលមានក្របខ័ណ្ឌជាក់លាក់ទៅតាមប្រទេស នៅកម្រិតជាតិ និងកម្រិតរដ្ឋបាលដទៃទៀត។

ស្ថានភាពនៅកម្រិតនីមួយៗ ជះឥទ្ធិពលទៅលើលទ្ធភាពនៃការគ្រប់គ្រងព្រៃឈើតាមច្បាប់កំណត់។ វាគួរតែមានភាពស៊ីសង្វាក់ និងតម្លាភាពនៅក្នុងល័ក្ខខ័ណ្ឌផ្នែកនយោបាយ

រដ្ឋបាល សេដ្ឋកិច្ច អេកូឡូស៊ី សង្គម និងវប្បធម៌ ដែលក្នុងនោះ ផ្នែកគ្រប់គ្រងព្រៃឈើ (forest management unit) ប្រតិបត្តិតាមលក្ខខណ្ឌទាំងនោះ។ ការវាយតម្លៃលើការគ្រប់គ្រងព្រៃឈើគួរពិចារណាលើកាលៈទេសៈនៅគ្រប់កម្រិតទាំងអស់ ចាប់តាំងពីកម្រិតអន្តរជាតិ ដល់កម្រិតប្រតិបត្តិការ។ ទោះជាយ៉ាងនេះក្តី សេចក្តីសម្រេចក្នុងការផ្តល់ ឬមិនផ្តល់វិញ្ញាបនប័ត្រ ដែលផ្អែកទាំងស្រុងទៅលើលទ្ធផលដែលបានរកឃើញនៅកម្រិតប្រតិបត្តិការ។

ការផ្តោតការយកចិត្តទុកដាក់លើការវាយតម្លៃអំពីគុណភាពនៃការគ្រប់គ្រងព្រៃឈើ គួរស្ថិតនៅលើផ្នែកការគ្រប់គ្រងព្រៃឈើ ពោលគឺ នៅកម្រិតប្រតិបត្តិការ។ នៅកម្រិតនេះ គោលនយោបាយ និងគោលការណ៍ណែនាំផ្នែករដ្ឋបាល ចាំបាច់ត្រូវតែធ្វើសម្មាហរណកម្មចូលទៅក្នុងការគ្រប់គ្រងព្រៃឈើជាក់ស្តែង។

ការវាយតម្លៃការគ្រប់គ្រងព្រៃឈើនៅកម្រិតប្រតិបត្តិការ ពិចារណាលើទិដ្ឋភាពទាំង ៥ ដូចខាងក្រោម៖

- ទិដ្ឋភាពផ្នែកច្បាប់ នយោបាយ និងរដ្ឋបាល
- ទិដ្ឋភាពផ្នែកបច្ចេកទេសនៃការធ្វើផែនការ និងការអនុវត្ត
- ទិដ្ឋភាពផ្នែកសេដ្ឋកិច្ច
- ទិដ្ឋភាពផ្នែកសង្គម និងវប្បធម៌
- ទិដ្ឋភាពផ្នែកអេកូឡូស៊ី

ការចុះត្រួតពិនិត្យនៅមូលដ្ឋាន គួរកំណត់ភាពគ្រប់គ្រាន់នៃយន្តការធ្វើផែនការ យន្តការអនុវត្ត និងយន្តការគ្រប់គ្រងដែលមានសព្វថ្ងៃ ដើម្បីតម្រង់ទិសដៅការគ្រប់គ្រងព្រៃឈើឲ្យឆ្ពោះទៅរកនិរន្តរភាព។ ការត្រួតពិនិត្យនេះ គួរពិនិត្យ និងវាយតម្លៃលើការអនុវត្តក្នុងការគ្រប់គ្រង ដែលជះឥទ្ធិពលលើតំបន់ និងរចនាសម្ព័ន្ធនៃកន្លែងលូតលាស់ព្រៃឈើ វិធីសាស្ត្រនៃការទាញយកឈើហ៊ុប ការដឹកជញ្ជូនឈើហ៊ុប ក៏ដូចជាល័ក្ខខ័ណ្ឌនៃការធ្វើសុវត្ថិកម្មព្រៃឈើ-អេកូឡូស៊ី ក្រោយការប្រមូលផល។

បទដ្ឋានខាងក្រោមនេះ ត្រូវបានរៀបចំឡើង ដើម្បីអនុញ្ញាតិឲ្យមានការកែសម្រួលឲ្យស្របទៅតាមកាលៈទេសៈក្នុងមូលដ្ឋាន ហើយស្របពេលជាមួយគ្នានោះដែរ ក៏ធ្វើយ៉ាងណាដើម្បីឲ្យអាចអនុវត្តបានទៅលើស្ថានភាពព្រៃផ្សេងៗជាច្រើនផងដែរ។ បទដ្ឋាននេះ សន្មតថាមាន (i) ម្ចាស់ព្រៃឈើ (ii)

អាជ្ញាធរអនុវត្តច្បាប់ និង (iii) អ្នកគ្រប់គ្រងព្រៃឈើ។ សម្រាប់បណ្តាប្រទេសជាច្រើន អ្នកទាំងនេះមានដូចជា ប្រទេសដែលជាម្ចាស់ព្រៃឈើ (ដែលមានរដ្ឋាភិបាលជាតំណាង) សេវាព្រៃឈើជាតិ និងក្រុមហ៊ុនគ្រប់គ្រងព្រៃឈើ អ្នកបានទទួលអាជ្ញាប័ណ្ណ ឬអ្នកទទួលបានសម្បទានដី។ ប៉ុន្តែ ម្ចាស់ព្រៃឈើដែលមានការទទួលស្គាល់ស្របច្បាប់ ក៏អាចជាអាជ្ញាធរក្រុង ឬសហគមន៍មូលដ្ឋាន ចំណែកឯអ្នកគ្រប់គ្រងព្រៃឈើក៏អាចជាសេវាព្រៃឈើជាតិនោះផ្ទាល់តែម្តង ឬអាចជាក្រុមហ៊ុនក្នុងវិស័យឯកជនដែលមានឯកទេស ឬអាចជាអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការសម្រាប់ប្រយោជន៍សាធារណៈផងដែរ។

**<u>ប្រវត្តិនៃសំណេរបទដ្ឋាននេះ</u>**

<u>សំណេរទី ១.០</u>

ការកែសម្រួល និងការទទួលយកសូចនាករដោយ Gerhard Kuske ដែលជានាយកកម្មវិធី GFA និងជំនាញការរុក្ខាប្រមាញ់កម្ពុជា។ ការពិចារណាលើច្បាប់ស្តីពីរុក្ខាប្រមាញ់ សង្គម និងបរិដ្ឋាន។

**<u>និយមន័យ៖</u>**

**បទដ្ឋាន៖** និយមន័យទូទៅ៖ កិច្ចព្រមព្រៀងដែលត្រូវបានចងក្រងជាឯកសារ ដែលផ្ទុកទៅដោយលក្ខខណ្ឌបច្ចេកទេស ឬលក្ខខណ្ឌវិនិច្ឆ័យជាក់លាក់ដទៃទៀត ដែលនឹងត្រូវប្រើប្រាស់យ៉ាងស៊ីសង្វាក់គ្នា ដើម្បីជាវិធាន ជាគោលការណ៍ណែនាំ ឬជានិយមន័យនៃលក្ខណៈសម្គាល់នានា ដើម្បីធានាឲ្យបានថា សម្ភារៈ ផលិតផល ដំណើរការ និងសេវាផ្សេងៗ មានភាពសក្តិសមទៅតាមគោលបំណងរបស់ពួកគេ [Upton និង Bass]។ និយមន័យសម្រាប់វិស័យរុក្ខាប្រមាញ់៖ និយាម ឬនីតិវិធីនានា ឧ. ដូចអ្វីដែលស្ថាប័នចេញវិញ្ញាបនប័ត្រប្រើប្រាស់ នៅក្នុងការវាយតម្លៃរបស់ខ្លួន ទៅលើការអនុវត្តរបស់អ្នកដាក់ពាក្យសុំបទដ្ឋាននៃការបញ្ជាក់វិញ្ញាប័នប័ត្រ ឬសង្វាក់នៃនីតិវិធីក្នុងការគ្រប់គ្រង។

**គោលការណ៍៖** ជាវិធាន ឬធាតុដ៏ចាំបាច់មួយនៃការបញ្ជាក់វិញ្ញាប័នប័ត្រ (នៅក្នុងបរិបទនៃការចេញវិញ្ញាបនប័ត្រ FSC)។

**លក្ខខណ្ឌវិនិច្ឆ័យ៖** ចំណាត់ប្រភេទនៃល័ក្ខខ័ណ្ឌ ឬដំណើរការ ដែលគេអាចយកទៅប្រើដើម្បីវាយតម្លៃលើការគ្រប់គ្រងព្រៃឈើប្រកបដោយការទទួលខុសត្រូវ៖ លក្ខខណ្ឌវិនិច្ឆ័យមួយ គឺត្រូវបានកំណត់

លក្ខណៈដោយ សូចនាករដែលពាក់ព័ន្ធមួយចំនួន ដែលត្រូវបានតាមដានជាទៀងទាត់ ដើម្បីវាយតម្លៃការផ្លាស់ប្តូរ [ដំណើរការក្រុងម៉ុងត្រេអាល់]។ លក្ខខណ្ឌវិនិច្ឆ័យ គឺជាមធ្យោបាយមួយ ដើម្បីវិនិច្ឆ័យថាតើគោលការណ៍មួយ (ស្តីពីការគ្រប់គ្រងព្រៃឈើ) បានបំពេញទៅតាម [គោលការណ៍ទី ១០ ដែលអនុម័តដោយក្រុមប្រឹក្សាភិបាល FSC ស្តីពីចម្ការព្រៃឈើ] ឬទេ។

**សូចនាករ៖** អថេរដែលអាចវាស់វែងបានដោយផ្ទាល់ ឬដោយប្រយោល ដែលត្រូវបានប្រើប្រាស់ដើម្បីរាយការណ៍អំពីស្ថានភាព ឬនិន្នាការរបស់លក្ខខណ្ឌវិនិច្ឆ័យណាមួយ។ សូចនាករ គឺខុសពីវត្ថុបំណង [កែសម្រួលចេញពី សេវារុក្ខាប្រមាញ់កាណាដា សន្លឹកព័ត៌មាន C&I]។ សូចនាករ គឺជារង្វាស់ (ការវាស់វែង) លើទិដ្ឋភាពណាមួយរបស់លក្ខខណ្ឌវិនិច្ឆ័យ៖ អថេរបែបបរិមាណ ឬគុណភាពដែលអាចវាស់វែងបាន ឬអាចពិពណ៌នាបាន ហើយដែលអាចឆ្លុះបញ្ចាំងឲ្យឃើញនូវនិន្នាការអ្វីមួយ នៅពេលមានការអង្កេតជាទៀងទាត់ [ដំណើរការក្រុងម៉ុងត្រេអាល់]។

**គោលការណ៍ទី ១៖ ការគោរពតាមច្បាប់ និងគោលការណ៍ FSC**
**ការគ្រប់គ្រងព្រៃឈើត្រូវគោរពតាមច្បាប់ដែលពាក់ព័ន្ធទាំងអស់របស់ប្រទេស ដែលការគ្រប់គ្រងព្រៃនោះត្រូវបានធ្វើឡើង ព្រមទាំងសន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិនានា ដែលប្រទេសនោះជាហត្ថលេខី ហើយត្រូវគោរពតាមគោលការណ៍ និងលក្ខខណ្ឌវិនិច្ឆ័យរបស់ FSC ទាំងអស់។**

**លក្ខខណ្ឌវិនិច្ឆ័យ ១.១** ការគ្រប់គ្រងព្រៃឈើ ត្រូវគោរពតាមច្បាប់ជាតិ ច្បាប់មូលដ្ឋាន និងការតម្រូវផ្នែករដ្ឋបាលទាំងអស់។

<u>សូចនាករ៖</u>

*១.១.១ មិនមានភស្តុតាង ដែលបង្ហាញអំពីការមិនគោរពតាមច្បាប់ជាតិ ច្បាប់មូលដ្ឋាន និងការតម្រូវផ្នែករដ្ឋបាលណាមួយឡើយ។*

*១.១.២ បុគ្គលិកដែលទទួលខុសត្រូវ បង្ហាញឲ្យឃើញនូវការយល់ដឹងអំពីបរិបទផ្នែកច្បាប់ដែលខ្លួនកំពុងប្រតិបត្តិការ ក៏ដូចជាក្រមអនុវត្ត គោលការណ៍ណែនាំ ឬកិច្ចព្រមព្រៀងនានា។*

*១.១.៣ ការប្រព្រឹត្តខុសច្បាប់ ឬគោលការណ៍ណែនាំផ្សេងៗ ត្រូវបានចងក្រងទុកជាឯកសារ ហើយវិធានការឆ្លើយតបត្រូវបានបង្កើតឡើង (មិនអនុវត្តចំពោះប្រតិបត្តិការ **SLIMF**)។*

**លក្ខខណ្ឌវិនិច្ឆ័យ ១.២** ចាំបាច់ត្រូវបង់ថ្លៃសេវា ថ្លៃឈ្នួល ពន្ធ និងថ្លៃដែលពាក់ព័ន្ធទាំងអស់។

<u>សូចនាករ៖</u>

*១.២.១ មានភស្តុតាងបង្ហាញថា ប្រតិបត្តិការព្រៃឈើបានបង់ថ្លៃសេវា ។ល។ ដែលចាំបាច់ទាំងអស់។*

**លក្ខខណ្ឌវិនិច្ឆ័យ ១.៣** ក្នុងបណ្តាប្រទេសជាហត្ថលេខី ចាំបាច់ត្រូវគោរពតាមបទបញ្ញត្តិក្នុងកិច្ចព្រមព្រៀងដែលជាប់កាតព្វកិច្ចជាអន្តរជាតិទាំងអស់ដូចជា CITES, អនុសញ្ញា ILO, ITTA, និងអនុសញ្ញាស្តីពីជីវៈចម្រុះជាដើម។

<u>សូចនាករ៖</u>

*១.៣.១ អ្នកគ្រប់គ្រងព្រៃឈើ គោរពតាមបទបញ្ញត្តិ CITIES, ITTA និងអនុសញ្ញាស្តីពីជីវៈចម្រុះ។*

*១.៣.២ អ្នកគ្រប់គ្រងព្រៃឈើ គោរពតាមបទបញ្ញត្តិរបស់អង្គការ ILO ដែលសមស្របតាមតំបន់របស់ពួកគេ។ ការអនុវត្តតាមអនុសញ្ញា ILO ខាងក្រោមនេះ គឺជាលក្ខខណ្ឌអប្បបរមាសម្រាប់ការផ្តល់វិញ្ញាបនប័ត្រ៖ ២៩, ៨៧, ៩៧, ៩៨, ១០០, ១០៥, ១១១, ១៣១, ១៣៨, ១៤១, ១៤២, ១៤៣, ១៥៥, ១៦៩, ១៨២, ក្រមអនុវត្តរបស់អង្គការ ILO ស្តីអំពីសុវត្ថិភាព និងសុខភាពសម្រាប់ការងារព្រៃឈើ អនុសាសន៍លេខ ១៣៥ អនុសាសន៍ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមា ឆ្នាំ ១៩៧០ (**SLIMF**៖ អ្នកគ្រប់គ្រងព្រៃឈើបានដឹង និងបានអនុវត្តការគ្រប់គ្រងនានា ដើម្បីធានាបាននូវការបន្តការអនុវត្តតាមច្បាប់ជាតិទាក់ទងនឹងបញ្ហាការងារ)។*

**លក្ខខណ្ឌវិនិច្ឆ័យ ១.៤** ចាំបាច់ត្រូវមានការវាយតម្លៃលើទំនាស់រវាងច្បាប់ បទបញ្ញត្តិ និងគោលការណ៍ ព្រមទាំងលក្ខណៈវិនិច្ឆ័យរបស់ FSC សម្រាប់គោលបំណងនៃការផ្តល់វិញ្ញាបនប័ត្រ ដោយឈរលើមូលដ្ឋានករណីនីមួយៗ ពីសំណាក់អ្នកចេញវិញ្ញាបនប័ត្រ និងភាគីដែលពាក់ព័ន្ធ ឬភាគីដែលរងផលប៉ះពាល់។

<u>សូចនាករ៖</u>

*១.៤.១ ទំនាស់រវាងច្បាប់ បទបញ្ញត្តិ និងគោលការណ៍ ព្រមទាំងលក្ខខណ្ឌនិច្ឆ័យរបស់ FSC ត្រូវបានចងក្រងជាឯកសារ និងរាយការណ៍ជូនទៅស្ថាប័នចេញវិញ្ញាបនប័ត្រ។*

*១.៤.២ មានភស្តុតាងបង្ហាញថា FME ព្យាយាមយ៉ាងសកម្ម ដើម្បីដោះស្រាយជម្លោះដែលត្រូវបានកំណត់ឃើញ។*

**លក្ខខណ្ឌវិនិច្ឆ័យ ១.៥** គួរមានការការពារតំបន់ស្ថិតក្រោមការគ្រប់គ្រងព្រៃឈើពីការប្រមូលផលខុសច្បាប់ ការតាំងទីលំនៅខុសច្បាប់ និងសកម្មភាពគ្មានការអនុញ្ញាតិដទៃទៀត។

<u>សូចនាករ៖</u>

*១.៥.១ មានប្រព័ន្ធដើម្បីកំណត់ និងតាមដាននូវរាល់សកម្មភាពខុសច្បាប់ ឬគ្មានការអនុញ្ញាតិ ហើយប្រព័ន្ធនេះ ត្រូវបានយកមកអនុវត្ត។*

*១.៥.២ មានវិធានការការពារសមស្រប (ឧ. ស្លាកសញ្ញា បុគ្គលិកពិសេស) ដើម្បីជៀសវាងកុំឲ្យកើតមាននូវសកម្មភាពគ្មានការអនុញ្ញាតិ ហើយវិធានការទាំងនេះ ត្រូវបានយកមកអនុវត្ត។*

*១.៥.៣ អ្នកគ្រប់គ្រងព្រៃឈើគួរសហការយ៉ាងសកម្ម ជាមួយអាជ្ញាធរមូលដ្ឋានតាមដែលអាចធ្វើបាន ដើម្បីជួយសម្រួលដល់កម្មករនិយោជិត ឲ្យទទួលបានដីសម្រាប់លំនៅដ្ឋាន។*

**លក្ខខណ្ឌវិនិច្ឆ័យ ១.៦** អ្នកគ្រប់គ្រងព្រៃឈើគួរបង្ហាញនូវការប្តេជ្ញាចិត្តរយៈពេលវែង ដើម្បីគោរពតាមគោលការណ៍ និងលក្ខខណ្ឌវិនិច្ឆ័យរបស់ FSC។

<u>សូចនាករៈ</u>

*១.៦.១ មានការថ្លែងប្តេជ្ញាចិត្តដ៏សមស្រប ដែលត្រូវបានដាក់បញ្ចូលនៅក្នុងឯកសារផ្លូវការរបស់សហគ្រាសព្រៃឈើ ឬសេវាព្រៃឈើនោះ ដោយបង្ហាញការប្តេជ្ញាចិត្តរបស់ស្ថាប័នក្នុងការគោរពតាមបទដ្ឋានវិញ្ញាបនប័ត្ររបស់ FSC ទាក់ទងនឹងព្រៃឈើដែលស្ថិតនៅក្រោមកម្មវត្ថុនៃការវាយតម្លៃ។ សម្រាប់ប្រតិបត្តិការទ្រង់ទ្រាយធំ (>១០.០០០ ហ.ត) FME ចាំបាច់ត្រូវមានគោលនយោបាយផ្សព្វផ្សាយជាសាធារណៈ។*

*១.៦.២ ប្រសិនបើម្ចាស់/អ្នកគ្រប់គ្រង មានការទទួលខុសត្រូវមួយចំនួនលើដីព្រៃឈើ ដែលមិនត្រូវបានរួមបញ្ចូលនៅក្នុងវិសាលភាពនៃការចេញវិញ្ញាបនប័ត្រ ចាំបាច់ត្រូវមានការប្តេជ្ញាចិត្តរយៈពេលវែងយ៉ាងច្បាស់លាស់ ដើម្បីគ្រប់គ្រងព្រៃទាំងអស់យោងទៅតាម FSC P&C។ មុនការចេញវិញ្ញាបនប័ត្រ ព្រៃឈើទាំងនេះ ចាំបាច់ត្រូវអនុវត្តតាមគោលនយោបាយ FSC ច្បាប់ចុងក្រោយបំផុត ស្តីពីការចេញវិញ្ញាបនប័ត្រ សម្រាប់ផ្ទៃដីមួយផ្នែក។*

**គោលការណ៍ទី ២៖ សិទ្ធិកាន់កាប់ សិទ្ធិប្រើប្រាស់ និងការទទួលខុសត្រូវ**
**ចំពោះសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ដី និងធនធានព្រៃឈើរយៈពេលវែង ចាំបាច់ត្រូវមានការកំណត់ ចងក្រងជាឯកសារ និងមានមូលដ្ឋានផ្នែកច្បាប់ច្បាស់លាស់។**

**លក្ខខណ្ឌវិនិច្ឆ័យ ២.១** ត្រូវបង្ហាញភស្តុតាងច្បាស់លាស់អំពីសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ព្រៃឈើរយៈពេលវែងនៅលើដីនោះ (ឧ. ប័ណ្ណកម្មសិទ្ធិដី សិទ្ធិទំនៀមទម្លាប់ ឬកិច្ចព្រមព្រៀងជួល។

<u>សូចនាករ៖</u>

*២.១.១ ឯកសារពិពណ៌នាអំពីស្ថានភាពស្របច្បាប់លើដីនោះ និងការប្រើប្រាស់ព្រៃឈើដែលមានស្រាប់*

*២.១.២ ទំនាស់ស្តីពីសិទ្ធិកាន់កាប់ និងប្រើប្រាស់ដី ត្រូវបានកំណត់ ទទួលស្គាល់ និងចងក្រងជាឯកសារ។*

*២.១.៣ FMU ប្តេជ្ញាចិត្តអនុវត្តការគ្រប់គ្រងព្រៃរយៈពេលវែង យ៉ាងហោចណាស់ស្មើនឹងអំឡុងពេលវិលជុំ ឬវដ្តនៃការប្រមូលផល។*

**លក្ខខណ្ឌវិនិច្ឆ័យ ២.២** សហគមន៍មូលដ្ឋាន ដែលមានសិទ្ធិកាន់កាប់ ឬសិទ្ធិប្រើប្រាស់តាមផ្លូវច្បាប់ ឬតាមបែបទំនៀមទម្លាប់ ត្រូវបន្តការគ្រប់គ្រងតាមការចាំបាច់ ដើម្បីការពារសិទ្ធិ ឬធនធានរបស់ពួកគេ លើប្រតិបត្តិការព្រៃឈើ លើកលែងតែពួកគាត់ធ្វើប្រតិភូកម្មសិទ្ធិគ្រប់គ្រងនោះ ដោយមានការយល់ព្រមដោយសេរី និងមានព័ត៌មានគ្រប់គ្រាន់ ទៅឲ្យភ្នាក់ងារដទៃទៀត។

<u>សូចនាករ៖</u>

*២.២.១ សហគមន៍មូលដ្ឋាន ដែលមានសិទ្ធិកាន់កាប់ ឬសិទ្ធិប្រើប្រាស់តាមផ្លូវច្បាប់ ឬតាមបែបទំនៀមទម្លាប់ត្រូវបានកំណត់ ចងក្រងជាឯកសារ និងធ្វើផែនទី។*

*២.២.២ ដំណើរការធ្វើផែនការរបស់ FMU រួមបញ្ចូលនូវការចូលរួមរបស់សហគមន៍ ឬភាគីនៅថ្នាក់មូលដ្ឋាន ដែលមានសិទ្ធិកាន់កាប់ ឬសិទ្ធិប្រើប្រាស់តាមផ្លូវច្បាប់ ឬតាមបែបទំនៀមទម្លាប់*

*២.២.៣ អ្នកគ្រប់គ្រងព្រៃ ផ្តល់ឲ្យសហគមន៍មូលដ្ឋាននូវការគ្រប់គ្រងលើប្រតិបត្តិការព្រៃឈើ ក្នុងកម្រិតមួយដែលចាំបាច់ដើម្បីការពារសិទ្ធិ និងធនធានរបស់ពួកគេ។*

*២.២.៤ ក្នុងករណីសហគមន៍បានធ្វើប្រតិភូកម្មការគ្រប់គ្រងសិទ្ធិកាន់កាប់ ឬសិទ្ធិប្រើប្រាស់តាមផ្លូវច្បាប់ ឬតាមបែបទំនៀមទម្លាប់របស់ខ្លួនទាំងមូល ឬមួយផ្នែក ការធ្វើប្រតិភូកម្មនេះ អាចធ្វើឡើងបានដោយមានការបញ្ជាក់អះអាងដោយកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ និង/ឬការសម្ភាសជាមួយអ្នកតំណាងសហគមន៍មូលដ្ឋាន។*

**លក្ខខណ្ឌវិនិច្ឆ័យ ២.៣** យន្តការសមស្រប ត្រូវបានយកមកប្រើប្រាស់ដើម្បីដោះស្រាយវិវាទលើបណ្តឹងស្តីពីសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់។ ស្ថានភាព និងដំណើរការមកទល់ពេលបច្ចុប្បន្នរបស់វិវាទមិនទាន់ដោះស្រាយ នឹងត្រូវបានយកមកពិចារណាយ៉ាងចំហរ នៅក្នុងការវាយតម្លៃដើម្បីផ្តល់វិញ្ញាបនប័ត្រ។ វិវាទធំដុំ ដែលពាក់ព័ន្ធនឹងផលប្រយោជន៍ច្រើន តាមធម្មតានឹងធ្វើឲ្យប្រតិបត្តិការមួយត្រូវបាត់បង់គុណវុឌ្ឍ ក្នុងការទទួលបានវិញ្ញាបនប័ត្រតែម្តង។

<u>សូចនាករ៖</u>

*២.៣.១ មាននីតិវិធីជាលាយល័ក្ខណ៍អក្សរសម្រាប់ដោះស្រាយបណ្តឹងអំពីសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ (**SLIMF**៖ មិនមានវិវាទដោះស្រាយមិនបានណាមួយទាក់ទងនឹងបណ្តឹងស្តីពីសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ដី នៅក្នុងព្រៃ។ វិវាទ ឬសារទុក ត្រូវបានដោះស្រាយដោយប្រើប្រាស់យន្តការ និងស្ថាប័នដែលត្រូវបានទទួលស្គាល់នៅថ្នាក់មូលដ្ឋាន)។*

*២.៣.២ មានការរក្សាកំណត់ត្រាស្តីពីវិវាទ និងភាពជឿនលឿននៃដំណោះស្រាយវិវាទទាំងនោះ រួមទាំងភស្តុតាងទាក់ទងនឹងវិវាទ និងឯកសារស្តីពីជំហាននានា ដែលត្រូវបានធ្វើឡើងដើម្បីដោះស្រាយវិវាទ។*

*២.៣.៣ មានគោលនយោបាយគ្រប់គ្រង និងនីតិវិធីប្រតិបត្តិការ ដែលតម្រូវថា ក្នុងករណីមានវិវាទ ឬការមិនចុះសម្រុងគ្នា រវាងសហគមន៍មូលដ្ឋាន និងអ្នកគ្រប់គ្រងព្រៃឈើទាក់ទងនឹងសិទ្ធិដីធ្លី ប្រតិបត្តិការព្រៃឈើដែលអាចធ្វើឲ្យសហគមន៍បាត់បង់សិទ្ធិទាំងនេះ នាពេលអនាគត នឹងត្រូវបានបញ្ឈប់ រហូតទាល់តែវិវាទត្រូវបានដោះស្រាយ (មិនអនុវត្តចំពោះ **SLIMF**)*

*២.៣.៤ មិនមានភស្តុតាង បង្ហាញអំពីវិវាទស្តីពីសិទ្ធិកាន់កាប់ និង/ឬសិទ្ធិប្រើប្រាស់មិនត្រូវបានដោះស្រាយ ដែលមានទំហំធំ និងពាក់ព័ន្ធជាមួយផលប្រយោជន៍ច្រើន។ ចំណុចនេះ*

*ត្រូវអនុវត្តចំពោះ FMU ទាំងឡាយណាដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ម្ចាស់/អ្នកគ្រប់គ្រងព្រៃ។*

## **គោលការណ៍ទី ៣៖ សិទ្ធិរបស់ជនជាតិដើមភាគតិច**

**សិទ្ធិកាន់កាប់ ឬសិទ្ធិប្រើប្រាស់តាមផ្លូវច្បាប់ ឬតាមបែបទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច ដើម្បីជាម្ចាស់កម្មសិទ្ធិ ប្រើប្រាស់ និងគ្រប់គ្រងដី ឬវណភាពទឹកដី និងធនធានរបស់ខ្លួន ត្រូវបាន ទទួលស្គាល់ និងគោរព។**

**លក្ខខណ្ឌវិនិច្ឆ័យ ៣.១** ជនជាតិដើមភាគតិច ត្រូវត្រួតត្រាលើការគ្រប់គ្រងព្រៃឈើនៅលើដី និងបូរណភាពទឹកដីរបស់ខ្លួន លើកលែងតែពួកគាត់បានធ្វើប្រតិភូកម្មសិទ្ធិត្រួតត្រានេះដោយមានកិច្ចព្រមព្រៀងដោយសេរី និងមានព័ត៌មានគ្រប់គ្រាន់ទៅឲ្យភ្នាក់ងារដទៃ។

<u>សូចនាករ៖</u>

*៣.១.១ អ្នកគ្រប់គ្រងព្រៃឈើបង្កើតឯកសារស្ដីពីអត្តសញ្ញាណ ទីតាំង និងចំនួនប្រជាជន ជនជាតិដើមភាគតិច និងប្រជាជនដែលមានលក្ខណៈបែបប្រពៃណីទាំងអស់ រួមទាំងក្រុមប្រជាជនចល័តដែលកំពុងរស់នៅក្នុងបរិវេណស្ថិតក្រោមការគ្រប់គ្រង។*

*៣.១.២ រាល់អំណះអំណាងទាមទារដីធ្លី បូរណភាពទឹកដី ឬសិទ្ធិកាន់កាប់ទាំងអស់ ដែលមាននៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រង ត្រូវបានចងក្រងជាឯកសារ និង/ឬធ្វើផែនទីយ៉ាងច្បាស់លាស់។*

*៣.១.៣ សិទ្ធិដែលត្រូវបានកំណត់ឃើញ ទាក់ទងនឹងសូចនាករលេខ ៣.១.២ ត្រូវបានគោរព។*

*៣.១.៤ ប្រតិបត្តិការគ្រប់គ្រងព្រៃឈើ មិនត្រូវធ្វើឡើងនៅក្នុងតំបន់ទាំងឡាយណាដែលត្រូវបានកំណត់ឃើញនៅក្នុងសូចនាករលេខ ៣.១.២ ខាងលើ ដោយគ្មានភស្តុតាងច្បាស់លាស់ដើម្បីបញ្ជាក់ពីការយល់ព្រមដោយសេរី និងបានទទួលព័ត៌មានគ្រប់គ្រាន់ពីសំណាក់ប្រជាជនជនជាតិដើមភាគតិច ឬប្រជាជនដែលមានលក្ខណៈបែបប្រពៃណីដែលទាមទារនូវសិទ្ធិលើដីធ្លី បូរណភាពទឹកដី ឬសិទ្ធិតាមបែបទំនៀមទម្លាប់ទាំងនោះឡើយ។*

**លក្ខខណ្ឌវិនិច្ឆ័យ ៣.២** ការគ្រប់គ្រងព្រៃឈើមិនត្រូវបង្កឲ្យមានការបាត់បង់ធនធាន ឬសិទ្ធិកាន់កាប់ដីធ្លីរបស់ប្រជាជនជនជាតិដើមភាគតិច ទោះជាដោយផ្ទាល់ ឬដោយប្រយោលក្ដី។

<u>សូចនាករ៖</u>

*៣.២.១ មិនមានភស្តុតាង ឬសញ្ញាណណាមួយដែលបង្ហាញថា FME អាចនឹងគម្រាមកំហែងដល់សិទ្ធិ និងធនធានរបស់ជនជាតិដើមភាគតិចឡើយ។*

*៣.២.២ ប្រជាជនជនជាតិដើមភាគតិច បានទទួលការជូនដំណឹងយ៉ាងច្បាស់លាស់ អំពីផលប៉ះពាល់ទាំងឡាយណា ដែលការគ្រប់គ្រងព្រៃឈើអាចនឹងបង្ករឲ្យមានមកលើធនធាន ឬសិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគាត់ ហើយព្រំដែនរួមរវាងដីរបស់សហគមន៍ត្រូវបានកំណត់ព្រំដែនរួបវន្ត ក្រោមការមើលខុសត្រូវពីសំណាក់សហគមន៍ មុនពេលមានប្រតិបត្តិការណាមួយអាចធ្វើឡើងបាន។*

**លក្ខខណ្ឌវិនិច្ឆ័យ ៣.៣** ទីតាំងដែលមានសារៈសំខាន់ពិសេសផ្នែកវប្បធម៌ អេកូឡូស៊ី សេដ្ឋកិច្ច ឬសាសនា ចំពោះប្រជាជនជនជាតិដើមភាគតិច ត្រូវបានកំណត់យ៉ាងច្បាស់លាស់ក្នុងកិច្ចសហការជាមួយប្រជាជនទាំងនេះ ហើយត្រូវបានទទួលស្គាល់ និងការពារដោយអ្នកគ្រប់គ្រងព្រៃឈើ។

<u>សូចនាករ៖</u>

*៣.៣.១ ទីតាំងដែលមានសារៈសំខាន់ពិសេសផ្នែកវប្បធម៌ អេកូឡូស៊ី សេដ្ឋកិច្ច ឬសាសនា ចំពោះប្រជាជនជនជាតិដើមភាគតិច ត្រូវបានកំណត់ និងធ្វើផែនទី ក្នុងកិច្ចសហការជាមួយភាគីពាក់ព័ន្ធដែលរងផលប៉ះពាល់ (SLIMF៖ ទីតាំងដែលមានសារៈសំខាន់ពិសេសផ្នែកវប្បធម៌ អេកូឡូស៊ី សេដ្ឋកិច្ច ឬសាសនា ចំពោះប្រជាជនជនជាតិដើមភាគតិច និងការតម្រូវពិសេសនានា ត្រូវបានគេដឹង)។*

*៣.៣.២ គោលនយោបាយ និងនីតិវិធីដើម្បីការពារទីតាំងទាំងនេះ ក្នុងអំឡុងពេលប្រតិបត្តិការការគ្រប់គ្រង ត្រូវបានចងក្រងជាឯកសារលាយលក្ខណ៍អក្សរ និងយកមកអនុវត្ត (SLIMF៖ វិធានការសមស្របសម្រាប់ការពារទីតាំងទាំងនេះ ក្នុងអំឡុងពេលប្រតិបត្តិការការគ្រប់គ្រង ត្រូវបានយកមកអនុវត្ត)។*

**លក្ខខណ្ឌវិនិច្ឆ័យ ៣.៤** ប្រជាជនជនជាតិដើមភាគតិច បានទទួលសំណងប៉ះប៉ូវ សម្រាប់ការប្រើប្រាស់ចំណេះដឹងបែបប្រពៃណីរបស់ពួកគាត់ទាក់ទងនឹងការប្រើប្រាស់ពូជព្រៃឈើ ឬប្រព័ន្ធគ្រប់គ្រងនៅក្នុងប្រតិបត្តិការព្រៃឈើ។ សំណងប៉ះប៉ូវនេះ ត្រូវមានការយល់ព្រមដោយសេរី និងមានព័ត៌មានគ្រប់គ្រាន់ជាផ្លូវការពីពួកគាត់ មុនពេលប្រតិបត្តិការព្រៃឈើអាចចាប់ផ្តើមបាន។

<u>សូចនាករ៖</u>

៣.៤.១ ចំណេះដឹងបែបប្រពៃណីរបស់ប្រជាជនជនជាតិដើមភាគតិច ទាក់ទងនឹងការប្រើប្រាស់ពូជព្រៃឈើ ឬប្រព័ន្ធគ្រប់គ្រងនៅក្នុងប្រតិបត្តិការព្រៃឈើដែល FME កំពុងប្រើប្រាស់ ឬនឹងអាចយកមកប្រើប្រាស់ជាលក្ខណៈពាណិជ្ជកម្ម ត្រូវបានចងក្រងជាឯកសារលាយលក្ខណ៍អក្សរ។

៣.៤.២ មានវត្តមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ឬកិច្ចព្រមព្រៀងផ្ទាល់មាត់ ស្តីពីល័ក្ខខ័ណ្ឌក្នុងការផ្តល់សំណងប៉ះប៉ូវ នៅពេលមានការប្រើប្រាស់ចំណេះដឹងបែបប្រពៃណីសម្រាប់គោលបំណងផ្នែកពាណិជ្ជកម្ម។

៣.៤.៣ រាល់សំណងប៉ះប៉ូវដែលបានព្រមព្រៀងគ្នា ត្រូវបានផ្តល់សំណងជាក់ស្តែង។

## គោលការណ៍ទី ៤៖ ទំនាក់ទំនងជាមួយសហគមន៍ និងសិទ្ធិរបស់កម្មករនិយោជិត

**ប្រតិបត្តិការព្រៃឈើ ត្រូវរក្សា ឬពង្រឹងសុខមាលភាពសង្គម និងសេដ្ឋកិច្ចរយៈពេលវែងរបស់កម្មករនិយោជិតព្រៃឈើ និងសហគមន៍មូលដ្ឋាន។**

**លក្ខខណ្ឌវិនិច្ឆ័យ** ៤.១ សហគមន៍នៅក្នុង ឬនៅជាប់តំបន់គ្រប់គ្រងព្រៃឈើ គួរបានទទួលឱកាសផ្នែកមុខរបរ ការបណ្តុះបណ្តាល និងសេវាដទៃទៀត។

<u>សូចនាករ៖</u>

*៤.១.១ ប្រជាជនមូលដ្ឋាន និងប្រជាជនដែលរស់ពឹងផ្អែកលើព្រៃ មានលទ្ធភាពទទួលបានឱកាសផ្នែកមុខរបរ និងការបណ្តុះបណ្តាល។*

*៤.១.២ នៅក្នុងប្រតិបត្តិការទ្រង់ទ្រាយធំ (> ១០.០០០ ហ.ត) ការបណ្តុះបណ្តាល និង/ឬការជួយជ្រោមជ្រែងក្នុងទម្រង់សមស្របដទៃទៀតត្រូវសម្រាប់ប្រជាជនមូលដ្ឋាន និងកម្មករនិយោជិត ដើម្បីឆ្លើយតបទៅនឹងតម្រូវការបុគ្គលិករយៈពេលវែងរបស់ស្ថាប័នត្រូវបានបង្កើតឡើង និងទទួលបានការគាំទ្រ។*

*៤.១.៣ ការគាំទ្រ ត្រូវបានផ្តល់សម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខានានា នៅថ្នាក់មូលដ្ឋាន តាមកម្រិតសមស្របជាមួយនឹងធនធានព្រៃឈើ (មិនអនុវត្តចំពោះប្រតិបត្តិការ **SLIMF**)។*

*៤.១.៤ និយោជិតមិនរងនូវការរើសអើង ក្នុងការជួល ការឡើងឋានៈ ប្រាក់បណ្តេញចេញ និងមុខរបរ ទាក់ទងនឹងសន្តិសុខសង្គម។*

*៤.១.៥ អ្នកគ្រប់គ្រងព្រៃឈើ ត្រូវធានាឲ្យបានថា និយោជិត អ្នកជាប់កិច្ចសន្យា និងអ្នកម៉ៅការបន្តទាំងអស់ ដែលធ្វើការនៅក្នុងព្រៃឈើរបស់អ្នកកាន់វិញ្ញាបនប័ត្រ បានទទួលប្រាក់ឈ្នួលសមរម្យ និងអត្ថប្រយោជន៍ដទៃទៀត ដែលឆ្លើយតប ឬលើសពីការតម្រូវរបស់ច្បាប់ និងការតម្រូវនានា ដែលមានចែងនៅក្នុងមុខរបរប្រហាក់ប្រហែល ក្នុងតំបន់នោះ។*

**លក្ខខណ្ឌវិនិច្ឆ័យ** ៤.២ ការគ្រប់គ្រងព្រៃឈើ ត្រូវអនុវត្តតាម ឬអនុវត្តឲ្យលើសពីច្បាប់ និង/ឬបទបញ្ញត្តិដែលពាក់ព័ន្ធទាំងអស់ ស្តីអំពីសុខភាព និងសុវត្ថិភាពរបស់និយោជិត និងគ្រួសាររបស់ពួកគេ។

<u>សូចនាករ៖</u>

៤.២.១ អ្នកគ្រប់គ្រងមានចំណេះដឹងអំពីគោលការណ៍ណែនាំ និងបទបញ្ញត្តិដែលពាក់ព័ន្ធស្តីពីសុខភាព និងសុវត្ថិភាព។ សម្រាប់អង្គភាពទ្រង់ទ្រាយធំ (> ១០.០០០ ហ.ត) ត្រូវមានគោលនយោបាយស្តីពីសុវត្ថិភាព និងសុខភាព និងប្រព័ន្ធគ្រប់គ្រង នៅក្នុងអង្គភាព។

៤.២.២ អ្នកគ្រប់គ្រង បានវាយតម្លៃហានីភ័យនានាដែលអាចមានចំពោះកម្មករនិយោជិតដែលធ្វើការងារ និងប្រើឧបករណ៍ជាក់លាក់ ហើយបានចាត់វិធានការដើម្បីកាត់បន្ថយឬលុបបំបាត់ហានីភ័យទាំងអស់នេះ (SLIMF៖ រាល់ការងារទាំងអស់ដែលត្រូវបានធ្វើនៅក្នុងព្រៃ ចាំបាច់ត្រូវតែគោរពតាមច្បាប់ និងបទបញ្ញត្តិនានាស្តីពីសុខភាព និងសុវត្ថិភាព)។

៤.២.៣ ការបណ្តុះបណ្តាលស្តីពីសុវត្ថិភាព ត្រូវបានធ្វើឡើង ទាក់ទងនឹងការងាររបស់កម្មករនិយោជិត និងឧបករណ៍ដែលប្រើ។

៤.២.៤ កម្មករនិយោជិត រួមទាំងអ្នកម៉ៅការបន្ត បានទទួលឧបករណ៍ការពារសុវត្ថិភាពទាក់ទងទៅនឹងការងាររបស់ពួកគាត់ ឧបករណ៍ដែលពួកគាត់ប្រើ និងអនុលោមទៅតាមក្រមអនុវត្តរបស់អង្គការ ILO ស្តីពីសុវត្ថិភាព និងសុខភាពនៅក្នុងព្រៃ (SLIMF៖ រាល់ការងារទាំងអស់ដែលត្រូវបានធ្វើនៅក្នុងព្រៃ ចាំបាច់ត្រូវតែគោរពតាមច្បាប់ និងបទបញ្ញត្តិនានាស្តីពីសុខភាព និងសុវត្ថិភាព។ អ្នកគ្រប់គ្រងព្រៃឈើ ត្រូវបង្ហាញនូវកិច្ចខិតខំយ៉ាងសមហេតុផលដើម្បីគោរពតាមក្រមអនុវត្តរបស់អង្គការ ILO ស្តីពីសុវត្ថិភាព និងសុខភាពនៅក្នុងព្រៃ ប្រសិនបើមាននៅក្នុងប្រទេស)។

៤.២.៥ ប្រសិនបើកម្មករនិយោជិតស្នាក់នៅក្នុងជំរុំ ល័ក្ខខ័ណ្ឌកន្លែងរស់នៅ និងអាហាររូបត្ថម្ភរបស់ពួកគាត់ យ៉ាងហោចណាស់ក៏ត្រូវអនុលោមទៅតាមក្រមអនុវត្តរបស់អង្គការ ILO ស្តីពីសុវត្ថិភាព និងសុខភាពនៅក្នុងព្រៃដែរ។

៤.២.៦ ត្រូវមានប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងមួយ ដើម្បីធានាបាននូវសុខភាព និងការថែទាំ (រួមទាំងស្ថិតិស្តីពីគ្រោះថ្នាក់ដែលកើតមានផងដែរ)។

៤.២.៧ វិធានការផ្នែកសុខភាព និងការថែទាំ បានទទួលការគាំទ្រពីនិយោជក (ឧ. ប្រាក់ឧបត្ថម្ភសម្រាប់ទិញឧបករណ៍ការពារសុវត្ថិភាពផ្ទាល់ខ្លួន)។

៤.២.៨ មានអត្ថប្រយោជន៍ដើម្បីធានានូវសំណងប៉ះប៉ូវ ក្នុងករណីមានគ្រោះថ្នាក់កើតឡើង។

៤.២.៩ អ្នកជាប់កិច្ចសន្យាទាំងអស់ ដែលមិនគោរពតាមសូចនាករដូចដែលបានពោលខាងលើត្រូវបានដកចេញពីប្រតិបត្តិការព្រៃឈើ។

*៤.២.១០ ប្រាក់ឈ្នួល និងសុខមាលភាពសង្គមដទៃទៀតរបស់ពលករធ្វើការនៅក្នុង FMU រួមទាំងអ្នកម៉ៅការបន្តផងដែរ ត្រូវមានកម្រិតស្មើ ឬខ្ពស់ជាងអត្រាមធ្យមនៅក្នុងតំបន់។*

**លក្ខខណ្ឌវិនិច្ឆ័យ ៤.៣** សិទ្ធិរបស់កម្មករនិយោជិត ក្នុងការចងក្រងជាសហជីព និងចរចាដោយស្ម័គ្រចិត្តជាមួយនិយោជករបស់ខ្លួន ត្រូវបានធានាស្របតាមខ្លឹមសារដែលមានចែងក្នុងអនុសញ្ញាលេខ ៨៧ និង ៩៨ របស់អង្គការពលកម្មអន្តរជាតិ (ILO)។

<u>សូចនាករ៖</u>

*៤.៣.១ ល័ក្ខខ័ណ្ឌការងារ អនុលោមតាមអនុសញ្ញាលេខ ៨៧ របស់អង្គការពលកម្មអន្តរជាតិ (អនុសញ្ញានេះ ទាក់ទងនឹងសិទ្ធិរបស់កម្មករនិយោជិតស្តីពី៖ សេរីភាពក្នុងការចងក្រងជាសហជីព និងការការពារសិទ្ធិក្នុងការចងក្រងជាសហជីព)។*

*៤.៣.២ ល័ក្ខខ័ណ្ឌការងារអនុលោមតាមអនុសញ្ញាលេខ ៩៨ របស់អង្គការពលកម្មអន្តរជាតិ (អនុសញ្ញានេះ ទាក់ទងនឹងសិទ្ធិរបស់កម្មករនិយោជិតស្តីពី៖ ការចងក្រងជាសហជីព និងការចរចាជាសមូហសភាព)។*

*៤.៣.៣ មានចំណុចមួយនៅក្នុងកិច្ចសន្យារបស់កម្មករនិយោជិត ស្តីអំពីការដោះស្រាយបញ្ហា។ កម្មករនិយោជិត គួរមានឱកាសនិយាយចេញមកនូវកង្វល់របស់ខ្លួន ក្នុងទម្រង់រក្សាការសម្ងាត់ (ឧ. ប្រអប់សំបុត្រ)។*

*៤.៣.៤ ប្រាក់ឈ្នួល បៀវត្ស និងអត្ថប្រយោជន៍ផ្នែកសុខមាលភាពផ្នែកសង្គមដទៃទៀត ដែលត្រូវបានព្រមព្រៀងគ្នារវាងនិយោជក និងកម្មករនិយោជិត ឬអ្នកតំណាងរបស់ពួកគេ (ឧ. សហជីព) ត្រូវបានកំណត់ជាក់លាក់នៅក្នុងកិច្ចសន្យា។*

**លក្ខខណ្ឌវិនិច្ឆ័យ ៤.៤** ការធ្វើផែនការ និងប្រតិបត្តិការការគ្រប់គ្រងព្រៃឈើ ត្រូវរួមបញ្ចូលនូវលទ្ធផលនៃការវាយតម្លៃលើផលប៉ះពាល់ផ្នែកសង្គម។ ត្រូវរក្សាឲ្យមានការពិគ្រោះយោបល់ជាមួយមនុស្ស និងក្រុមដែលរងផលប៉ះពាល់ដោយផ្ទាល់ពីប្រតិបត្តិការការគ្រប់គ្រងព្រៃឈើ។

<u>សូចនាករ៖</u>

*៤.៤.១ មានប្រព័ន្ធដើម្បីផ្តល់ការវាយតម្លៃលើផលប៉ះពាល់ផ្នែកសង្គម ដែលសមស្របទៅនឹងទំហំ និងកម្លាំងនៃប្រតិបត្តិការរបស់ពួកគេ ដែល៖*

*- កំណត់អត្តសញ្ញាណក្រុមដែលរងផលប៉ះពាល់*

*- រួមបញ្ចូលនូវការពិគ្រោះយោបល់ជាមួយក្រុមដែលរងផលប៉ះពាល់*

- *កំណត់នូវផលប៉ះពាល់សំខាន់ដែលប្រតិបត្តិការអាចបង្ករឡើងចំពោះក្រុមទាំងនោះ*
- *កំណត់នូវវិធានការនានាដើម្បីកែលំអរផលប៉ះពាល់ជាអវិជ្ជមានដែលត្រូវបានកំណត់ឃើញនោះឡើងវិញ។*
- *ផ្តល់ការទំនាក់ទំនងជាប្រចាំជាមួយក្រុមដែលរងផលប៉ះពាល់ ដើម្បីតាមដានប្រសិទ្ធភាពនៃវិធានការទាំងនោះ។*

*៤.៤.២ ផលប៉ះពាល់ជាអវិជ្ជមាន ឱកាសសម្រាប់ផលប៉ះពាល់ជាវិជ្ជមាន និងចំណុចជាសក្តានុពលអាចមានទំនាស់ ដែលត្រូវបានកំណត់ឃើញតាមរយៈការវាយតម្លៃ ត្រូវបានឆ្លើយតបយ៉ាងគ្រប់គ្រាន់ នៅក្នុងការធ្វើផែនការការគ្រប់គ្រង (មិនអនុវត្តចំពោះ SLIMF)។*

*៤.៤.៣ បញ្ជីបច្ចុប្បន្នភាពភាគីពាក់ព័ន្ធ ត្រូវបានរក្សាទុក (SLIMF៖ សហគ្រាសស្គាល់អ្នកពាក់ព័ន្ធ)*

*៤.៤.៤ មានប្រព័ន្ធដើម្បីពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធជាប្រចាំ (ឧ. កិច្ចប្រជុំតុមូល) ហើយប្រព័ន្ធនេះត្រូវបានយកមកអនុវត្ត។*

**លក្ខខណ្ឌវិនិច្ឆ័យ ៤.៥** មានយន្តការសមស្របដើម្បីដោះស្រាយសារទុក និងផ្តល់សំណងប៉ះប៉ូវដ៏យុត្តិធម៌ ក្នុងករណីមានការបាត់បង់ ឬការខូចខាតនានា ដែលប៉ះពាល់ដល់សិទ្ធិតាមផ្លូវច្បាប់ ឬសិទ្ធិបែបទំនៀមទម្លាប់ ទ្រព្យសម្បត្តិ ធនធាន ឬជីវភាពរស់នៅរបស់ប្រជាជនក្នុងមូលដ្ឋាន។ ត្រូវមានវិធានការធ្វើឡើង ដើម្បីជៀសវាងនូវការបាត់បង់ ឬខូចខាតទាំងនេះ។

<u>សូចនាករ៖</u>

*៤.៥.១ នីតិវិធីប្រកបដោយភាពស៊ីសង្វាក់ និងប្រសិទ្ធិភាព ដើម្បីដោះស្រាយវិវាទ និងសារទុក្ខ និងកំណត់សំណងប៉ះប៉ូវសម្រាប់ការខូចខាត ឬបាត់បង់ ត្រូវបានយកមកអនុវត្ត។ ប្រតិបត្តិការទ្រង់ទ្រាយធំ (> ១០.០០០ ហ.ត) ត្រូវមាននីតិវិធីដោះស្រាយវិវាទជាលាយលក្ខណ៍អក្សរ ហើយត្រូវប្រកាសប្រាប់ពីវត្តមាននីតិវិធីដោះស្រាយវិវាទនេះ នៅក្នុងកិច្ចប្រជុំភាគីពាក់ព័ន្ធ)។*

*៤.៥.២ FME ខិតខំប្រឹងប្រែងយ៉ាងសមហេតុផល ដើម្បីជៀសវាងនូវការបាត់បង់ និងការខូចខាត ដែលប៉ះពាល់ដល់ប្រជាជនក្នុងមូលដ្ឋាន និងខិតខំដោះស្រាយសារទុក្ខនានាទាក់ទងនឹងសិទ្ធិតាមផ្លូវច្បាប់ សំណងការខូចខាត និងផលប៉ះពាល់ជាអវិជ្ជមាននានា។*

**គោលការណ៍ទី ៥៖ អត្ថប្រយោជន៍ដែលទទួលបានពីព្រៃឈើ**

**ប្រតិបត្តិការគ្រប់គ្រងព្រៃឈើ ត្រូវលើកទឹកចិត្តចំពោះការប្រើប្រាស់ពហុផលិតផល និងសេវារបស់ព្រៃឈើប្រកបដោយប្រសិទ្ធិផល ដើម្បីធានាបាននូវលទ្ធភាពផ្នែកសេដ្ឋកិច្ច និងអត្ថប្រយោជន៍ផ្នែកបរិដ្ឋាន និងសង្គម ដ៏ទូលំទូលាយ។**

**លក្ខខណ្ឌវិនិច្ឆ័យ ៥.១** ការគ្រប់គ្រងព្រៃឈើ គួរពុះពារឆ្ពោះទៅរកលទ្ធភាពផ្នែកសេដ្ឋកិច្ច ហើយស្របពេលជាមួយគ្នានោះដែរ ក៏ត្រូវយកចិត្តទុកដាក់លើថ្លៃចំណាយសម្រាប់ផលិតកម្មផ្នែកបរិដ្ឋាន សង្គម និងប្រតិតបត្តិការ ហើយត្រូវធានាឲ្យមានការវិនិយោគដែលចាំបាច់នានាដើម្បីធានានូវផលិតភាពផ្នែកអេកូឡូស៊ីរបស់ព្រៃឈើ។

<u>សូចនាករ៖</u>

*៥.១.១ មានផែនការការងារ និងផែនការថវិកា ដែលបង្ហាញពីការចំណាយ និងចំណូលរំពឹងទុកសម្រាប់រយៈពេលយ៉ាងហោចណាស់ប្រាំឆ្នាំសារពើភ័ណ្ឌ។*

*៥.១.២ ថវិកាប្រចាំឆ្នាំ មានបញ្ជាក់អំពីការចំណាយដែលពាក់ព័ន្ធនឹងការអនុវត្តនូវការប្តេជ្ញាចិត្តផ្នែកសង្គម និងបរិដ្ឋាន ដែលបានកំណត់ឃើញ (សូមមើលគោលការណ៍ទី ៤ និង ទី ៦ នៅក្នុងបទដ្ឋាននេះ) ក៏ដូចជាការចំណាយផ្នែកប្រតិបត្តិការទាំងអស់ (**SLIMF**៖ អ្នកគ្រប់គ្រងព្រៃឈើ ផ្តោតគោលដៅលើការធ្វើយ៉ាងណាឲ្យឈានទៅដល់ស្ថានភាពដែលអាចធ្វើបានផ្នែកសេដ្ឋកិច្ច ដែលអនុញ្ញាតិឲ្យអាចគ្រប់គ្រងព្រៃឈើរយៈពេលវែងបាន)។*

*៥.១.៣ ចំណូលដែលត្រូវបានទស្សន៍ទាយទុកក្នុងថវិកាប្រចាំឆ្នាំ គឺផ្អែកលើការសន្មត់យ៉ាងសមហេតុផល និងអនុលោមទៅតាមទំហៀបតម្លៃ នៅថ្នាក់តំបន់ និងថ្នាក់ជាតិ។*

*៥.១.៤ ប្រសិនបើចាំបាច់ ត្រូវមានការវិនិយោគ ធ្វើយ៉ាងណាដើម្បីរក្សាផលិតភាពផ្នែកអេកូឡូស៊ីរបស់ព្រៃឈើ។*

**លក្ខខណ្ឌវិនិច្ឆ័យ ៥.២** ប្រតិបត្តិការការគ្រប់គ្រងព្រៃឈើ និងការរកទីផ្សារ គួរលើកទឹកចិត្តដល់ការប្រើប្រាស់ផលិតផលនានារបស់ព្រៃឈើឲ្យអស់ពីលទ្ធភាព និងកែច្នៃផលិតផលទាំងនោះក្នុងមូលដ្ឋាន។

<u>សូចនាករ៖</u>

*៥.២.១ គ្រប់ពេលដែលអាចធ្វើបាន FME គួរលើកកំពស់ការប្រើប្រាស់ និងការប្រមូលផល ប្រកបដោយនិរន្តរភាពនូវពូជធម្មតា ពូជមិនសូវល្បីឈ្មោះ និងអនុផលព្រៃឈើនានា (មិនអនុវត្តចំពោះ SLIMF)។*

*៥.២.២ សហគ្រាសមានទំនោរលក់ផលិតផលព្រៃឈើរបស់ខ្លួនទៅឲ្យឧស្សាហកម្មកែច្នៃ ដែលមាននៅក្នុងមូលដ្ឋាន ឬក្នុងតំបន់* លើកលែងតែមានហេតុផលសមស្រប ក្នុងការមិនលក់ទៅឲ្យឧស្សាហកម្មទាំងនេះ។

**លក្ខខណ្ឌវិនិច្ឆ័យ ៥.៣** ប្រតិបត្តិការព្រៃឈើ គួរកាត់បន្ថយកាកសំណល់ពាក់ព័ន្ធនឹងការប្រមូលផល និងប្រតិបត្តិការកែច្នៃនៅនឹងកន្លែង និងជៀសវាងកុំឲ្យប៉ះពាល់ដល់ធនធានព្រៃឈើដទៃទៀត។

<u>សូចនាករ៖</u>

*៥.៣.១ បច្ចេកទេសប្រមូលផល ត្រូវបានរចនាឡើងដើម្បីជៀសវាងកុំឲ្យបាក់បែកឈើហ៊ុប ថយចុះគុណភាពក្តារ និងប៉ះពាល់ដល់ដើមឈើឈរ។*

*៥.៣.២ វិធីសាស្ត្រនានាដើម្បីបញ្ចៀសផលប៉ះពាល់ដែលត្រូវបានមូលដ្ឋានកំណត់ថាមិនអាចទទួលយកបាន ទៅលើដី ប្រព័ន្ធទឹក និងដីសើម តំបន់មានទឹកស្ទឹងទន្លេ តំបន់ព្រៃរេចរិល និងតំបន់រសើប វិធីសាស្ត្រនេះកំពុងត្រូវបានយកមកអនុវត្ត។*

*៥.៣.៣ ចំពោះសហគ្រាសខ្នាតធំ (> ១០.០០០ ហ.ត) ប្រតិបត្តិការកែច្នៃនៅនឹងកន្លែង ត្រូវគោរពតាមបទដ្ឋាន និងបច្ចេកវិទ្យាចុងក្រោយបំផុត ហើយត្រូវមាននីតិវិធីដែលចែងអំពីវិធានការដើម្បីជៀសវាងការបង្ករការខូចខាត។*

*៥.៣.៤ ឈើដែលប្រមូលផលបាន ត្រូវបានដឹកជញ្ជូនពីព្រៃ មុនពេលឈើចាប់ថយចុះគុណភាព ឬពុកផុយ។*

*៥.៣.៥ ការខ្ជះខ្ជាយឈើ និងការខូចខាតដល់ព្រៃដែលនៅសល់ ក្នុងអំឡុងពេលប្រមូលផល ការកែច្នៃ និងការទាញយកផលនៅនឹងកន្លែង ត្រូវបានកាត់បន្ថយឲ្យនៅជាអប្បរមា។*

*៥.៣.៦ វគ្គបណ្តុះបណ្តាលជាប្រចាំស្តីអំពីនីតិវិធីប្រមូលផលឈើ និងវិធីសាស្ត្រដឹកជញ្ជូន សម្រាប់បុគ្គលិក និងកម្មករនិយោជិត ត្រូវបានធ្វើឡើង។*

**លក្ខខណ្ឌវិនិច្ឆ័យ ៥.៤** ការគ្រប់គ្រងព្រៃឈើ គួរពង្រឹង និងធ្វើពិពិធភាពសេដ្ឋកិច្ចក្នុងមូលដ្ឋាន ដើម្បីជៀសវាងនូវការពឹងផ្អែកលើផលិតផលព្រៃឈើតែមួយមុខ។

<u>សូចនាករៈ</u>

*៥.៤.១ ការគ្រប់គ្រងព្រៃឈើ មានទិសដៅក្នុងការផលិតនូវផលិតផល និងសេវាពីព្រៃឈើជាច្រើនមុខ (ផលិតផលធ្វើពីឈើ និងមិនមែនឈើ រួមទាំងពូជដែលគេមិនសូវស្គាល់) រួមទាំងទេសចរណ៍ និងការកំសាន្តផងដែរ។ (មិនអនុវត្តចំពោះ SLIMF)។*

*៥.៤.២ ការប្រើប្រាស់អនុផលព្រៃឈើពីសំណាក់សហគ្រាសក្នុងមូលដ្ឋាន ត្រូវបានលើកទឹកចិត្ត ប្រសិនបើការប្រើប្រាស់នេះ មិនបង្ករឲ្យមានគ្រោះថ្នាក់ដល់វត្ថុបំណងដទៃទៀតរបស់ការគ្រប់គ្រងព្រៃឈើទេនោះ។*

**លក្ខខណ្ឌវិនិច្ឆ័យ ៥.៥** ប្រតិបត្តិការគ្រប់គ្រងព្រៃឈើ ត្រូវទទួលស្គាល់ រក្សា និងពង្រឹងតម្លៃសេវា និងធនធានព្រៃឈើ ដូចជាប្រភពទឹកលើភ្នំ និងជលផលជាដើម។

<u>សូចនាករៈ</u>

*៥.៥.១ អ្នកគ្រប់គ្រងព្រៃឈើដឹងអំពីសេវា និងធនធានព្រៃឈើជាច្រើន ដូចជាប្រភពទឹកលើភ្នំ និងជលផលជាដើម។*

*៥.៥.២ តំបន់ងាយរសើប ឬតំបន់ពិសេសៗ ដូចជាប្រភពទឹកលើភ្នំជាដើម ត្រូវបានយកមកពិចារណា នៅក្នុងការធ្វើផែនការ និងការអនុវត្តការគ្រប់គ្រងព្រៃឈើ ហើយត្រូវបានកំណត់ទុកនៅលើផែនទី។*

*៥.៥.៣ មានគោលការណ៍ណែនាំ និងវិធានការ ដើម្បីការពារ និងពង្រឹងតម្លៃ និងសេវាព្រៃឈើ ហើយគោលការណ៍ណែនាំ និងវិធានការ ទាំងនេះ ត្រូវបានយកមកអនុវត្ត។*

*៥.៥.៤ សកម្មភាពព្រៃឈើ មិនបង្កការខូចខាតដល់ជម្រករបស់ពូជត្រីដែលមានសារៈសំខាន់ផ្នែកពាណិជ្ជកម្ម ឬផ្នែកវប្បធម៌ ដែលស្ថិតនៅខាងក្នុង ឬខាងក្រោមខ្សែទឹករបស់តំបន់ការគ្រប់គ្រងព្រៃឈើ*

**លក្ខខណ្ឌវិនិច្ឆ័យ ៥.៦** អត្រានៃការប្រមូលផលពីផលិតផលព្រៃឈើ មិនត្រូវលើសពីកម្រិតដែលអាចរក្សានិរន្តរភាពបានជាអចិន្ត្រៃនោះឡើយ។

<u>សូចនាករៈ</u>

*៥.៦.១ ការធ្វើផែនការចំនួនឈើដែលអនុញ្ញាតិឲ្យកាប់បានប្រចាំឆ្នាំ (AAC) ត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងផែនការគ្រប់គ្រងព្រៃឈើ ហើយត្រូវផ្អែកលើវិធីសាស្ត្រដែលត្រូវ*

បានទទួលស្គាល់ (បោះពុម្ពផ្សាយ) និងអនុលោមទៅតាមវត្ថុបំណងនៃការគ្រប់គ្រងព្រៃដែលត្រូវបានកំណត់។

៥.៦.២ មានការផ្តល់មូលដ្ឋានហេតុផលច្បាស់លាស់ អំពីកម្រិតការប្រមូលផលដែលត្រូវបានរំពឹងទុក សម្រាប់ទិន្នផលផលិតផលព្រៃឈើប្រកបដោយនិរន្តរភាពជាអចិន្ត្រៃ ហើយត្រូវផ្អែកលើមូលដ្ឋាននោះដើម្បីធ្វើផែនការគ្រប់គ្រងព្រៃឈើ។

៥.៦.៣ បរិមាណឈើប្រមូលផល ត្រូវបានតាមដាន ចងក្រងជាឯកសារ និងយកមកពិចារណាក្នុងដំណើរការធ្វើផែនការ។

៥.៦.៤ ការប្រមូលផលអនុផលព្រៃឈើដែលត្រូវបានអនុញ្ញាតិ មិនលើសពីអត្រានៃការដាំដុះជំនួសវិញ ក្នុងអំឡុងរយៈពេលវែង។

## គោលការណ៍ទី ៦៖ ផលប៉ះពាល់ផ្នែកបរិដ្ឋាន

**ការគ្រប់គ្រងព្រៃឈើ ត្រូវអភិរក្សជីវចម្រុះ និងតម្លៃដែលពាក់ព័ន្ធរបស់វា អភិរក្សប្រភពទឹក ដី ប្រព័ន្ធអេកូឡូស៊ីដែលមានលក្ខណៈពិសេសដោយឡែក និងងាយផុយស្រួយ ព្រមទាំងទីតាំងភូមិសាស្ត្រ ហើយតាមរយៈការអភិរក្សនេះ ក៏ជួយរក្សាការបំពេញមុខងារផ្នែកអេកូឡូស៊ី និងការលូតលាស់របស់ព្រៃផងដែរ។**

**លក្ខខណ្ឌវិនិច្ឆ័យ ៦.១** ចាំបាច់ត្រូវបញ្ចប់ការវាយតម្លៃផលប៉ះពាល់ផ្នែកបរិដ្ឋាន ដែលសមស្របទៅនឹងទំហំ និងកម្លាំងរបស់ការគ្រប់គ្រងព្រៃឈើ និងលក្ខណៈពិសេសដោយឡែករបស់ធនធានដែលរងផលប៉ះពាល់ ហើយចាំបាច់ត្រូវបញ្ចូលការវាយតម្លៃនេះចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងព្រៃឈើឲ្យបានគ្រប់គ្រាន់។ ការវាយតម្លៃត្រូវរួមបញ្ចូលនូវការពិចារណានៅកម្រិតទីតាំងភូមិសាស្ត្រ ក៏ដូចជាផលប៉ះពាល់នៃបរិក្ខាកែច្នៃនៅនឹងកន្លែង។ ការវាយតម្លៃផលប៉ះពាល់ផ្នែកបរិដ្ឋាន ចាំបាច់ត្រូវធ្វើឡើងនៅមុនពេលចាប់ផ្តើមប្រតិបត្តិការដែលអាចបង្កការរំខានដល់ទីតាំងនោះ។

<u>សូចនាករ៖</u>

*៦.១.១ ប្រព័ន្ធមួយដើម្បីវាយតម្លៃផលប៉ះពាល់ផ្នែកបរិដ្ឋាន ដែលសមស្របជាមួយទំហំ និងកម្លាំងនៃការគ្រប់គ្រងព្រៃឈើ និងលក្ខណៈពិសេសដោយឡែកនៃធនធានដែលរងផលប៉ះពាល់ ត្រូវបានយកមកអនុវត្ត និងចងក្រងជាឯកសារទុក មុនពេលអាចចាប់ផ្តើមប្រតិបត្តិការណាមួយ (SLIMF៖ មុនពេលចាប់ផ្តើមប្រតិបត្តិការណាមួយ ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន ត្រូវបានកំណត់ឃើញ ហើយប្រតិបត្តិការត្រូវបានតាក់តែងឡើង ដើម្បីកាត់បន្ថយផលប៉ះពាល់ទាំងនោះ។ មិនចាំបាច់ត្រូវចងក្រងលទ្ធផលនៃការវាយតម្លៃនោះជាឯកសារទេ លើកលែងតែមានការតម្រូវដោយច្បាប់)។*

*៦.១.២ លទ្ធផលនៃការវាយតម្លៃនេះ ត្រូវបានយកមកពិចារណានៅក្នុងប្រតិបត្តិការក្រោយៗទៀត និងនៅក្នុងដំណើរការធ្វើផែនការផងដែរ ប្រសិនបើចាំបាច់។*

**លក្ខខណ្ឌវិនិច្ឆ័យ ៦.២** ចាំបាច់ត្រូវមានវិធានការការពារសុវត្ថិភាពប្រភេទពូជដែលកម្រ រងការគម្រាមកំហែង និងជិតផុតពូជ ព្រមទាំងទីជម្រករបស់ពួកគេ (ឧ. សំបុក និងកន្លែងរកចំណី)។ ចាំបាច់ត្រូវបង្កើតតំបន់អភិរក្ស និងតំបន់ការពារ ដែលសមស្របទៅតាមទំហំ និងកម្លៃ

នៃការគ្រប់គ្រងព្រៃឈើ និងលក្ខណៈពិសេសដោយឡែករបស់ធនធានដែលរងផលប៉ះពាល់។ ត្រូវមានការទប់ស្កាត់ការប្រមាញ់ ការនេសាទ ការដាក់អន្ទាក់ និងការប្រមូលផលដែលមិនសមស្រប។

<u>សូចនាករ៖</u>

*៦.២.១ ប្រភេទពូជដែលកម្រ រងការគម្រាមកំហែង និងជិតផុតពូជ ព្រមទាំងទីជម្រករបស់ពួកគេ (ឧ. សំបុក និងកន្លែងរកចំណី) ដែលមានវត្តមាន ឬទំនងជានឹងអាចមានវត្តមាន ត្រូវបានកំណត់ និងធ្វើផែនទី (**SLIMF**៖ ប្រភេទពូជដែលកម្រ និងជិតផុតពូជដែលគេបានដឹង ព្រមទាំងទីជម្រករបស់ពួកគេ ត្រូវបានការពារ)។*

*៦.២.២ នីតិវិធីដើម្បីការពារសុវត្ថិភាពពូជទាំងនេះ ត្រូវបានចងក្រងជាឯកសារ និងយកមកអនុវត្ត (**SLIMF**៖ នីតិវិធីដើម្បីការពារសុវត្ថិភាពប្រភេទពូជទាំងនេះ ត្រូវបានយកមកអនុវត្ត)។*

*៦.២.៣ តំបន់អភិរក្ស តំបន់ការពារ និងច្រកចេញចូលរបស់សត្វព្រៃ ត្រូវបានបង្កើតឡើង និងដាក់សញ្ញាសំគាល់នៅលើផែនទី សមស្របទៅតាមទំហំ និងកម្លាំងនៃការគ្រប់គ្រងព្រៃឈើ និងលក្ខណៈពិសេសដោយឡែករបស់ធនធានដែលរងផលប៉ះពាល់ (មិនអនុវត្តចំពោះប្រតិបត្តិការ **SLIMF**)។*

*៦.២.៤ ការជ្រើសរើសតំបន់អភិរក្ស និងតំបន់ការពារ មានហេតុផលគាំទ្រច្បាស់លាស់ ស្តីអំពីសក្តានុពលដើម្បីពង្រីកការចូលរួមវិភាគទានរបស់ខ្លួនជាអតិបរមា ក្នុងការរក្សា ឬពង្រឹងជីវចម្រុះ។*

*៦.២.៥ ការធ្វើបំលាស់ទីរបស់ប្រភេទពូជរុក្ខជាតិ និងសត្វសំខាន់ៗរវាងតំបន់អភិរក្ស និងតំបន់ប្រមូលផល ត្រូវបានលើកទឹកចិត្តឲ្យមាន តាមរយៈការរក្សាច្រកធ្វើដំណើរដោយកុំកាប់ព្រៃនៅតាមមាត់ទឹកដែលភ្ជាប់តំបន់ជម្រាលមួយទៅមួយ និងឆ្លងកាត់ច្រករបៀង ហើយភ្ជាប់ទៅនឹងបំណែកព្រៃដែលមិនត្រូវបានប្រមូលផល (មិនអនុវត្តចំពោះប្រតិបត្តិការ **SLIMF** ទោល)។*

*៦.២.៦ ត្រូវមានការគ្រប់គ្រងលើសកម្មភាពបរបាញ់ នេសាទ ដ្ឋល់ស្នៅ និងប្រមូលអនុផលនានា ដើម្បីធានាឲ្យបានថាសកម្មភាពទាំងនេះ មិនត្រូវបានធ្វើឡើងហួសពីកម្រិតដែលអាចធានានិរន្តរភាពឡើយ។*

*៦.២.៧ មានការទប់ស្កាត់សកម្មភាពមិនសមស្របនានា ដូចជាការបរបាញ់ ឬការដាក់អន្ទាក់ប្រភេទពូជដែលត្រូវបានការពារ។*

**លក្ខខណ្ឌវិនិច្ឆ័យ ៦.៣** ការបំពេញមុខងារ និងតម្លៃផ្នែកអេកូឡូស៊ីត្រូវបានរក្សាការពារមិនឲ្យមានការប៉ះពាល់ ពង្រឹង ឬស្តារឡើងវិញ រួមទាំង៖

ក) ការកើតសារឡើងវិញ និងការដុះកូនចៅរបស់ព្រៃឈើ

ខ) នានាភាពផ្នែកសេនេទិក ពូជ និងប្រព័ន្ធអេកូឡូស៊ី

គ) វដ្តធម្មជាតិ ដែលជះឥទ្ធិពលដល់ផលិតភាពនៃប្រព័ន្ធអេកូឡូស៊ីរបស់ព្រៃ

<u>សូចនាករ៖</u>

*៦.៣.១ ប្រព័ន្ធដាំដុះព្រៃឈើដែលត្រូវបានយកមកអនុវត្ត មានភាពសមស្របជាមួយអេកូឡូស៊ីរបស់ព្រៃ។*

*៦.៣.២ ប្រព័ន្ធដែលប្រើប្រាស់តំបន់កាប់សំអាតទំហំតូច ការកាប់រំលំដោយចោះៗ និងបង្កើតចំណាត់ថ្នាក់អាយុខុសៗគ្នា ត្រូវបានយកមកពិចារណា។*

*៦.៣.៣ ប្រសិនបើសមស្របចំពោះប្រព័ន្ធដាំដុះព្រៃឈើ ប្រតិបត្តិការព្រៃឈើ ចាំបាច់ត្រូវមានគោលដៅធ្វើយ៉ាងណាឲ្យមានភាពលាយចម្រុះគ្នាទាំងទំហំ ទ្រង់ទ្រាយ ពូជ និងកាលបរិច្ឆេទនៃការដាំ និងការកាប់រំលំនៅក្នុងខ័ណ្ឌនិមួយៗ ឲ្យស៊ីសង្វាក់គ្នាជាមួយនឹងទីតាំងភូមិសាស្ត្រនោះ។*

*៦.៣.៤ ទំហំនៃការកាប់រំលំ (ឧ. ទំហំផ្លូល) សមមាត្រទៅនឹងកម្លាំងធម្មជាតិនៃប្រភេទព្រៃ និងតំបន់សាមី (លើកលែងតែការផ្តល់ហេតុផលតាមបែបវិទ្យាសាស្ត្រដាំដុះព្រៃ ត្រូវបានផ្តល់ឲ្យ)*

*៦.៣.៥ ការកាប់រំលំបែបចោះៗ និងរបបការកាប់រំលោះ ត្រូវបានតាក់តែងឡើងដើម្បីរក្សានានាភាពផ្នែកសេនេទិច។*

*៦.៣.៦ ជីវៈចម្រុះត្រូវបានថែរក្សាជាប្រចាំ តាមរយៈការរក្សាទុកទីជម្រកនីបរិវេណជាយៗឧទាហរណ៍ដូចជា រុក្ខជាតិនៅតាមជាយមាត់ទឹក រុក្ខជាតិដុះនៅលើផ្ទាំងថ្ម កន្លែងដីល្បប់ និងគុម្ពោតរុក្ខជាតិល្អិតល្អោច។*

*៦.៣.៧ ដើមឈើងាប់ ទាំងដើមឈរ និងដើមដួល ត្រូវបានរក្សាទុកក្នុងទំហំសមស្រប។*

**លក្ខខណ្ឌវិនិច្ឆ័យ ៦.៤** គំរូតំណាងរបស់ប្រព័ន្ធអេកូឡូស៊ីដែលមានស្រាប់នៅក្នុងភូមិសាស្ត្រតំបន់នោះ បានទទួលការពារឲ្យស្ថិតនៅក្នុងស្ថានភាពធម្មជាតិរបស់ខ្លួន និងត្រូវបានកត់ត្រា

ទុកនៅក្នុងផែនទីយ៉ាងសមស្របទៅតាមទំហំ និងកម្លាំងនៃប្រតិបត្តិការ និងលក្ខណៈពិសេសដោយឡែករបស់ធនធានដែលរងផលប៉ះពាល់។

<u>សូចនាករ៖</u>

*៦.៤.១ គំរូតំណាងរបស់ប្រព័ន្ធអេកូឡូស៊ីដែលមានស្រាប់នៅក្នុងភូមិសាស្ត្រតំបន់នោះ បានទទួលការពារឲ្យស្ថិតនៅក្នុងស្ថានភាពធម្មជាតិរបស់ខ្លួន និងត្រូវបានកត់ត្រាទុកនៅក្នុងផែនទីយ៉ាងសមស្របទៅតាមទំហំ និងកម្លាំងនៃប្រតិបត្តិការ និងលក្ខណៈពិសេសដោយឡែករបស់ធនធានដែលរងផលប៉ះពាល់ (SLIMF៖ ប្រសិនបើដឹងថាមានគំរូតំណាងរបស់ប្រព័ន្ធអេកូឡូស៊ីនៅក្នុង FMU នោះ ចាំបាច់ត្រូវផ្តល់ការការពារដល់គំរូតំណាងទាំងនេះ)។*

**លក្ខខណ្ឌវិនិច្ឆ័យ ៦.៥** ចាំបាច់ត្រូវរៀបចំឲ្យមាន និងអនុវត្តនូវគោលការណ៍ណែនាំនានា ក្នុងគោលដៅដើម្បី៖ ទប់ស្កាត់ការហូរច្រោះដី កាត់បន្ថយការខូចខាតព្រៃក្នុងអំឡុងពេលប្រមូលផល ការកសាងផ្លូវ និងរាល់ការរំខានផ្នែកមេកានិចដទៃទៀត ព្រមទាំងការពារប្រភពទឹក។

<u>សូចនាករ៖</u>

*៦.៥.១ មានគោលការណ៍ណែនាំសមស្របនៅថ្នាក់មូលដ្ឋាន ស្តីពីការប្រមូលផល និងការសាងសង់ផ្លូវ ដែលឆ្លើយតបទៅតាមការតម្រូវរបស់ការអនុវត្តល្អបំផុតថ្នាក់ជាតិ ឬថ្នាក់តំបន់ (ដូចជាក្រមគំរូរបស់អង្គការ* **រដ្ឋបាលព្រៃឈើ** *O ស្តីពីការអនុវត្តល្អបំផុតក្នុងការប្រមូលផលព្រៃឈើ) សម្រាប់អ្នកគ្រប់គ្រងព្រៃឈើ និងបុគ្គលថ្នាក់លើ (SLIMF៖ ប្រតិបត្តិការគ្រប់គ្រងព្រៃឈើទាំងអស់ ត្រូវដឹងអំពីកត្តាដែលអាចនឹងបង្កការខូចខាងដល់ដី (ឧ. ដីប្រែជាហាប់ណែន ការហូរច្រោះដី) និងមានវិធីសាស្ត្រដើម្បីកាត់បន្ថយ ឬជៀសវាងកុំឲ្យមានការខូចខាងទាំងនេះ)។*

*៦.៥.២ គោលការណ៍ណែនាំទាំងឡាយដែលត្រូវបានបង្កើតឡើងស្របតាមសូចនាករ ៦.៥.១ ត្រូវបានយកមកអនុវត្តនៅក្នុងអំឡុងពេលប្រតិបត្តិការ និងការធ្វើផែនការ។*

*៦.៥.៣ តំបន់ទ្រនាប់ ត្រូវបានថែរក្សាទុកនៅតាមបណ្តោយខ្សែទឹក និងជុំវិញបរិវេណកន្លែងផ្ទុកទឹក។ តំបន់ទ្រនាប់ទាំងនេះ ត្រូវបានដាក់សញ្ញាសំគាល់នៅលើផែនទី ហើយត្រូវគោរពតាមការតម្រូវជាក់លាក់ ដែលមានចែងនៅក្នុងគោលការណ៍ណែនាំការអនុវត្ត*

*ល្អបំផុតថ្នាក់ជាតិ និងថ្នាក់តំបន់ (ដូចជាក្រមគំរូរបស់អង្គការ* **រដ្ឋបាលព្រៃឈើ** *ស្តីពីការអនុវត្តល្អបំផុតក្នុងការប្រមូលផលព្រៃឈើជាដើម)។*

*៦.៥.៤ ប្រតិបត្តិករមានការយល់ដឹង និងមានសមត្ថភាពអនុវត្តនីតិវិធីគ្រោះអាសន្ន ដើម្បីសំអាតជម្រះក្រោយពេលមានការខ្ចាយកំពប់ប្រេង និងសារធាតុគីមីផ្សេងៗ បានយ៉ាងសមស្រប។*

*៦.៥.៥ ប្រតិបត្តិការកាប់ឈើ មិនធ្វើឲ្យមានការបំពុលដល់ទឹកដែលនៅជាប់នោះ ដោយបង្កឲ្យទឹកមានកករកើនឡើងឡើយ។*

*៦.៥.៦ គោលនយោបាយ និងនីតិវិធី រួមបញ្ចូលនូវនិយាមដូចខាងក្រោម ដែលត្រូវបានយកទៅអនុវត្តៈ យ៉ាងហោចណាស់ ត្រូវមានការដាក់សញ្ញារូបវន្តដើម្បីសំគាល់ព្រំដែនតំបន់ការពារជាបណ្តោះអាសន្ន មុនពេលអាចចាប់ផ្តើមប្រតិបត្តិការព្រៃឈើណាមួយនៅលើដីជាប់នោះ។*

*- គ្រឿងចក្រសម្រាប់ប្រមូលផល មិនត្រូវចូលទៅក្នុងដែនទឹកជាដាច់ខាត លើកលែងតែនៅតាមដែនទឹកដែលត្រូវបានកំណត់ និងដែនទឹកឆ្លងកាត់ដែលត្រូវបានកំណត់។*

*- មិនត្រូវរុញមែក និងចុងឈើទម្លាក់ចូលទៅក្នុងទឹកឡើយ។*

*- ការទាញយកផល ត្រូវបានបញ្ឈប់នៅពេលដីសើមជោគជាំ។*

*- ទ្រនាប់មែកឈើត្រូវបានយកមកប្រើតាមការគួរ។*

*៦.៥.៧ រាល់ប្រតិបត្តិការប្រមូលផលឈើទាំងអស់ ត្រូវបានអនុវត្តឡើងយោងទៅតាមការណែនាំនៅក្នុងផែនការ។*

*៦.៥.៨ កម្មករនិយោជិតទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់អំពីវិធីប្រមូលផល និងទាញយកផល។ សម្រាប់ FME ទ្រង់ទ្រាយធំ (> ១០.០០០ ហ.ត) ត្រូវមានកម្មវិធីបណ្តុះបណ្តាល និងកំណត់ត្រាការបណ្តុះបណ្តាលជាលាយលក្ខណ៍អក្សរ។*

**លក្ខខណ្ឌវិនិច្ឆ័យ** **៦.៦** ប្រព័ន្ធគ្រប់គ្រង ចាំបាច់ត្រូវលើកកំពស់ការបង្កើតឲ្យមាន និងការប្រើប្រាស់វិធីបែបគ្មានជាតិគីមី ដែលអំណោយផលដល់បរិដ្ឋាន ក្នុងការគ្រប់គ្រងលើសត្វចង្រៃ និងត្រូវពុះពារធ្វើយ៉ាងណា ជៀសវាងពីការប្រើប្រាស់វិធីកំចាត់សត្វចង្រៃ ដោយប្រើសារធាតុគីមី។ ត្រូវហាមឃាត់ថ្នាំកំចាត់សត្វចង្រៃប្រភេទ ១A និង ១B របស់អង្គការសុខភាពពិភពលោក និងថ្នាំប្រភេទក្លរីណាតអ៊ីដ្រូកាបូន ថ្នាំកំចាត់សត្វចង្រៃដែលស្ថិតនៅជាអចិន្ត្រៃ ដែលពុល ឬដែលកាកសំណល់ថ្នាំបន្តមានសកម្មភាពផ្នែកជីវសាស្ត្រ និងសេសសល់នៅក្នុង

សង្វាក់អាហារ ហួសពីចេតនាប្រើប្រាស់របស់ថ្នាំ ក៏ដូចជាថ្នាំកំចាត់សត្វចង្រៃទាំងឡាយណា ដែលត្រូវបានហាមឃាត់ដោយកិច្ចព្រមព្រៀងជាអន្តរជាតិ។ ប្រសិនបើមានការប្រើប្រាស់សារធាតុគីមី ចាំបាច់ត្រូវផ្តល់ឧបករណ៍ និងការបណ្តុះបណ្តាលសមស្រប ដើម្បីកាត់បន្ថយហានិភ័យផ្នែកសុខភាព និងបរិដ្ឋាន។

<u>សូចនាករ៖</u>

*៦.៦.១. មានការចងក្រងជាឯកសារលោយលក្ខណ៍អក្សរអំពីយុទ្ធសាស្ត្រកំចាត់ជំងឺ និងរុក្ខជាតិចង្រៃ។*

*៦.៦.២ សារធាតុគីមី ត្រូវបានប្រើប្រាស់តែក្នុងករណីចាំបាច់បំផុត ដើម្បីសម្រេចបានគោលដៅនៃការគ្រប់គ្រងដែលត្រូវបានកំណត់ទុក។ សារធាតុគីមីសំយោគ ត្រូវបានប្រើប្រាស់តែក្នុងករណីមិនមានជម្រើសដោយមិនប្រើសារធាតុគីមីណាផ្សេងទៀត ដែលមិនតម្រូវឲ្យមានការចំណាយហួសប្រមាណ។*

*៦.៦.៣ មានបញ្ជីបច្ចុប្បន្នភាពឈ្មោះថ្នាំកំចាត់សត្វចង្រៃ ដែលត្រូវបានប្រើប្រាស់នៅក្នុងអង្គភាព ដោយមានកត់ត្រាទុកនូវម៉ាកយីហោ និងសារធាតុផ្សំសកម្មរបស់ថ្នាំ។ ត្រូវកត់ត្រាទុកផងដែរនូវព័ត៌មានអំពីការប្រើប្រាស់ដែលត្រូវបានអនុញ្ញាតិឲ្យប្រើ វិធីប្រើ និងបរិមាណថ្នាំដែលត្រូវប្រើ ប្រសិនបើមិនមានការបញ្ជាក់ទាំងអស់នេះ នៅលើសំបកថ្នាំទេនោះ។*

*៦.៦.៤ មិនត្រូវប្រើប្រាស់ថ្នាំកំចាត់សត្វចង្រៃដែលត្រូវបានហាមឃាត់ជាដាច់ខាត លើកលែងតែក្នុងករណីបានទទួលការនិរាករណ៍ថ្នាំកំចាត់សត្វចង្រៃពីលេខាធិការដ្ឋាន FSC ឬមានការលើកលែងក្នុងករណីអាសន្នដោយមានការអនុញ្ញាតិពី GFA មុនពេលប្រើប្រាស់។*

*៦.៦.៥ ការប្រើប្រាស់សារធាតុគីមី (ថ្នាំកំចាត់ដើមឈើ ថ្នាំកំចាត់សត្វល្អិត ថ្នាំកំចាត់ស្មៅ។ល។) ត្រូវស្ថិតក្រោមការត្រួតពិនិត្យយ៉ាងតឹងរ៉ឹង។*

*៦.៦.៦ ប្រសិនបើមានការប្រើប្រាស់សារធាតុគីមី ត្រូវមានឧបករណ៍សមស្របសម្រាប់ប្រើ ហើយបុគ្គលិកត្រូវទទួលបានការបណ្តុះបណ្តាលយ៉ាងសមស្រប។*

*៦.៦.៧ ការប្រើប្រាស់សារធាតុគីមីក្នុងចម្ងាយ ១០ ម ពីប្រភពទឹក និង ៣០ ម ពីអាងស្តុកទឹក និងបឹង ត្រូវបានហាមឃាត់។*

*៦.៦.៨ ការប្រើប្រាស់សារធាតុគីមីនៅពេលហៀបមានភ្លៀងខ្លាំង ក្នុងពេលអាកាសធាតុសើម នៅលើដីដែលគ្របដណ្ដប់ដោយព្រិល ឬនៅលើដីស្ងួតបែកក្រហែងដោយគ្រោះរាំងស្ងួត ត្រូវបានហាមឃាត់។*

*៦.៦.៩ ការរក្សាទុក និងការចាត់ចែងសារធាតុគីមី ត្រូវគោរពតាមគោលការណ៍ណែនាំចុងក្រោយបំផុត ស្ដីពីសុវត្ថិភាព និងសុខភាព។*

**លក្ខខណ្ឌវិនិច្ឆ័យ ៦.៧** ការចោលសារធាតុគីមី ភាជន៍សម្រាប់ផ្ទុក កាកសំណល់អសរីរាង្គពាវ និងរឹង រួមទាំងឥន្ធនៈ និងប្រេងជាដើម ត្រូវធ្វើឡើងក្នុងលក្ខណៈដែលសមស្របសម្រាប់បរិដ្ឋាន នៅក្រៅទីតាំងប្រតិបត្តិការ។

<u>សូចនាករៈ</u>

*៦.៧.១ មានគោលការណ៍ណែនាំដែលពិពណ៌នាអំពីការប្រើប្រាស់ និងការចោលសារធាតុគីមី ភាជន៍សម្រាប់ផ្ទុក កាកសំណល់អសរីរាង្គពាវ និងរឹង ហើយគោលការណ៍ណែនាំនេះត្រូវបានយកមកអនុវត្ត។*

*៦.៧.២ មានបុគ្គលិកម្នាក់ទទួលខុសត្រូវលើការចោលកាកសំណល់ ដែលសមស្របសម្រាប់បរិដ្ឋាន។*

*៦.៧.៣ មានការផ្ដល់ទំនោរចិត្តទៅលើការប្រើប្រាស់ប្រេងរំអិល និងឥន្ធនៈដែលអំណោយផលដល់បរិដ្ឋាន។*

*៦.៧.៤ ដី និងទឹក ត្រូវបានការពារពីការបំពុល។*

*៦.៧.៥ ការចោលកាលសំណល់ចេញពីឧបករណ៍ ឬសម្ភារៈផ្គត់ផ្គង់ ត្រូវបានធ្វើឡើងយ៉ាងសមស្រប។*

**លក្ខខណ្ឌវិនិច្ឆ័យ ៦.៨** ការប្រើប្រាស់សារធាតុគ្រប់គ្រងជីវសាស្ត្រ ត្រូវបានចងក្រងទុកជាឯកសារ កាត់បន្ថយ តាមដាន និងត្រួតពិនិត្យយ៉ាងតឹងរ៉ឹង ស្របទៅតាមច្បាប់ជាតិ និងពិធីការវិទ្យាសាស្ត្រ ដែលត្រូវបានទទួលយកជាអន្តរជាតិ។ ការប្រើប្រាស់សារធាតុកែប្រែសេនេទិចត្រូវបានហាមឃាត់។

<u>សូចនាករៈ</u>

*៦.៨.១ មាននីតិវិធី និងការអនុវត្ត ដើម្បីចងក្រងទុកជាឯកសារ និងតាមដានលើរាល់ការប្រើប្រាស់សារធាតុគ្រប់គ្រងជីវសាស្ត្រទាំងអស់។*

*៦.៨.២ ការប្រើប្រាស់សារធាតុគ្រប់គ្រងជីវសាស្ត្រត្រូវបានជៀសវាង ឬកាត់បន្ថយ តាមរយៈការប្រើប្រាស់វិធីគ្រប់គ្រងជាជម្រើសដែលមានផ្សេងទៀត ដែលមិនបង្កឲ្យមានការចំណាយហួសប្រមាណ។*

*៦.៨.៣ មិនមានការប្រើប្រាស់សារធាតុកែប្រែសេនេទិច រួមទាំងសម្ភារៈសម្រាប់ដាំដុះ និងសារធាតុគ្រប់គ្រងជីវសាស្ត្រ។*

**លក្ខខណ្ឌវិនិច្ឆ័យ ៦.៩** ការប្រើប្រាស់ពូជក្រៅស្រុក ត្រូវស្ថិតក្រោមការត្រួតពិនិត្យដោយប្រុងប្រយ័ត្ន និងត្រូវមានការតាមដានយ៉ាងសកម្ម ដើម្បីជៀសវាងកុំឲ្យមានផលប៉ះពាល់ផ្នែកអេកូឡូស៊ីជាអវិជ្ជមាន។

<u>សូចនាករ៖</u>

*៦.៩.១ គ្រប់ករណីនៃការប្រើប្រាស់ពូជក្រៅស្រុក សុទ្ធតែមានការផ្តល់ហេតុផលគាំទ្រ។*

*៦.៩.២ ពូជក្រៅស្រុក ដែលត្រូវបានប្រើប្រាស់ជាលក្ខណៈពាណិជ្ជកម្ម មិនគួរជះឥទ្ធិពលអវិជ្ជមានលើបរិដ្ឋាន ឬមានផលប៉ះពាល់ជាអវិជ្ជមានលើទីតាំងជុំវិញ និងសមាសធាតុពូជធម្មជាតិឡើយ។*

*៦.៩.៣ ការប្រើប្រាស់ពូជក្រៅស្រុក ត្រូវបានតាមដានយ៉ាងសកម្ម ដើម្បីជៀសវាងកុំឲ្យមានផលប៉ះពាល់ផ្នែកអេកូឡូស៊ីជាអវិជ្ជមាន ដូចជាការដុះលាស់ឡើងវិញ ដែលមិនគួរជាទីចង់បានជាដើម។*

**លក្ខខណ្ឌវិនិច្ឆ័យ ៦.១០** មិនត្រូវឲ្យកើតមានការប្រែក្លាយព្រៃធម្មជាតិ ទៅជាដីចម្ការ ឬទៅជាបំរើបំរាស់ដីមិនមែនជាព្រៃ នៅក្នុងតំបន់ក្រោមការគ្រប់គ្រងព្រៃឈើឡើយ លើកលែងតែក្នុងករណីដែលការប្រែក្លាយនោះ៖

ក) ពាក់ព័ន្ធបំណែកតូចបំផុតនៃផ្ទៃដីក្រោមការគ្រប់គ្រងព្រៃឈើ និង

ខ) មិនកើតឡើងនៅក្នុងតំបន់ព្រៃដែលមានតម្លៃផ្នែកការអភិរក្សខ្ពស់ និង

គ) នឹងជួយជម្រុញដល់អត្ថប្រយោជន៍ផ្នែកអភិរក្សយ៉ាងជាក់ច្បាស់ គួរឲ្យកត់សំគាល់ បន្ថែមមានសន្តិសុខ រយៈពេលវែង នៅក្នុងការគ្រប់គ្រងព្រៃទាំងមូល។

<u>សូចនាករ៖</u>

*៦.១០.១ មិនមានការប្រែក្លាយព្រៃឈើ ទៅជាដីចម្ការ ឬបំរើបំរាស់ដីមិនមែនជាដី លើកលែងតែក្នុងករណីដែលការប្រែក្លាយនោះ៖*

ក) ពាក់ព័ន្ធបំណែកតូចបំផុតនៃផ្ទៃដីក្រោមការគ្រប់គ្រងព្រៃឈើ និង

ខ) មិនកើតឡើងនៅក្នុងតំបន់ព្រៃដែលមានតម្លៃផ្នែកការអភិរក្សខ្ពស់ និង

គ) នឹងជួយជម្រុញដល់អត្ថប្រយោជន៍ផ្នែកអភិរក្សយ៉ាងជាក់ច្បាស់ គួរឲ្យកត់សំគាល់ បន្ថែម មានសន្តិសុខ រយៈពេលវែង នៅក្នុងការគ្រប់គ្រងព្រៃទាំងមូល។

## គោលការណ៍ទី ៧៖ ការប្រើប្រាស់ដី និងផែនការគ្រប់គ្រង

ផែនការគ្រប់គ្រងមួយដែលសមស្របទៅនឹងទំហំ និងកម្លាំងរបស់ប្រតិបត្តិការត្រូវបានសរសេរឡើង យកមកអនុវត្ត និងធ្វើបច្ចុប្បន្នភាព។ វត្ថុបំណងរយៈពេលវែងរបស់ការគ្រប់គ្រង និងមធ្យោបាយដើម្បីសម្រេចបានវត្ថុបំណងទាំងនោះ ត្រូវបានចែងយ៉ាងច្បាស់។ ផែនការគ្រប់គ្រងព្រៃឈើ ត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងការធ្វើផែនការប្រើប្រាស់ដីទូទៅ ហើយត្រូវផ្អែកនៅលើសន្និធិជារយៈៗ។

**លក្ខខណ្ឌវិនិច្ឆ័យ ៧.១** ផែនការគ្រប់គ្រង និងឯកសារគាំទ្រ គួរផ្តល់៖

ក) វត្ថុបំណងនៃការគ្រប់គ្រង។

ខ) ការពិពណ៌នាអំពីធនធានព្រៃឈើដែលនឹងត្រូវគ្រប់គ្រង ដែនកំណត់ផ្នែកបរិដ្ឋាន ការប្រើប្រាស់ដី និងស្ថានភាពផ្នែកកម្មសិទ្ធិ ល័ក្ខខ័ណ្ឌសង្គមសេដ្ឋកិច្ច និងលក្ខណៈសម្បត្តិនៃដីនៅជាប់នោះ។

គ) ការពិពណ៌នាអំពីវិទ្យាសាស្ត្រនៃការដាំដុះព្រៃឈើ និង/ឬប្រព័ន្ធគ្រប់គ្រងដទៃទៀត ដោយផ្អែកលើអេកូឡូស៊ីរបស់ព្រៃសាមី និងព័ត៌មានដែលប្រមូលបានតាមរយៈសន្និធិធនធាន។

ឃ) ហេតុផល សម្រាប់អត្រានៃការប្រមូលផលប្រចាំឆ្នាំ និងការជ្រើសរើសពូជ។

ង) បទបញ្ញត្តិអំពីការតាមដានការលូតលាស់ និងថាមពលរបស់ព្រៃ។

ច) ការការពារសុវត្ថិភាពបរិដ្ឋាន ដោយផ្អែកលើការវាយតម្លៃផ្នែកបរិដ្ឋាន។

ឆ) ផែនការដើម្បីកំណត់ និងការពារប្រភេទពូជកម្រ រងការគម្រាមកំហែង និងជិតផុតពូជ។

ជ) ផែនទីពិពណ៌នាធនធានព្រៃឈើ ដោយរួមទាំងទាំងតំបន់ការពារ សកម្មភាពការគ្រប់គ្រងដែលបានគ្រោងទុក និងកម្មសិទ្ធិដីធ្លី។

ឈ) ការពិពណ៌នា និងការផ្តល់ហេតុផលបញ្ជាក់អំពីបច្ចេកទេសប្រមូលផល និងឧបករណ៍ដែលនឹងត្រូវប្រើប្រាស់។

<u>សូចនាករ៖</u>

*៧.១.១ ផែនការការគ្រប់គ្រង ផ្តល់ផែនការស្តីពីវត្ថុបំណងនៃការគ្រប់គ្រង។*

*៧.១.២ ផែនការការគ្រប់គ្រង ផ្តល់ការពិពណ៌នាអំពីធនធានព្រៃឈើ ដែលនឹងត្រូវស្ថិតក្រោមការគ្រប់គ្រង ដែនកំណត់ផ្នែកបរិដ្ឋាន ការប្រើប្រាស់ដី និងស្ថានភាពកម្មសិទ្ធិដីធ្លី ល័ក្ខខ័ណ្ឌផ្នែកសង្គមសេដ្ឋកិច្ច និងលក្ខណៈសម្បត្តិរបស់ដីដែលនៅជាប់នោះ។*

*៧.១.៣ ផែនការការគ្រប់គ្រង ផ្តល់ការពិពណ៌នាអំពីវិធីសាស្ត្រការដាំដុះព្រៃ និង/ឬប្រព័ន្ធគ្រប់គ្រងដទៃទៀត ដោយផ្អែកលើអេកូឡូស៊ីរបស់ព្រៃសាមី និងព័ត៌មានប្រមូលបានតាមរយៈសន្និធិធនធាន។*

*៧.១.៤ ផែនការការគ្រប់គ្រង ផ្តល់ហេតុផលសម្រាប់អត្រានៃការប្រមូលផលប្រចាំឆ្នាំ និងការជ្រើសរើសពូជ។*

*៧.១.៥ ផែនការការគ្រប់គ្រង ផ្តល់បទបញ្ញត្តិអំពីការតាមដានការលូតលាស់ និងថាមពលរបស់ព្រៃ។*

*៧.១.៦ ផែនការការគ្រប់គ្រង ផ្តល់ការការពារសុវត្ថិភាពបរិស្ថាន ដោយផ្អែកលើការវាយតម្លៃផ្នែកបរិស្ថាន។*

*៧.១.៧ ធ្វើផែនការសម្រាប់ការកំណត់អត្តសញ្ញាណ និងការការពារប្រភេទពូជកម្រ រងការគម្រាមកំហែង និងជិតផុតពូជ។*

*៧.១.៨ ធ្វើផែនទីពិពណ៌នាធនធានព្រៃឈើ ដោយរួមទាំងទាំងតំបន់ការពារ សកម្មភាពការគ្រប់គ្រងដែលបានគ្រោងទុក និងកម្មសិទ្ធិដីធ្លី។*

*៧.១.៩ ការពិពណ៌នា និងការផ្តល់ហេតុផលបញ្ជាក់អំពីបច្ចេកទេសប្រមូលផល និងឧបករណ៍ដែលនឹងត្រូវប្រើប្រាស់។*

**លក្ខខណ្ឌវិនិច្ឆ័យ** ៧.២ ត្រូវកែសម្រួលផែនការការគ្រប់គ្រងជារយៈៗ ដើម្បីអាចដាក់បញ្ចូលនូវលទ្ធផលនៃការតាមដាន ឬព័ត៌មានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេសថ្មីៗ ក៏ដូចជាដើម្បីឆ្លើយតបនឹងការផ្លាស់ប្តូរផ្នែកបរិស្ថាន សង្គម និងសេដ្ឋកិច្ច។

<u>សូចនាករ៖</u>

*៧.២.១ មាននីតិវិធីសម្រាប់ការកែសម្រួល និងការធ្វើបច្ចុប្បន្នភាពជាប្រចាំទៅលើផែនការការគ្រប់គ្រង។*

*៧.២.២ នៅក្នុងការកែសម្រួលផែនការការគ្រប់គ្រង ទស្សនៈដែលពាក់ព័ន្ធរបស់វិទ្យាស្ថានស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាលផ្នែកបរិស្ថាន និងសង្គម ត្រូវបានយកមកពិចារណា។*

*៧.២.៣ មានភស្តុតាងបង្ហាញថាការពិចារណាលើបំលាស់ប្តូរផ្នែកបរិស្ថាន សង្គម និងសេដ្ឋកិច្ច ត្រូវបានដាក់បញ្ចូលទៅក្នុងការកែសម្រួលនៃផែនការការគ្រប់គ្រង។*

*៧.២.៤ មានវិធីសាស្ត្រដើម្បីវាយតម្លៃលើការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេសថ្មីៗដើម្បីដាក់បញ្ចូលទៅក្នុងផែនការការគ្រប់គ្រងដែលត្រូវបានកែសម្រួលជាថ្មីនោះ។*

**លក្ខខណ្ឌវិនិច្ឆ័យ ៧.៣** កម្មករនិយោជិតនៅក្នុងព្រៃឈើ ត្រូវទទួលបានការបណ្តុះបណ្តាល និងការណែនាំឲ្យបានគ្រប់គ្រាន់ ដើម្បីធានានូវការអនុវត្តផែនការការគ្រប់គ្រងបានយ៉ាងសមស្រប។

<u>សូចនាករ៖</u>

*៧.៣.១ ការបណ្តុះបណ្តាលបន្ថែមពិសេសស្តីពីទិដ្ឋភាពផ្នែកអេកូឡូស៊ី និងផ្នែកបច្ចេកទេសរបស់ការគ្រប់គ្រងព្រៃឈើ ត្រូវបានផ្តល់ឲ្យ និងគាំទ្រ។*

*៧.៣.២ កម្មករនិយោជិតនៅក្នុងព្រៃឈើត្រូវបានណែនាំឲ្យដឹងច្បាស់អំពីភារកិច្ចរបស់ខ្លួន។*

*៧.៣.៣ កម្មករនិយោជិតនៅក្នុងព្រៃឈើបានដឹងអំពីវត្ថុបំណងរបស់ការគ្រប់គ្រងព្រៃឈើ។*

*៧.៣.៤ ការងាររបស់កម្មករនិយោជិតព្រៃឈើ បានទទួលការត្រួតពិនិត្យពីអ្នកគ្រប់គ្រងព្រៃឈើក្នុងចន្លោះរយៈពេលសមស្រប។*

**លក្ខខណ្ឌវិនិច្ឆ័យ ៧.៤** ស្របពេលដែលមានការគោរពលក្ខណៈសម្ងាត់នៃព័ត៌មាន អ្នកគ្រប់គ្រងព្រៃឈើត្រូវដាក់ឲ្យមានជាសាធារណៈ នូវសេចក្តីសង្ខេបធាតុចំបងៗរបស់ផែនការការគ្រប់គ្រងព្រៃឈើ រួមទាំងបណ្តាធាតុដែលមានចែងនៅក្នុងលក្ខខណ្ឌវិនិច្ឆ័យ ៧.១។

<u>សូចនាករ៖</u>

*៧.៤.១ សង្ខេបជាប្រចាំនូវធាតុចំបងៗរបស់ផែនការការគ្រប់គ្រង រួមទាំងបណ្តាធាតុដែលមានចែងនៅក្នុងលក្ខខណ្ឌវិនិច្ឆ័យ ៧.១ ដើម្បីដាក់ឲ្យមានជាសាធារណៈ។ សហគ្រាសទ្រង់ទ្រាយធំ (> ១០.០០០ ហ.ត) ជម្រាបជូនដល់សាធារណជនយ៉ាងសកម្ម ក្នុងអំឡុងកិច្ចប្រជុំប្រចាំជាមួយភាគីពាក់ព័ន្ធ (សូមមើលចំណុច ៤.៤.៤) (**SLIMF**៖ នៅពេលមានការស្នើសុំ FME ត្រូវដាក់ផ្នែកដែលពាក់ព័ន្ធនៃផែនការការគ្រប់គ្រង ជូនភាគីពាក់ព័ន្ធដែលរងផលប៉ះពាល់ដោយផ្ទាល់ពីសកម្មភាពការគ្រប់គ្រងព្រៃឈើ)។*

**គោលការណ៍ទី ៨៖ ការតាមដាន និងវាយតម្លៃ**

**ការតាមដានដែលសមស្របទៅនឹងទំហំ និងកម្លាំងរបស់ប្រតិបត្តិការត្រូវបានធ្វើឡើង ដើម្បីវាយតម្លៃទៅលើល័ក្ខខ័ណ្ឌរបស់ព្រៃ ទិន្នផលនៃផលិតផលព្រៃឈើ សង្វាក់នៃការមើលខុសត្រូវ សកម្មភាពការគ្រប់គ្រង និងផលប៉ះពាល់ផ្នែកសង្គម និងបរិដ្ឋានរបស់កម្មភាពទាំងនោះ។**

**លក្ខខណ្ឌវិនិច្ឆ័យ** ៨.១ ភាពញឹកញាប់ និងកម្លាំងនៃការតាមដាន គួរត្រូវបានកំណត់ដោយទំហំ និងកម្លាំងនៃប្រតិបត្តិការគ្រប់គ្រងព្រៃឈើ ក៏ដូចជាទៅលើកម្រិតនៃភាពស្មុគ្រស្មាញ និងភាពផុយស្រួយនៃបរិដ្ឋានដែលរងផលប៉ះពាល់។ នីតិវិធីនៃការតាមដានគួរមានលក្ខណៈស៊ីសង្វាក់គ្នា ហើយអាចចម្លងគ្នាពីពេលមួយទៅពេលមួយទៀត ដើម្បីអនុញ្ញាតិឲ្យអាចប្រៀបធៀបលទ្ធផល និងការវាយតម្លៃទៅលើការផ្លាស់ប្តូរ។

<u>សូចនាករ៖</u>

*៨.១.១ សកម្មភាពទាំងអស់ដែលទាមទារឲ្យមានការតាមដាន ត្រូវបានកំណត់ឃើញ។*

*៨.១.២ មានផែនការ និងការតាក់តែងមួយ ដែលផ្អែកលើនីតិវិធីដែលមានលក្ខណៈស៊ីសង្វាក់គ្នា និងអាចចម្លងគ្នាបាន ហើយនីតិវិធី និងការតាក់តែងនេះ ត្រូវបានយកមកអនុវត្ត ដើម្បីធ្វើការតាមដាន និងការរាយការណ៍ជារយៈៗ។*

*៨.១.៣ ភាពញឹកញាប់ និងការចំណាយសម្រាប់ការតាមដាន គឺមានភាពសមស្របទៅតាមទំហំ និងកម្លាំងនៃប្រតិបត្តិការគ្រប់គ្រងព្រៃឈើ ក៏ដូចជាទៅលើកម្រិតនៃភាពស្មុគ្រស្មាញ និងភាពផុយស្រួយនៃបរិដ្ឋានដែលរងផលប៉ះពាល់។*

**លក្ខខណ្ឌវិនិច្ឆ័យ** ៨.២ ការគ្រប់គ្រងព្រៃឈើគួររួមបញ្ចូលនូវការស្រាវជ្រាវ និងការប្រមូលទិន្នន័យដែលចាំបាច់សម្រាប់តាមដាន យ៉ាងហោចណាស់ ទៅលើសូចនាករដូចខាងក្រោម៖

ក) ទិន្នផលនៃផលិតផលព្រៃឈើទាំងអស់ដែលប្រមូលផលបាន។

ខ) អត្រាការលូតលាស់ ការលាស់ដុះឡើងវិញ និងល័ក្ខខ័ណ្ឌរបស់ព្រៃឈើ។

គ) សមាសធាតុ និងការផ្លាស់ប្តូរដែលត្រូវបានសង្កេតឃើញ ខាងផ្នែករុក្ខសាស្ត្រ និងសត្វមានជីវិត។

ឃ) ផលប៉ះពាល់ផ្នែកបរិដ្ឋាន និងសង្គម ដែលកើតចេញពីការប្រមូលផល និងប្រតិបត្តិការដទៃទៀត។

ង) ការចំណាយ ផលិតភាព និងប្រសិទ្ធិភាពនៃការគ្រប់គ្រងព្រៃឈើ។

<u>សូចនាករ៖</u>

*៨.២.១ ទិន្នផលនៃផលិតផលព្រៃឈើទាំងអស់ដែលប្រមូលផលបានត្រូវបានកត់ត្រាទុក។*

*៨.២.២ ក្នុងករណីមិនដឹងអំពីគំរូបទដ្ឋានការលូតលាស់ ឬព័ត៌មានអំពីការដុះលាស់ឡើងវិញរបស់ពូជបែបពាណិជ្ជកម្មទេនោះ ត្រូវមានកម្មវិធីមួយ ដើម្បីប្រមូលព័ត៌មានលំអិតសម្រាប់ការគ្រប់គ្រងនាពេលអនាគត។*

*៨.២.៣ ល័ក្ខខ័ណ្ឌរបស់ព្រៃ (វត្តមាននៃសត្វល្អិតចង្រៃ ជំងឺ ភស្តុតាងដែលបង្ហាញពីការហោប់ណែនដី ការហូរច្រោះដី។ល។) ត្រូវបានតាមដាន និងពិនិត្យឡើងវិញជាប្រចាំ។*

*៨.២.៤ តំបន់អភិរក្ស (សូមមើលចំណុច ៦.២) ត្រូវបានតាមដានជាប្រចាំ ដើម្បីធានាឲ្យបានថាមិនមានភស្តុតាងបង្ហាញអំពីការរេចរិល ឬការរំខាន។*

*៨.២.៥ សមាសធាតុ និងបំលាស់ប្តូរផ្នែករុក្ខសាស្ត្រ និងសត្វមានជីវិត និងប្រសិទ្ធិភាពនៃសកម្មភាពអភិរក្ស ជាពិសេសគឺសម្រាប់ប្រភេទពូជកម្រ ពូជរងការជម្រាមកំហែង និងពូជដែលជិតផុតពូជ ត្រូវបានតាមដាន។*

*៨.២.៦ សូចនាករស្តីពីផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម រួមទាំងផ្នែកសុខភាព និងសុវត្ថិភាពដែលបង្ករឡើងដោយប្រតិបត្តិការព្រៃឈើ ត្រូវបានកំណត់ឃើញ និងប្រមូលទិន្នន័យសម្រាប់ការតាមដាន។*

*៨.២.៧ ការបំពេញការងាររបស់អ្នកជាប់កិច្ចសន្យា រួមទាំងការគោរពតាមការតម្រូវជាក់លាក់នៅក្នុងកិច្ចសន្យាផងដែរ ត្រូវបានតាមដាន។*

*៨.២.៨ ការចំណាយទាំងអស់របស់សកម្មភាពការគ្រប់គ្រងព្រៃឈើ ត្រូវបានកត់ត្រាទុក និងវាយតម្លៃ ដើម្បីវិនិច្ឆ័យអំពីផលិតភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងព្រៃឈើ។*

**លក្ខខណ្ឌវិនិច្ឆ័យ ៨.៣** អ្នកគ្រប់គ្រងព្រៃឈើត្រូវផ្តល់ឯកសារ ដើម្បីជួយជម្រុញដល់ស្ថាប័នតាមដាន និងចេញវិញ្ញាបនប័ត្រ ដើម្បីស្វែងយល់ពីផលិតផលព្រៃឈើនីមួយៗ ចាប់តាំងពីប្រភពដើមរបស់វាមក ហើយដំណើរការនេះគេហៅថា "សង្វាក់នៃការមើលខុសត្រូវ"។

<u>សូចនាករ៖</u>

*៨.៣.១ ផលិតផលព្រៃឈើដែលនឹងត្រូវលក់ជាផលិតផលមានវិញ្ញាបនប័ត្រ អាចត្រូវបានកំណត់អត្តសញ្ញាណបានភ្លាមថា ជាផលិតផលមានប្រភពដើមមកពីព្រៃដែលទទួលបានការវាយតម្លៃ។ ចំណុចនេះ អាចសម្រេចបានតាមរយៈការដាក់សញ្ញាសំគាល់*

*រូបវន្តលើឈើ ប្រព័ន្ធគ្រប់គ្រងក្រដាស់ស្នាម កំណត់ត្រាផលិតកម្មប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍ ឬការរួមបញ្ចូលគ្នានូវបច្ចេកទេសទាំងអស់នេះ និងបច្ចេកទេសប្រហាក់ប្រហែល។*

*៨.៣.២ ផលិតផលទាំងអស់ ដែលប្រតិបត្តិការព្រៃឈើលក់ចេញ ជាផលិតផលមានវិញ្ញាបនប័ត្រ ត្រូវបានកត់ត្រា៖ ប្រភេទផលិតផល ("FSC ១០០%" លើកលែងតែមានការណែនាំឲ្យប្រើស័ព្ទថ្មីនៅក្រុងបទដ្ឋាន FSC COC) គុណភាព ឬបរិមាណ កាលបរិច្ឆេទ លេខអាជ្ញាប័ណ្ណ FSC (GFA-FM/COC- xxxxxx) អតិថិជន និងព័ត៌មានស្តីពីច្រកទ្វារព្រៃ។ ព័ត៌មានទាំងនេះ នឹងត្រូវគាំទ្រដោយភស្តុតាងនៅក្នុងប្រព័ន្ធរក្សាកំណត់ត្រា (វិក្ក័យប័ត្រ ប័ណ្ណផ្ទុកទំនិញ ការបញ្ជាទិញ។ល។)។*

*៨.៣.៣ រាល់ការប្រើប្រាស់ផ្លាកសញ្ញារបស់ FSC គឺត្រូវស្របទៅតាមបទដ្ឋានផ្លាកសញ្ញារបស់ FSC (FSC-STD-៥០-០០១ និងគោលនយោបាយ FSC ដែលពាក់ព័ន្ធ/ជំនួស) ហើយត្រូវបានអនុម័តដោយ GFA ឬស្ថាប័នមានសមត្ថកិច្ចដទៃទៀត មុនការអនុវត្ត។*

**លក្ខខណ្ឌវិនិច្ឆ័យ** ៨.៤ លទ្ធផលនៃការតាមដាន ត្រូវបានរួមបញ្ចូលទៅក្នុងការអនុវត្ត និងការកែសម្រួលផែនការការគ្រប់គ្រងឡើងវិញ។

<u>សូចនាករ៖</u>

*៨.៤.១ មានប្រព័ន្ធមួយ ដែលបង្ហាញអំពីរបៀបដាក់បញ្ចូលលទ្ធផលការតាមដាន ទៅក្នុងការអនុវត្តការកែសម្រួលឡើងវិញលើផែនការការគ្រប់គ្រង (**SLIMF៖** សំដៅទៅលើសូចនាករ ៧.២.៣ និង ៧.២.៤)។*

*៨.៤.២ ការផ្លាស់ប្តូរទៅលើការគ្រប់គ្រង ដែលត្រូវបានស្នើឡើងក្នុងអំឡុងពេលការវិភាគលើលទ្ធផលការតាមដាន ត្រូវបានយកមកអនុវត្ត (**SLIMF៖** សំដៅលើសូចនាករ ៧.២.៣ និង ៧.២.៤)។*

**លក្ខខណ្ឌវិនិច្ឆ័យ ៨.៥** ស្របពេលដែលមានការគោរពលក្ខណៈសម្ងាត់នៃព័ត៌មាន អ្នកគ្រប់គ្រងព្រៃឈើត្រូវដាក់ឲ្យមានជាសាធារណៈ នូវសេចក្តីសង្ខេបលទ្ធផលនៃសូចនាករតាមដាន រួមទាំងអ្វីដែលមានចែងនៅក្នុងលក្ខខណ្ឌវិនិច្ឆ័យ ៨.២។

<u>សូចនាករ៖</u>

*៨.៥.១ ការសង្ខេបជាប្រចាំនូវលទ្ធផលការតាមដាន និងការវិភាពដោយ FMU មានដាក់ជូនសម្រាប់សាធារណជន។ សហគ្រាសទ្រង់ទ្រាយធំ (> ១០.០០០ ហ.ត) ជម្រាបជូនដល់សាធារណជនយ៉ាងសកម្ម ក្នុងអំឡុងកិច្ចប្រជុំប្រចាំជាមួយភាគីពាក់ព័ន្ធ (សូមមើលចំណុច ៤.៤.៤) (**SLIMF**៖ នៅពេលមានការស្នើសុំ FME ត្រូវដាក់ផ្នែកដែលពាក់ព័ន្ធនៃផែនការការគ្រប់គ្រង ជូនភាគីពាក់ព័ន្ធដែលរងផលប៉ះពាល់ដោយផ្ទាល់ពីសកម្មភាពការគ្រប់គ្រងព្រៃឈើ)។*

**គោលការណ៍ទី ៩៖ ការថែរក្សាព្រៃដែលមានតម្លៃខ្ពស់ផ្នែកការអភិរក្ស**
សកម្មភាពគ្រប់គ្រង នៅក្នុងព្រៃដែលមានតម្លៃខ្ពស់ផ្នែកការអភិរក្ស ត្រូវរក្សា ឬពង្រឹងលក្ខណៈសម្បត្តិនានា ដែលជាលក្ខណៈសំគាល់របស់ព្រៃប្រភេទនេះ។ ការសម្រេចចិត្ត ទាក់ទងនឹងព្រៃដែលមានតម្លៃខ្ពស់ផ្នែកការអភិរក្ស ជានិច្ចកាលត្រូវបានយកមកពិចារណាក្នុងបរិបទនៃវិធីប្រកបដោយភាពប្រុងប្រយ័ត្ន។

**លក្ខខណ្ឌវិនិច្ឆ័យ** ៩.១ ការវាយតម្លៃដើម្បីកំណត់វត្តមានរបស់លក្ខណៈសម្បត្តិទាំងឡាយ ដែលស្របគ្នានឹងព្រៃដែលមានតម្លៃខ្ពស់ផ្នែកការអភិរក្ស នឹងត្រូវបានបំពេញរួចរាល់ សមស្របទៅតាមទំហំ និងកម្លាំងរបស់ការគ្រប់គ្រងព្រៃឈើ។

<u>សូចនាករ៖</u>

*៩.១.១ FMU ត្រូវបានវាយតម្លៃយ៉ាងគ្រប់គ្រាន់ (ក្រោមការប្រឹក្សាយោបល់ជាមួយអង្គភាពដែលពាក់ព័ន្ធ ឧ. អង្គការអភិរក្ស អាជ្ញាធរត្រួតពិនិត្យការអនុវត្តច្បាប់ និងភាគីពាក់ព័ន្ធដទៃទៀតនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ) ហើយព្រៃដែលមានតម្លៃខ្ពស់ផ្នែកការអភិរក្ស ព្រមជាមួយលក្ខណៈសម្បត្តិផ្នែកជីវសាស្ត្រ និង/ឬសង្គមសេដ្ឋកិច្ច ឬវប្បធម៌របស់ពួកគេ ត្រូវបានកំណត់។*

*៩.១.២ នីតិវិធីវាយតម្លៃ ត្រូវបានចងក្រងជាឯកសារ ហើយកំណត់ត្រានៃការពិគ្រោះយោបល់ប្រភពព័ត៌មាន និងព័ត៌មាននោះ ត្រូវបានរក្សាទុក។*

*៩.១.៣ ប្រសិនបើមានវត្តមានព្រៃដែលមានតម្លៃខ្ពស់ផ្នែកការអភិរក្សនោះ ការគ្រប់គ្រងព្រៃឈើត្រូវដឹងអំពីលក្ខណៈសម្បត្តិដែលមានស្រាប់ ហើយត្រូវមានផែនទីដើម្បីកំណត់ទីតាំងព្រៃដែលមានតម្លៃខ្ពស់ផ្នែកការអភិរក្ស និងតំបន់ការពារដទៃទៀត។*

**លក្ខខណ្ឌវិនិច្ឆ័យ** ៩.២ ការងារទាក់ទងនឹងការពិគ្រោះយោបល់ ដែលជាផ្នែកមួយនៅក្នុងដំណើរការផ្តល់វិញ្ញាបនប័ត្រ ចាំបាច់ត្រូវសង្កត់ធ្ងន់លើលក្ខណៈសម្បត្តិផ្នែកការអភិរក្ស ដែលត្រូវបានកំណត់ឃើញ និងជម្រើសនានាដើម្បីថែរក្សាលក្ខណៈសម្បត្តិផ្នែកការអភិរក្សទាំងអស់នោះ។

<u>សូចនាករ/សំនួរសំខាន់ៗ៖</u>

*៩.២.១ ម្ចាស់/អ្នកគ្រប់គ្រង បានកំណត់ឃើញការណែនាំជាក់លាក់ ទាក់ទងនឹងការគ្រប់គ្រងព្រៃដែលមានតម្លៃខ្ពស់ផ្នែកការអភិរក្សយ៉ាងសមស្រប ដោយមានការពិគ្រោះយោបល់ជាមួយអង្គការដែលពាក់ព័ន្ធ ឧ. អង្គការអភិរក្ស អាជ្ញាធរត្រួតពិនិត្យការអនុវត្តច្បាប់ និងភាគីពាក់ព័ន្ធដទៃទៀតនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។*

*៩.២.២ នៅពេលមានការកំណត់ឃើញនូវព្រៃដែលមានតម្លៃខ្ពស់ផ្នែកការអភិរក្ស ដោយសារលក្ខណៈសម្បត្តិផ្នែកសង្គមសេដ្ឋកិច្ច ឬផ្នែកវប្បធម៌របស់ព្រៃនោះហើយ គួរមានការវិភាគ និងការសម្រេចចិត្តរួមគ្នារវាងភាគីពាក់ព័ន្ធទាំងឡាយ ដែលរងផលប៉ះពាល់ដោយផ្ទាល់ កិច្ចខិតខំយ៉ាងសមហេតុផលទាំងអស់ គួរត្រូវបានធ្វើឡើងដើម្បីបង្កើតកិច្ចព្រមព្រៀងសហការគ្រប់គ្រង ជាមួយភាគីពាក់ព័ន្ធទាំងនេះ។*

**លក្ខខណ្ឌវិនិច្ឆ័យ ៩.៣** ផែនការការគ្រប់គ្រង ត្រូវរួមបញ្ចូល និងអនុវត្តនូវវិធានការជាក់លាក់ ដែលធានាបាននូវការថែរក្សា និង/ឬការពង្រឹងលក្ខណៈសម្បត្តិផ្នែកការអភិរក្សដែលពាក់ព័ន្ធ អនុលោមទៅតាមវិធីសាស្ត្រការពារទុកជាមុន។ វិធានការទាំងនេះ ត្រូវរួមបញ្ចូលជាពិសេស នៅក្នុងអត្ថបទសង្ខេបផែនការការគ្រប់គ្រងដែលដាក់សម្រាប់សាធារណជន។

<u>សូចនាករៈ</u>

*៩.៣.១ ផែនការការគ្រប់គ្រង ចែងអំពីលក្ខណៈសម្បត្តិរបស់ព្រៃដែលមានតម្លៃខ្ពស់ផ្នែកការអភិរក្ស ដែលត្រូវបានកំណត់ឃើញ ហើយផែនទីបង្ហាញអំពីតំបន់សំខាន់ៗ។*

*៩.៣.២ ផែនការការគ្រប់គ្រង ចែងអំពីវិធានការនានា ដែលធានាបានការថែរក្សា និង/ឬពង្រឹងដល់លក្ខណៈសម្បត្តិដែលពាក់ព័ន្ធរបស់ព្រៃដែលមានតម្លៃខ្ពស់ផ្នែកការអភិរក្ស។*

*៩.៣.៣ អត្ថបទសង្ខេបផែនការការគ្រប់គ្រងដែលដាក់សម្រាប់សាធារណជន មាននៅក្រោមចំណុច ៧.៥ ហើយផ្តុកទៅដោយវិធានការដែលត្រូវបានកំណត់ ដើម្បីពង្រឹងដល់លក្ខណៈសម្បត្តិរបស់ព្រៃដែលមានតម្លៃខ្ពស់ផ្នែកការអភិរក្ស ដែលត្រូវបានកំណត់ឃើញ។*

**លក្ខខណ្ឌវិនិច្ឆ័យ ៩.៤** ការតាមដានប្រចាំឆ្នាំ ត្រូវបានធ្វើឡើង ដើម្បីវាយតម្លៃប្រសិទ្ធភាពរបស់វិធានការដែលត្រូវបានអនុវត្ត ដើម្បីរក្សា ឬពង្រឹងលក្ខណៈសម្បត្តិដែលមានតម្លៃខ្ពស់ផ្នែកការអភិរក្ស ដែលពាក់ព័ន្ធ។

<u>សូចនាករៈ</u>

*៩.៤.១ សូចនាករការតាមដាន និងភាពញឹកញាប់ ត្រូវបានកំណត់ ក្រោមការពិគ្រោះយោបល់ ជាមួយអង្គការដែលពាក់ព័ន្ធ ឧ. អង្គការអភិរក្ស អាជ្ញាធរត្រួតពិនិត្យការអនុវត្តច្បាប់ និងភាគីពាក់ព័ន្ធដទៃទៀតនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ដើម្បីតាមដានប្រសិទ្ធិភាព នៃវិធានការនីមួយ ដែលមានចែងនៅក្នុងផែនការការគ្រប់គ្រង។ (**SLIMF**៖ សូមយោង ទៅសូចនាករ ៨.២.៤–៨.២.៦)។*

*៩.៤.២ កំណត់ត្រានៃការតាមដាន ត្រូវបានរក្សាទុក និងប្រើប្រាស់ ដើម្បីកែសម្រួលដល់ការ គ្រប់គ្រងនាពេលអនាគត។*

## គោលការណ៍ទី១០៖ ចម្ការឈើ

ចម្ការឈើចាំបាច់ត្រូវបានធ្វើផែនការនិងគ្រប់គ្រងស្របទៅតាមគោលការណ៍ និងលក្ខណៈវិនិច្ឆ័យ ១ - ៩, និងគោលការណ៍ទី១០ ព្រមទាំងលក្ខណៈវិនិច្ឆ័យរបស់គោលការណ៍ទី១០។ ថ្វីបើចម្ការឈើអាចផ្តល់អត្ថប្រយោជន៍ផ្នែកសង្គមនិងផ្នែកសេដ្ឋកិច្ចជាច្រើនហើយអាចចូលរួមវិភាគទាន ក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការផលិតផលព្រៃឈើ របស់ពិភពលោកក្តី ប៉ុន្តែសម្ការឈើគួរតែបំពេញបន្ថែមការគ្រប់គ្រង ការកាត់បន្ថយសំពាធ និងការលើកកំពស់នូវការស្តារនិងការអភិរក្សព្រៃធម្មជាតិ។

**លក្ខខណ្ឌវិនិច្ឆ័យ ១០.១** វត្ថុបំណងនៃការគ្រប់គ្រងចម្ការឈើរួមមានការអភិរក្សព្រៃធម្មជាតិ និងវត្ថុបំណងក្នុងការស្តារព្រៃធម្មជាតិ ចាំបាច់ត្រូវតែមានចែងយ៉ាងច្បាស់ នៅក្នុងផែនការគ្រប់គ្រង និងត្រូវបានបកស្រាយបង្ហាញយ៉ាងច្បាស់លាស់នៅក្នុងការអនុវត្តផែនការ។

<u>សូចនាករ៖</u>

*១០.១.១ វត្ថុបំណងនៃការគ្រប់គ្រងចម្ការឈើ ត្រូវបានរួមបញ្ចូលនៅក្នុងផែនការការគ្រប់គ្រងដោយទទួលស្គាល់នូវការអភិរក្ស និងការស្តារព្រៃធម្មជាតិ។*

*១០.១.២ ផែនការការគ្រប់គ្រងព្រៃឈើ រួមនូវបញ្ចូលយុទ្ធសាស្រ្ត ឬធាតុនានាដើម្បីអភិរក្សព្រៃធម្មជាតិនិងដើម្បីស្តារទីតាំងដែលបានថយចុះគុណភាព។*

*១០.១.៣ មានភស្តុតាងច្បាស់លាស់អំពីការអនុវត្តផែនការការគ្រប់គ្រង។ សូមមើលលក្ខណៈវិនិច្ឆ័យ ៧.១ - ៧.៥។*

**លក្ខខណ្ឌវិនិច្ឆ័យ ១០.២** ការតាក់តែង និងរូបរាងរបស់ចម្ការឈើ គួរលើកកំពស់ការការពារ ការស្តារ និងការអភិរក្សព្រៃធម្មជាតិ ហើយមិនបង្កើនសំពាធលើព្រៃធម្មជាតិឡើយ។ ច្រកចេញចូលរបស់សត្វព្រៃនៅតាមតំបន់ជាយមាត់ទឹក និងដើមឈើឈរដែលមានអាយុចម្រុះគ្នា ព្រមទាំងអំឡុងរយៈពេលវិលជុំ គួរត្រូវបានប្រើប្រាស់នៅក្នុងទម្រង់របស់ចម្ការឈើ ឲ្យស៊ីសង្វាក់ជាមួយទំហំនៃប្រតិបត្តិការ។ ទំហំ និងរូបរាងចម្ការ គួរមានលក្ខណៈស៊ីសង្វាក់ជាមួយទម្រង់នៃព្រៃដើមឈើឈរ ដែលមាននៅក្នុងទិដ្ឋភាពធម្មជាតិ។

<u>សូចនាករ៖</u>

*១០.២.១ ការគ្រប់គ្រងចម្ការឈើ ត្រូវបានតាក់តែងឡើងដើម្បីរក្សា ឬពង្រឹងលក្ខណៈសម្បត្តិរបស់ព្រៃធម្មជាតិដែលនៅជាប់នោះ។*

*១០.២.២ គោលនយោបាយ និងនីតិវិធីត្រូវបានអនុវត្តដើម្បីធានាបាននូវ៖*

*ក. ការបង្កើត និងរក្សាឲ្យមានលក្ខណៈចម្រុះគ្នានៃដើមឈើឈរ ដែលមានអាយុផ្សេងៗគ្នា និងការវិលជុំ*

*ខ. ការផ្តល់ឲ្យមានច្រកផ្លូវរបស់សត្វព្រៃ*

*គ. ច្រកចេញចូលរបស់សត្វព្រៃ ដោយកើតពីរុក្ខជាតិធម្មជាតិ នៅតាមជាយមាត់ទឹក ឬនៅក្នុងជ្រលងថ្ម*

*ឃ. ចំណុចទាំងអស់ខាងលើនេះ ត្រូវបានការពារពីប្រតិបត្តិការដាំដុះ និងប្រមូលផល ហើយត្រូវបានអភិវឌ្ឍ*

*ង. ការចូលទៅក្នុងតំបន់រក្សាទុក នៅតាមជាយមាត់ទឹក*

*១០.២.៣ ទាំងទីតាំងការដាំដុះទូទៅ និងការតាក់តែងខាងក្នុងចម្ការឈើ ត្រូវចុះសម្រុងជាមួយទីតាំងភូមិសាស្ត្រនៃតំបន់។*

*១០.២.៤ ផែនការដាំដុះចម្ការឈើរបស់ FMU ស្របគ្នាជាមួយផែនការអភិវឌ្ឍក្នុងមូលដ្ឋាន (នៅកម្រិតខេត្ត ស្រុក និងឃុំ)។*

**លក្ខខណ្ឌវិនិច្ឆ័យ ១០.៣** យកល្អ គួរមានសមាសភាពដើមឈើចម្រុះគ្នានៅក្នុងចម្ការ ដើម្បីជួយពង្រឹងស្ថេរភាពផ្នែកសេដ្ឋកិច្ច អេកូឡូស៊ី និងសង្គម។ លក្ខណៈចម្រុះគ្នាទាំងនេះអាចរួមមានភាពចម្រុះគ្នាផ្នែកទំហំ និងរបាយទីតាំងនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងយោងតាមទីតាំងភូមិសាស្ត្រ ចំនួន និង សមាសធាតុសេនេទិចនៃពូជ ចំណាត់ថ្នាក់អាយុ និងរចនាសម្ព័ន្ធ។

<u>សូចនាករ៖</u>

*១០.៣.១ ការគ្រប់គ្រងចម្ការ ជួយរក្សា និង/ឬពង្រឹងលក្ខណៈចម្រុះគ្នានៅក្នុងតំបន់ តាមរយៈការធ្វើឲ្យមានខ័ណ្ឌដាំដើមឈើទំហំផ្សេងៗគ្នា និងមានរបាយចម្រុះគ្នា នៅក្នុងទីតាំងភូមិសាស្ត្រទាំងមូល។*

*១០.៣.២ ប្រតិបត្តិការការគ្រប់គ្រងព្រៃឈើ បង្កើតឲ្យមានបទបញ្ញត្តិសម្រាប់ការប្រើប្រាស់ចម្រុះគ្នានូវពូជឈើ ប្រភពពូជឈើ និងរុក្ខជាតិដទៃទៀត ។*

*១០.៣.៣ មិនអនុវត្តចំពោះប្រតិបត្តិការ SLIMF៖ យ៉ាងហោច ២០% នៃផ្ទៃចម្ការ ផ្ទុកទៅដោយដំណាំពូជចម្រុះ លើកលែងតែក្នុងករណីមានភាពស៊ីសង្វាក់ជាមួយទម្រង់នៃបំណែងចែកពូជរុក្ខជាតិ តាមធម្មជាតិនៅក្នុងតំបន់សាមីនោះ។*

*១០.៣.៤ មានសម្ភារៈដើម្បីចាត់ចំណាត់ថ្នាក់ដីព្រៃ ហើយត្រូវបានធ្វើផែនទីតាមទំហំសមស្រម*

*១០.៣.៥ ត្រូវមានគម្រោងតាក់តែងចម្ការឈើ ហើយគម្រោងនេះត្រូវបានអនុម័តដោយភ្នាក់ងារមានសមត្ថកិច្ច ក្នុងករណីមានការស្នើឡើងដោយច្បាប់ ។*

**លក្ខខណ្ឌវិនិច្ឆ័យ ១០.៤** ការជ្រើសរើសពូជដើម្បីដាំដុះ ត្រូវតែផ្អែកលើភាពសមស្របជាទូទៅរបស់ពូជជាមួយទីតាំង និងជាមួយវត្ថុបំណងរបស់ការគ្រប់គ្រង។ ដើម្បីពង្រឹងការអភិរក្សភាពចម្រុះផ្នែកជីវសាស្ត្រ ជាការល្អគួរប្រើពូជក្នុងស្រុក ជាជាងពូជនាំចូលពីក្រៅស្រុកសម្រាប់ការបង្កើតចម្ការឈើ និងការស្តារប្រព័ន្ធអេកូឡូស៊ីដែលចុះថមថយ។ គួរប្រើពូជក្រៅស្រុក តែក្នុងករណីដែលពូជនេះ អាចផ្តល់ផលល្អ ដែលខ្លាំងជាងពូជក្នុងស្រុក គួរត្រូវបានតាមដានយ៉ាងប្រុងប្រយ័ត្នដើម្បីពិនិត្យរកក្រែងមានការស្លាប់ជម្ងឺ ឬការផ្ទុះឡើងនៃសត្វល្អិតចង្រៃ និងផលប៉ះពាល់ផ្នែកអេកូឡូស៊ីជាអវិជ្ជមានខុសពីធម្មតា។

<u>សូចនាករៈ</u>

*១០.៤.១ មានមូលដ្ឋានហេតុផលច្បាស់លាស់ សម្រាប់ការជ្រើសរើសពូជ និងប្រភេទសេនេទិច ដើម្បីយកមកដាំដុះនៅក្នុងចម្ការ ដោយត្រូវពិចារណាអំពីវត្ថុបំណងរបស់ចម្ការឈើ ក៏ដូចជាអាកាសធាតុ ផែនដីវិទ្យា និងដីនៅទីតាំងដាំដុះ។*

*១០.៤.២ ប្រសិនបើពូជក្រៅស្រុកត្រូវបានជ្រើសរើសយកមកដាំ ចាំបាច់ត្រូវផ្តល់ភស្តុតាងបង្ហាញថា ពូជនេះផ្តល់លទ្ធផលល្អជាង។*

*១០.៤.៣ មិនត្រូវដាំដុះពូជដំណាំដែលមានលក្ខណៈរាទីនោះឡើយ។*

*១០.៤.៤ មាននីតិវិធីជាលាយល័ក្ខអក្សរ ដើម្បីតាមដានលទ្ធផលរបស់ពូជក្រៅស្រុក ហើយនីតិវិធីនេះត្រូវបានយកមកអនុវត្ត។*

*១០.៤.៥ គួរមានការសង្កត់ធ្ងន់លើការដាំដុះ និង/ឬ ការស្រាវជ្រាវដាក់ស្តែង អំពីពូជឈើក្នុងស្រុក ដែលមានដុះនៅក្នុងតំបន់នោះ។*

**លក្ខខណ្ឌវិនិច្ឆ័យ ១០.៥** ចំណែកមួយចម្ការ ក្នុងសមមាត្រសមស្របទៅនឹងទំហំចម្ការទាំងមូល ហើយដែលនឹងត្រូវកំណត់ដោយយោងទៅតាមបទដ្ឋានថ្នាក់តំបន់ នឹងត្រូវគ្រប់គ្រងយ៉ាងណាដើម្បីស្តារទីតាំងនោះ ឲ្យក្លាយទៅជាគម្របព្រៃធម្មជាតិឡើងវិញ។

<u>សូចនាករៈ</u>

*១០.៥.១ សមមាត្រសមស្រប (ជាទូទៅ ៥-១០%) ក្នុងតំបន់គ្រប់គ្រងព្រៃឈើទាំងមូល ត្រូវបានគ្រប់គ្រងក្នុងលក្ខណៈយ៉ាងណា ដើម្បីស្តារទីតាំងនោះ ឲ្យក្លាយទៅជាគម្របព្រៃធម្មជាតិឡើងវិញ។ (SLIMF៖ ការកែលំអរតម្លៃផ្នែកអេកូឡូស៊ីរបស់ចម្ការ ត្រូវបានធ្វើឡើង ចំពោះកន្លែងណាដែលមានលក្ខណៈសម្បត្តិផ្នែកការអភិរក្ស)។*

*១០.៥.២ មានយុទ្ធសាស្ត្រជាលាយលក្ខណ៍អក្សរ (ជាផ្នែកមួយនៃផែនការគ្រប់គ្រង) សម្រាប់តំបន់ដែលត្រូវស្តារឲ្យក្លាយជាព្រៃធម្មជាតិឡើងវិញ ហើយយុទ្ធសាស្ត្រនេះ ត្រូវបានយកមកអនុវត្ត។*

*១០.៥.៣ តំបន់ដែលត្រូវស្តារឲ្យក្លាយទៅជាគម្របព្រៃធម្មជាតិឡើងវិញ ត្រូវបានដាក់សញ្ញាសំគាល់ព្រំដែននៅលើផែនទី និងត្រូវបានពិចារណានៅក្នុងឯកសារធ្វើផែនការ។*

**លក្ខខណ្ឌវិនិច្ឆ័យ ១០.៦** ត្រូវចាត់វិធានការដើម្បីថែរក្សា ឬកែលំអរចនាសម្ព័ន្ធដី ជីជាតិ និងសកម្មភាពផ្នែកជីវសាស្ត្រ។ បច្ចេកទេស និងអត្រានៃការប្រមូលផល ការសាងសង់ និងថែទាំផ្លូវថ្នល់ ផ្លូវលំ និងជម្រើសពូជ មិនត្រូវបង្កឲ្យមានការថមថយគុណភាពដីរយៈពេលវែង ឬផលប៉ះពាល់ជាអវិជ្ជមានណាមួយចំពោះគុណភាព ឬបរិមាណទឹក ឬធ្វើឲ្យមានការបង្វែរទិសលំហូរទឹកស្ទឹងបឹងបួរ ក្នុងលក្ខណៈធំដុំឡើយ។

<u>សូចនាករ៖</u>

*១០.៦.១ មានការរៀបរាប់អំពីមធ្យោបាយដើម្បីការពារដី និងធនធានទឹកយ៉ាងច្បាស់លាស់នៅក្នុងផែនការការគ្រប់គ្រង ឬឯកសារគាំទ្រដទៃទៀត។*

*១០.៦.២ ផែនការ និងនីតិវិធីដើម្បីស្តារឡើងវិញ ក្រោយពេលប្រមូលផល ត្រូវបានតាក់តែងឡើងដើម្បីកាត់បន្ថយការហាលដីចោលទទេ ហើយត្រូវធានាឲ្យបានថា ដើមឈើត្រូវបានបង្កើតឡើងវិញយ៉ាងឆាប់បំផុតតាមដែលអាចធ្វើបាន។*

*១០.៦.៣ មិនមានភស្តុតាងបង្ហាញអំពីការខូចខាតគុណភាពនៅនឹងកន្លែងប្រតិបត្តិការ។*

*១០.៦.៤ ការអនុវត្តរបស់ការគ្រប់គ្រង មិនបង្កឲ្យមានការថមថយគុណភាពទឹក និង/ឬធ្វើឲ្យមានការប្រែប្រួលដល់ទម្រង់នៃការបង្ហូរទឹកឡើយ។*

**លក្ខខណ្ឌវិនិច្ឆ័យ ១០.៧** ត្រូវចាត់វិធានការដើម្បីទប់ស្កាត់ និងកាត់បន្ថយការផ្ទុះឡើងនូវករណីសត្វចង្រៃ ជំងឺ អគ្គីភ័យ និងការនាំយករុក្ខជាតិដែលមានលក្ខណៈរាទីឡើយ។ ការ

គ្រប់គ្រងបែបរួមបញ្ចូលទៅលើសត្វចង្រៃ ត្រូវតែជាផ្នែកដ៏ចាំបាច់មួយនៅក្នុងផែនការការគ្រប់គ្រង ដោយត្រូវពឹងផ្អែកជាចំបងទៅលើការទប់ស្កាត់ និងវិធីសាស្ត្រគ្រប់គ្រងបែបជីវសាស្ត្រ ជាជាងការប្រើប្រាស់ថ្នាំគីមីកំចាត់សត្វចង្រៃ និងជីគីមី។ ការគ្រប់គ្រងចម្ការ គួរខិតខំដោយប្រើគ្រប់មធ្យោបាយ ដើម្បីជៀសវាងពីការប្រើថ្នាំគីមីកំចាត់សត្វចង្រៃ និងជីគីមី រួមទាំងការប្រើប្រាស់ផលិតផលទាំងនេះនៅក្នុងថ្នាលបណ្តុះកូនឈើផងដែរ។

<u>សូចនាករៈ</u>

*១០.៧.១ សត្វល្អិត និងជំងឺសំខាន់ៗ ដែលកើតមាននៅក្នុងព្រៃ ត្រូវបានកំណត់ឃើញ។*

*១០.៧.២ នីតិវិធីជាលាយលក្ខណ៍អក្សរសម្រាប់ការគ្រប់គ្រងបែបរួមបញ្ចូលទៅលើសត្វចង្រៃ រួមទាំងរុក្ខជាតិដែលមានលក្ខណៈរាទីផងដែរ ត្រូវបានយកមកអនុវត្ត។*

*១០.៧.៣ តម្រូវការក្នុងការគ្រប់គ្រង និងទប់ស្កាត់អគ្គីភ័យ ត្រូវបានវាយតម្លៃ ហើយក្នុងករណីចាំបាច់ ត្រូវមាននីតិវិធី និងឧបករណ៍គ្រប់គ្រាន់ ដើម្បីទប់ស្កាត់ និងពន្លត់ភ្លើងព្រៃ។*

*១០.៧.៤ គោលនយោបាយដើម្បីកាត់បន្ថយការប្រើប្រាស់សារធាតុគីមី និងជីគីមី រួមទាំងការប្រើប្រាស់ផលិតផលទាំងនេះនៅក្នុងថ្នាលបណ្តុះកូនឈើផងដែរ ត្រូវបានយកមកអនុវត្ត។*

**លក្ខខណ្ឌវិនិច្ឆ័យ** ១០.៨ ការតាមដានលើចម្ការ ត្រូវរួមបញ្ចូលការវាយតម្លៃជាប្រចាំលើសក្តានុពលនៃផលប៉ះពាល់ផ្នែកអេកូឡូស៊ី និងសង្គមនៅក្នុង និងក្រៅទីតាំងប្រតិបត្តិការ (ឧ. ការកកើតកូនថៅតាមបែបធម្មជាតិ ផលប៉ះពាល់លើធនធានទឹក និងជីជាតិដី និងផលប៉ះពាល់លើសុខមាលភាពក្នុងមូលដ្ឋាន និងសុខមាលភាពសង្គម) បន្ថែមទៅលើបណ្តាធាតុដែលត្រូវបានលើកឡើងនៅក្នុងគោលការណ៍ទី ៨, ៦ និង ៤ ស្របទៅតាមទំហំ និងនានាភាពរបស់ប្រតិបត្តិការ។ មិនត្រូវដាំពូជណាមួយក្នុងទ្រង់ទ្រាយធំឡើយ លុះត្រាណាតែការសាកល្បង និង/ឬបទពិសោធន៍ក្នុងមូលដ្ឋានបានបង្ហាញថា ពូជទាំងនោះសម្របខ្លួនបានល្អជាមួយអេកូឡូស៊ីរបស់ទីតាំង ហើយមិនមែនជាពូជដែលមានលក្ខណៈរាទី ហើយមិនមានផលប៉ះពាល់ផ្នែកអេកូឡូស៊ីជាអវិជ្ជមានធំដុំ លើប្រព័ន្ធអេកូឡូស៊ីផ្សេងទៀតឡើយ។ មានការផ្តោតការយកចិត្តទុកដាក់ពិសេសលើបញ្ហាផ្នែកសង្គម ទាក់ទងនឹងការទទួលបានដីសម្រាប់ចម្ការ ជាពិសេសគឺការការពារសិទ្ធិជាម្ចាស់កម្មសិទ្ធិ ការប្រើប្រាស់ និងលទ្ធភាពទទួលបាននៅក្នុងមូលដ្ឋាន។

<u>*សូចនាករ៖*</u>

*១០.៨.១ មិនមានការដាំដុះទ្រង់ទ្រាយធំ នូវពូជណាដែលមិនទាន់បានបង្ហាញថាមានភាពសមស្របជាមួយទីតាំង ដោយផ្អែកលើមូលដ្ឋាននៃការសាកល្បង ឬបទពិសោធន៍ក្នុងមូលដ្ឋានឡើយ។*

*១០.៨.២ ចម្ការ មិនត្រូវបានបង្កើតឡើងនៅលើទីតាំងដែលមានសារៈសំខាន់ ឬមានភាពងាយរងើបផ្អែកអេកូឡូស៊ី តំបន់ដែលមានលក្ខណៈចម្រុះផ្អែកជីវសាស្ត្រខ្ពស់ ឬពិសេសដោយឡែក ជាតំបន់ដែលគ្រោងនឹងក្លាយជាតំបន់អភិរក្ស ឬតំបន់ការពារ ឬទីតាំងដែលមានសក្តានុពលអាចបង្កផលប៉ះពាល់ជាអវិជ្ជមានលើតំបន់ស្តុកទឹកសំខាន់ៗ។*

*១០.៨.៣ ការតាមដាន រួមបញ្ចូលការវាយតម្លៃពីសក្តានុពលនៃផលប៉ះពាល់ផ្អែកអេកូឡូស៊ី និងសង្គមរបស់សកម្មភាពការដាំដុះនៅក្នុង និងក្រៅទីតាំងប្រតិបត្តិការ (សូមមើលបន្ថែម លក្ខខណ្ឌវិនិច្ឆ័យ ៨.២)។ (**SLIMF**៖ FME ត្រូវចងក្រងផលប៉ះពាល់អវិជ្ជមានផ្អែកបរិដ្ឋាន ឬផ្អែកសង្គមជាលាយល័ក្ខណ៍អក្សរ ហើយតាក់តែង និងអនុវត្តវិធានការនានាដើម្បីឆ្លើយតបនឹងផលប៉ះពាល់ទាំងនោះ)។*

*១០.៨.៤ ការទិញដី ឬការជួលដីសម្រាប់បង្កើតជាចម្ការ មិនមានផលប៉ះពាល់ជាអវិជ្ជមានលើសហគមន៍ និង/ឬធនធានដែលប្រជាជនមូលដ្ឋានប្រើប្រាស់ ហើយមិនមានចម្ការណាមួយត្រូវបានបង្កើតឡើង នៅលើដីណាដែលមិនទាន់បានដោះស្រាយបញ្ហាកម្មសិទ្ធិ និងសិទ្ធិប្រើប្រាស់នោះឡើយ។*

**លក្ខខណ្ឌវិនិច្ឆ័យ ១០.៩** ចម្ការព្រៃឈើ ត្រូវបានបង្កើតឡើងនៅក្នុងតំបន់ ដែលត្រូវបានប្រែក្លាយពីព្រៃឈើធម្មជាតិក្រោយខែវិច្ឆិកា ឆ្នាំ ១៩៩៤ ដោយតាមធម្មតាគឺមិនត្រូវមានគុណវុឌ្ឍដើម្បីទទួលបានវិញ្ញាបនប័ត្រឡើយ។ ការផ្តល់វិញ្ញាបនប័ត្រ អាចអនុញ្ញាតិឲ្យធ្វើឡើងបាន ក្នុងកាលៈទេសៈដែលមានភស្តុតាងគ្រប់គ្រាន់ត្រូវបានដាក់ជូនទៅស្ថាប័នចេញវិញ្ញាបនប័ត្រ ដែលអ្នកគ្រប់គ្រង/ម្ចាស់ មិនទទួលខុសត្រូវលើការផ្ទេរនេះដោយផ្ទាល់ ឬដោយប្រយោលក្តី។

<u>*សូចនាករ៖*</u>

**១០.៩.១** មានភស្តុតាងជាលាយលក្ខណ៍អក្សរដើម្បីបញ្ជាក់ថា ចម្ការព្រៃឈើមិនត្រូវបង្កើតឡើងនៅលើដីដែលត្រូវបានប្រែក្លាយពីព្រៃធម្មជាតិក្រោយថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៩៩៤ (ប៉ុន្តែ សូមមើលចំណុច ៦.១០ និង ០.៩) លើកលែងតែមានភស្តុតាងច្បាស់លាស់ដើម្បីបញ្ជាក់ថា ម្ចាស់ និងអ្នកគ្រប់គ្រងនាពេលបច្ចុប្បន្ន មិនមែនជាអ្នកទទួលខុសត្រូវដោយផ្ទាល់ ឬដោយប្រយោលក្នុងការប្រែក្លាយនេះ។

## ឧបសម្ព័ន្ធទី ១៖ សទ្ទានុក្រម

(ដកស្រង់ពី៖ "គោលការណ៍ និងលក្ខខណ្ឌវិនិច្ឆ័យ FSC"។ ឯកសារ FSC លេខ ១.២ ច្បាប់កែសម្រួលឡើងវិញក្នុងខែមករា ឆ្នាំ ១៩៩៩)

ពាក្យទាំងឡាយនៅក្នុងឯកសារនេះ ត្រូវបានប្រើប្រាស់តាមន័យដែលត្រូវបានកំណត់នៅក្នុងវចនានុក្រមភាសាអង់គ្លេសជាបទដ្ឋានទូទៅ។ អត្ថន័យជាក់លាក់ និងការបកស្រាយនៅថ្នាក់មូលដ្ឋានសម្រាប់ប្រយោគមួយចំនួន (ដូចជាពាក្យសហគមន៍មូលដ្ឋានជាដើម) គួរត្រូវបានសម្រេចនៅក្នុងបរិបទមូលដ្ឋាន ដោយអ្នកគ្រប់គ្រងព្រៃឈើ និងអ្នកចេញវិញ្ញាបនប័ត្រ។ នៅក្នុងឯកសារនេះ ពាក្យខាងក្រោមត្រូវបានបកស្រាយថាមានអត្ថន័យដូចតទៅ៖

**ភាពចម្រុះផ្នែកជីវសាស្ត្រ៖** ភាពចម្រុះគ្នានៃភាវៈរស់ ដែលមានប្រភពមកពីគ្រប់ទិសទីទាំងអស់ រួមមានដូចជា លើដីគោក ក្នុងទឹក និងពីប្រព័ន្ធអេកូឡូស៊ីជលសាស្ត្រដទៃទៀត និងភាពស្មុគស្មាញផ្នែកអេកូឡូស៊ីដែលភាវៈរស់ទាំងនោះស្ថិតនៅ ដោយរួមបញ្ចូលទាំងភាពចម្រុះដែលមាននៅក្នុងពូជតែមួយ ភាពចម្រុះរវាងពូជខុសៗគ្នា និងភាពចម្រុះរវាងប្រព័ន្ធអេកូឡូស៊ីផ្សេងៗ។ (សូមមើលអនុសញ្ញាស្តីពីភាពចម្រុះផ្នែកជីវសាស្ត្រ ឆ្នាំ ១៩៩២)។

**តម្លៃនៃភាពចម្រុះផ្នែកជីវសាស្ត្រ៖** តម្លៃខាងក្នុង តម្លៃផ្នែកអេកូឡូស៊ី សេនេទិច សង្គម សេដ្ឋកិច្ច វិទ្យាសាស្ត្រ ការអប់រំ វប្បធម៌ ការកំសាន្ត និងសោភ័ណវិទ្យា របស់ភាពចម្រុះផ្នែកជីវសាស្ត្រ និងសមាសធាតុរបស់វា។ (សូមមើលអនុសញ្ញាស្តីពីភាពចម្រុះផ្នែកជីវសាស្ត្រ ឆ្នាំ ១៩៩២)។

**សារធាតុគ្រប់គ្រងផ្នែកជីវសាស្ត្រ៖** ភាវៈរស់ដែលត្រូវបានប្រើប្រាស់ដើម្បីលុបបំបាត់ ឬគ្រប់គ្រងលើចំនួននៃភាវៈរស់ដទៃទៀត។

**សង្វាក់នៃការមើលខុសត្រូវ៖** បណ្តាញនៃលំហូរការចែកចាយផលិតផល ចាប់តាំងពីប្រភពដើមរបស់ផលិតផលនៅក្នុងព្រៃ រហូតដល់អ្នកប្រើប្រាស់ចុងក្រោយ។

**សារធាតុគីមី៖** រួមមានដូចជា ជីគីមី ថ្នាំកម្ចាត់សត្វល្អិត ថ្នាំកម្ចាត់ផ្សិត និងអ័រម៉ូនផ្សេងៗដែលត្រូវបានប្រើប្រាស់នៅក្នុងការគ្រប់គ្រងព្រៃឈើ។

**លក្ខខណ្ឌវិនិច្ឆ័យ ៖** ជាមធ្យោបាយមួយដើម្បីវិនិច្ឆ័យថាតើគោលការណ៍ណាមួយនៃវិញ្ញាបនប័ត្រព្រៃឈើ (forest stewardship) ត្រូវបានបំពេញតាម ឬមិនត្រូវបានបំពេញតាម។

**សិទ្ធិតាមបែបទំនៀមទម្លាប់៖** សិទ្ធិទាំងឡាយដែលជាលទ្ធផលកើតចេញពីសកម្មភាព នៃការតាំងទីលំនៅ ឬសកម្មភាពបែបទំនៀមទម្លាប់ជាច្រើន ដែលត្រូវបានធ្វើឡើងសារចុះសារឡើងជាប្រចាំ ហើយតាមរយៈការធ្វើឡើងសារចុះសារឡើង និងការទទួលបានដោយឥតអាក់នេះ ធ្វើឲ្យជននោះបានទទួលកម្លាំងផ្នែកច្បាប់នៅក្នុងបំណែកភូមិសាស្ត្រ ឬសង្គមសាស្ត្រណាមួយ។

**ប្រព័ន្ធអេកូឡូស៊ីៈ** សហគមន៍រុក្ខជាតិ និងសត្វ ព្រមទាំងបរិស្ថានរូបវន្តទាំងអស់របស់ពួកវា ដែលបំពេញមុខងាររួមគ្នាជាអង្គមួយដែលមានអន្តរកម្មគ្នាទៅវិញទៅមក។

**ជិតផុតពូជៈ** ប្រភេទពូជទាំងឡាយណា ដែលកំពុងប្រឈមនឹងគ្រោះថ្នាក់នៃការផុតពូជទាំងស្រុង ឬការបាត់បង់មួយភាគធំនៃពូជរបស់ខ្លួន។

**ពូជក្រៅស្រុកៈ** ជាប្រភេទពូជនាំចូល ហើយមិនមែនជាពូជក្នុងស្រុក ឬពូជដែលមានជាទូទៅនៅក្នុងតំបន់សាមីនោះឡើយ។

**ការលូតលាស់របស់ព្រៃៈ** សមាសធាតុផ្សំ កម្លាំង មុខងារ និងលក្ខណៈសម្បត្តិផ្នែករចនាសម្ព័ន្ធរបស់ព្រៃធម្មជាតិ។

**ការគ្រប់គ្រង/អ្នកគ្រប់គ្រងព្រៃឈើៈ** មនុស្សដែលទទួលខុសត្រូវលើការគ្រប់គ្រងប្រតិបត្តិការធនធានព្រៃឈើ និងសហគ្រាសព្រៃឈើ ក៏ដូចជាប្រព័ន្ធ និងរចនាសម្ព័ន្ធគ្រប់គ្រង និងការធ្វើផែនការ និងប្រតិបត្តិការនៅមូលដ្ឋាន។

**ភាពៈដែលត្រូវបានកែសម្រួលផ្នែកសេនេទិចៈ** ភាវៈជីវសាស្ត្រដែលត្រូវបានទទួលរងនូវវិធីផ្សេងៗជាច្រើនដែលផ្ទុកទៅដោយការផ្លាស់ប្តូររចនាសម្ព័ន្ធសេនេទិច។

**ដី និងបូរណភាពទឹកដីជនជាតិដើមភាគតិចៈ** បរិស្ថានទាំងមូលដែលរួមមានដី ខ្យល់ ទឹក សមុទ្រ សមុទ្រទឹកកក រុក្ខជាតិ និងសត្វមានជីវិត និងធនធានដទៃទៀតដែលប្រជាជនជនជាតិដើមភាគតិចគឺជាម្ចាស់កម្មសិទ្ធិតាមបែបប្រពៃណី ឬបានកាន់កាប់ ឬប្រើប្រាស់ដីនោះ។ (សេចក្តីព្រៀងការប្រកាសអំពីសិទ្ធិរបស់ជនជាតិដើមភាគតិចៈ ផ្នែកទី VI)

**ប្រជាជនជនជាតិដើមភាគតិចៈ** "កូនចៅដែលមានស្រាប់របស់ប្រជាជនដែលធ្លាប់តាំងទីលំនៅលើដែនដីទាំងមូល ឬដែនដីមួយផ្នែករបស់ប្រទេសបច្ចុប្បន្ន នៅក្នុងពេលមួយដែលមានមនុស្សមកពីវប្បធម៌ ឬប្រភពជាតិពន្ធុដទៃបានមកពីផ្នែកផ្សេងទៀតនៃពិភពលោកមកដល់ទីនោះ និងបានយកឈ្នះលើពួកគេ ហើយតាមរយៈការច្បាំងឈ្នះ ការតាំងទីលំនៅ ឬតាមមធ្យោបាយផ្សេងៗទៀត បានធ្វើឲ្យពួកគេថមថយទៅជាប្រជាជនដែលស្ថិតនៅក្នុងស្ថានភាពមិនគ្របដណ្តប់ ឬមិនស្ថិតនៅក្នុងការត្រួតត្រា ហើយបច្ចុប្បន្នរស់នៅដោយអនុលោមទៅតាមទំនៀមទម្លាប់ និងប្រពៃណីសង្គម សេដ្ឋកិច្ច និងវប្បធម៌ដាច់ដោយឡែករបស់ខ្លួន ជាជាងទៅតាមស្ថាប័នរបស់ប្រទេសដែលពួកគេកំពុងស្ថិតនៅ ក្រោមរចនាសម្ព័ន្ធរបស់រដ្ឋដែលបង្កើតបានជាលក្ខណៈសម្បត្តិចម្បងរបស់ជាតិសង្គម និងវប្បធម៌របស់ប្រជាជនក្រុមផ្សេងទៀត ដែលមានលក្ខណៈជាជនជាតិភាគច្រើន។" (និយមន័យការងារដែលក្រុមការងារទទួលបន្ទុកជនជាតិដើមភាគតិចរបស់អង្គការសហប្រជាជាតិបានអនុម័តយក)។

**ព្រៃឈើដែលមានតម្លៃខ្ពស់ផ្នែកការអភិរក្ស៖** ព្រៃដែលមានតម្លៃខ្ពស់ផ្នែកការអភិរក្ស គឺជាព្រៃទាំងឡាយណាដែលមានលក្ខណៈសម្បត្តិណាមួយក្នុងចំណោមលក្ខណៈសម្បត្តិដូចខាងក្រោម៖

ក. តំបន់ព្រៃផ្ទុកទៅដោយលក្ខណៈសំខាន់ពិសេសជាសកល កម្រិតតំបន់ និងកម្រិតជាតិ៖

- ការប្រមូលផ្តុំនៃតម្លៃផ្នែកជីវសាស្ត្រចម្រុះ (ឧទាហរណ៍ ពូជដើមកំណើត ប្រភេទជិតផុតពូជ តំបន់មិនមានការផ្លាស់ប្តូរផ្នែកអេកូឡូស៊ី) និង/ឬ
- ព្រៃដែលមានកម្រិតទីតាំងភូមិសាស្ត្រធំទូលាយដោយផ្ទុកនៅក្នុងនោះ ឬផ្ទុកនៅក្នុងផ្នែកស្ថិតក្រោមការគ្រប់គ្រងនូវពូជភាគច្រើនដែលកើតឡើងតាមលក្ខណៈធម្មជាតិនៅក្នុងទម្រង់នៃការបែងចែក និងភាពសម្បូរសប្បាយតាមបែបទម្រង់ធម្មជាតិ។

ខ. តំបន់ព្រៃដែលស្ថិតនៅ ឬដែលផ្ទុកទៅដោយប្រព័ន្ធអេកូឡូស៊ីកម្រ រងការគម្រាមកំហែង ឬជិតផុតពូជ

គ. តំបន់ព្រៃដែលផ្តល់សេវាមូលដ្ឋាននៃស្ថានភាពមានសារៈសំខាន់ផ្នែកធម្មជាតិ (ការការពារប្រភពទឹកលើភ្នំ ការគ្រប់គ្រងការហូរច្រោះដី)

ឃ. តំបន់ព្រៃដែលជាមូលដ្ឋានគ្រឹះដើម្បីឆ្លើយតបសេចក្តីត្រូវការមូលដ្ឋានរបស់សហគមន៍មូលដ្ឋាន (ការរស់នៅ សុខភាព) និង/ឬដែលមានសារៈសំខាន់សម្រាប់អត្តសញ្ញាណផ្នែកវប្បធម៌ប្រពៃណីរបស់សហគមន៍មូលដ្ឋាន (តំបន់ដែលមានសារៈសំខាន់ផ្នែកវប្បធម៌ អេកូឡូស៊ី សេដ្ឋកិច្ច ឬសាសនា ដែលត្រូវបានកំណត់ឃើញនៅក្នុងកិច្ចសហការជាមួយសហគមន៍មូលដ្ឋានទាំងនោះ)។

**ទេសភាព (Landscape)៖** ភាពចម្រុះផ្នែកភូមិសាស្ត្រដែលផ្ទុកទៅដោយប្រព័ន្ធអេកូឡូស៊ីមានទំនាក់ទំនងគ្នាទៅវិញទៅមក ដែលជាលទ្ធផលបានមកពីឥទ្ធិពលនៃអន្តរទំនាក់ទំនងផ្នែកភូមិសាស្ត្រ ភូគពសាស្ត្រ ដី អាកាសធាតុ ជីវវិទ្យា និងមនុស្សនៅក្នុងតំបន់ជាក់លាក់ណាមួយ។

**ច្បាប់ក្នុងមូលដ្ឋាន៖** រួមបញ្ចូលនូវនិយាមផ្នែកផ្លូវច្បាប់ទាំងអស់ដែលផ្តល់ដោយស្ថាប័នរដ្ឋាភិបាលដែលមានយុត្តាធិការទាបជាងស្ថាប័នថ្នាក់ជាតិ ដូចជាច្បាប់របស់ថ្នាក់មន្ទីរ ថ្នាក់ក្រុង និងច្បាប់បែបទំនៀមទម្លាប់ជាដើម។

**រយៈពេលវែង៖** រង្វាស់ពេលវេលារបស់ម្ចាស់ ឬអ្នកគ្រប់គ្រងព្រៃឈើដូចដែលបានបង្ហាញនៅក្នុងវត្ថុបំណងនៃផែនការការគ្រប់គ្រង អត្រានៃការប្រមូលផល និងការប្តេជ្ញាក្នុងការរក្សាគម្របព្រៃអចិន្ត្រៃយ៍។ ប្រវែងរយៈពេលអាចខុសៗគ្នាយោងទៅតាមបរិបទ និងលក្ខខណ្ឌផ្នែកអេកូឡូស៊ី ហើយនឹងបំពេញមុខងារថាតើត្រូវចំណាយរយៈពេលប៉ុន្មានដើម្បីផ្តល់ឲ្យប្រព័ន្ធអេកូឡូស៊ីអាចសះជានូវ

រចនាសម្ព័ន្ធធម្មជាតិរបស់ខ្លួនឡើងវិញ និងសមាសធាតុរបស់ខ្លួនក្រោយពេលការប្រមូលផល ឬការរំខានណាមួយ ឬដើម្បីបង្កើតឲ្យមានលក្ខខណ្ឌចាស់ទុំ ឬលក្ខខណ្ឌចម្បងបាន។

**ពូជក្នុងស្រុក៖** ពូជមួយប្រភេទដែលកើតឡើងជាធម្មជាតិនៅក្នុងតំបន់ ដែលមានសាយភាយសម្រាប់តំបន់នោះ។

**វដ្តធម្មជាតិ៖** វដ្តផ្នែកសមាសធាតុគីមីអាហារ និងរ៉ែដែលជាលទ្ធផលបានពីអន្តរទំនាក់ទំនងរវាងដី ទឹក រុក្ខជាតិ និងសត្វនានានៅក្នុងបរិស្ថានព្រៃឈើដែលជះឥទ្ធិពលលើផលិតភាពអេកូឡូស៊ីនៃទីតាំងណាមួយ។

**ព្រៃធម្មជាតិ៖** តំបន់ព្រៃដែលក្នុងនោះលក្ខណៈសម្បត្តិចម្បង និងធាតុគន្លឹះនៃប្រព័ន្ធអេកូឡូស៊ីក្នុងមូលដ្ឋានដូចជាភាពស្មុគស្មាញ រចនាសម្ព័ន្ធ និងភាពចម្រុះ មានវត្តមាន ដូចដែលត្រូវបានកំណត់ដោយ FSC ដែលអនុម័តដោយបទដ្ឋានថ្នាក់ជាតិ និងថ្នាក់តំបន់នៃការគ្រប់គ្រងព្រៃឈើ។

**អនុផលព្រៃឈើ៖** ផលិតផលដែលបានពីព្រៃទាំងអស់ លើកលែងតែឈើ ដោយក្នុងនោះរួមមានសម្ភារៈដទៃទៀតដែលបានទទួលពីដើមឈើ ដូចជាជ័រឈើ និងស្លឹកឈើ ក៏ដូចជាផលិតផលរុក្ខជាតិ និងផលិតផលសត្វដទៃទៀតផងដែរ។

**ប្រភេទព្រៃឈើផ្សេងទៀត៖** តំបន់ព្រៃឈើដែលមិនស៊ីទៅតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការដាំដុះចម្ការ ឬព្រៃធម្មជាតិ ហើយដែលត្រូវបានកំណត់យ៉ាងជាក់ច្បាស់ដោយបទដ្ឋានដែលទទួលបានការអនុម័តពី FSC ថ្នាក់ជាតិ និងថ្នាក់តំបន់ក្នុងការផ្តល់វិញ្ញាបនប័ត្រព្រៃឈើ។

**ចម្ការព្រៃឈើ៖** តំបន់ព្រៃ ដែលខ្វះខាតលក្ខណៈសម្បត្តិសំខាន់ៗភាគច្រើន និងធាតុចម្បងរបស់ប្រព័ន្ធអេកូឡូស៊ីក្នុងស្រុក ដូចដែលបានកំណត់ដោយបទដ្ឋាន FSC ដែលត្រូវបានអនុម័តនៅថ្នាក់ជាតិ និងថ្នាក់តំបន់ស្តីពីការផ្តល់វិញ្ញាបនប័ត្រព្រៃឈើ ដែលជាលទ្ធផលកើតចេញពីសកម្មភាពមនុស្សនៅក្នុងការដាំដុះ សាបព្រោះ ឬការប្រព្រឹត្តក្នុងការដាំដុះព្រៃបែបប្រពលវប្បកម្ម។

**គោលការណ៍៖** វិធាន ឬធាតុចាំបាច់ នៅក្នុងករណីរបស់ FSC គឺសំដៅលើវិធាន ឬធាតុចាំបាច់នៃការផ្តល់វិញ្ញាបនប័ត្រព្រៃឈើ។។

**វិធីសាស្ត្រដាំដុះព្រៃ៖** សិល្បៈក្នុងការផលិត និងការថែទាំព្រៃឈើតាមរយៈការប្រើប្រាស់ ការបង្កើត សមាសធាតុ និងការលូតលាស់របស់វាដើម្បីបំពេញវត្ថុបំណងរបស់ម្ចាស់ឲ្យបានល្អបំផុត។ ចំណុចនេះអាចរួមបញ្ចូល ឬមិនរួមបញ្ចូលនូវផលិតកម្មឈើ។

**ការស្នងបន្ត៖** ការផ្លាស់ប្តូរជាបន្តបន្ទាប់នៅក្នុងសមាសធាតុរបស់ពូជ និងរចនាសម្ព័ន្ធសហគមន៍ព្រៃឈើ ដែលបង្កឡើងដោយដំណើរការធម្មជាតិ (មិនមែនបង្កឡើងដោយមនុស្ស)។

**សិទ្ធិកាន់កាប់៖** កិច្ចព្រមព្រៀងដែលត្រូវបានកំណត់ដោយសង្គម ដែលកាន់កាប់ដោយបុគ្គល ឬក្រុម ទទួលស្គាល់ដោយស្ថាប័នផ្នែកច្បាប់ ឬការអនុវត្តតាមបែបទំនៀមទម្លាប់ ទាក់ទង "នឹងកញ្ចប់នៃសិទ្ធិ និងការតព្វកិច្ច" នៃភាពជាម្ចាស់ ការកាន់កាប់ លទ្ធភាពក្នុងការចូលទៅរក និង/ឬការប្រើប្រាស់បំណែកដីជាក់លាក់ណាមួយ ឬធនធានពាក់ព័ន្ធដែលមាននៅក្នុងដីនោះ (ដូចជាដើមឈើ ពូជរុក្ខជាតិ ទឹក រ៉ែ។ល។)។

**ប្រភេទពូជរងការគម្រាមកំហែង៖** ពូជទាំងឡាយណាដែលទំនងជានឹងអាចឈានទៅជិតផុតពូជនៅក្នុងពេលអនាគតដែលអាចប្រមើលមើលបានតាមរយៈបំណែកទាំងអស់ ឬបំណែកគួរឲ្យកត់សម្គាល់ណាមួយនៃលំដាប់របស់ខ្លួន។

**សិទ្ធិប្រើប្រាស់៖** សិទ្ធិក្នុងការប្រើប្រាស់ធនធានព្រៃឈើ ដែលអាចកំណត់ដោយទំនៀមទម្លាប់ក្នុងមូលដ្ឋាន កិច្ចព្រមព្រៀងទៅវិញទៅមក ឬដែលត្រូវបានកំណត់ដោយស្ថាប័នដទៃទៀតដែលមានលទ្ធភាពចូលទៅក្នុងសិទ្ធិនោះ។ សិទ្ធិទាំងនេះអាចដាក់កំហិតទៅលើការប្រើប្រាស់ធនធានជាក់លាក់ណាមួយនៅកម្រិតជាក់លាក់ក្នុងការប្រើប្រាស់ ឬបច្ចេកទេសប្រមូលផលជាក់លាក់ណាមួយ។

## ឧបសម្ព័ន្ធទី ២៖ ច្បាប់ និងបទបញ្ញត្តិនានា

### ច្បាប់ ក្រិត្យច្បាប់ អនុក្រឹត្យ និងបទបញ្ញត្តិនានាទាក់ទងនឹងព្រៃឈើ

| ល.រ | ឈ្មោះ | ចំនួន និងកាលបរិច្ឆេទ | ចេញដោយ |
|---|---|---|---|
| | **ច្បាប់ និងក្រិត្យច្បាប់** | | |
| ១ | ច្បាប់ស្តីពីព្រៃឈើ (Forestry Law) | ៣១-០៨-០២ | ព្រះបរមរាជវាំង |
| ២ | ក្រឹត្យច្បាប់ស្តីពីការគ្រប់គ្រងព្រៃឈើ (Decree-Law on Forest Management) | ៣៥. ២៥-០៦-១៩៨៨ | ទីស្តីការគណរដ្ឋមន្ត្រី |
| | **ព្រះរាជក្រឹត្យ** | | |
| ១ | ច្បាប់ស្តីពីការចាត់តាំងសត្វ និងរុក្ខជាតិជានិមិត្តរូបជាតិនៃព្រះរាជាណាចក្រកម្ពុជា (Designation of animals and plants as National Symbols of the Kingdom of Cambodia) | ០៣០៥/១៩៩ ២១/០៣/២០០៥ | ព្រះបរមរាជវាំង |
| ២ | ស្តីពីការបង្កើតបតំបន់អភិរក្សអាងត្រពាំងថ្មក្នុងស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ (On the Establishment of Ang Trapeang Thmor Sarus Crane Conservation Area in Phnom Srok District, Banteay Meanchey Province) | ០២០០/១១០. ២២-០២-២០០០ | ព្រះបរមរាជវាំង |
| ៣ | ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ប្រភពទឹកលើភ្នំក្នុងប្រទេសកម្ពុជា (On the Establishment and Management of Watershed Areas in the Kingdom of Cambodia) | ០១៩៩/០៧.១១-០១-១៩៩៩ | ព្រះបរមរាជវាំង |
| ៤ | ស្តីពីតំបន់ការពារធម្មជាតិ (On Protected Areas for Nature) | ០១-១១-១៩៩៤ | ព្រះបរមរាជវាំង |
| | **អនុក្រឹត្យ** | | |
| ១ | ស្តីពីផលិតផលឈើ និងអនុផលព្រៃឈើ ដែលត្រូវបានអនុញ្ញាតិសម្រាប់ការនាំចេញ និងនាំចូល (ឯកសារភ្ជាប់៖ | ១៣១/២០.១១.២០០៦ | រដ្ឋាភិបាល |

| | | | |
|---|---|---|---|
| | ដំណើរការក្នុងការស្នើសុំនាំចេញ-នាំចូលផលិតផលឈើ និងអនុផលព្រៃឈើ) On Timber and Non-Timber Forest Products Allow for Expot and Import (Attachment: Processes of Request for Export-Import of Timber and Non Timber Forest Products) | | |
| ២ | ការគ្រប់គ្រងដីរដ្ឋ (Statt Land Management) | ១១៨ . ១០/២០០៥ | រដ្ឋាភិបាល |
| ៣ | ការផ្ទេរចលនទ្រព្យ និងអចលនទ្រព្យ ឯកសារដែលពាក់ព័ន្ធ និងការដាក់សាលាកសិកម្មព្រែកលាបរបស់រដ្ឋាភិបាល ឲ្យនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Transfer of morable and nonmovable properties, relevant documents and government statt of Prek Learp Agriculture school to be under the ក្រសួងកសិកម្ម) | ៧៥. ១៥/១១/២០០៥ | រដ្ឋាភិបាល |
| ៤ | ស្ដីពីការបង្កើតតំបន់ការពារជីវសាស្ត្រចម្រុះ អភិរក្សច្រកផ្លើដំណើររបស់ដំរី និងមជ្ឈមណ្ឌលស្តារសត្វព្រៃនៅខេត្តកោះកុង (On the establishment of the proted forest for biodiversity conservation elephant corridor protection and wildlife rehabilitation centre in Koh Kong province) | ៦៥. ០៦/១០/២០០៤ | រដ្ឋាភិបាល |
| ៥ | ច្បាប់ស្ដីពីការបង្កើត ចាត់ថ្នាក់ និងចុះបញ្ជីដីព្រៃអចិន្ត្រៃ (Ligislation on establishment clacification and registration of perminant forest estate) | ៥៣/ | រដ្ឋាភិបាល |
| ៦ | ស្ដីពីការប្ដូរឈ្មោះ DFW ទៅជា រដ្ឋបាលព្រៃឈើ (On the rename from DFW to FA) | ៦៤. ១១/០៩/២០០៣ | រដ្ឋាភិបាល |
| ៧ | ស្ដីពីការគ្រប់គ្រងព្រៃសហគមន៍ (On the community forestry management) | ៧៩. ០២/១២/២០០៣ | រដ្ឋាភិបាល |
| ៨ | ស្ដីពីការបង្កើតព្រៃការពារមណ្ឌលគិរី សម្រាប់ការអភិរក្ស | ៧៥. ៣០-០៧-២០០២ | រដ្ឋាភិបាល |

| | | | |
|---|---|---|---|
| | ធនធានសេនេទិច និងសត្វព្រៃ (On the Establishment of Protected Forest MondulKiri for Genetic Resources and Wildlife Conservation) | | |
| ៩ | ស្តីពីការបង្កើតព្រៃការពារព្រះវិហារ សម្រាប់ការអភិរក្ស ធនធានសេនេទិច និងសត្វព្រៃ (On the Establishment of Protected Forest Preah Vihear for Genetic Resources and Wildlife Conservation) | ៧៦. ៣០-០៧-២០០២ | រដ្ឋាភិបាល |
| ១០ | ស្តីពីការបង្កើតព្រៃការពារភ្នំក្រវ៉ាញ សម្រាប់ការអភិរក្ស ប្រភពទឹកលើភ្នំ និងជីវសាស្ត្រចម្រុះ (On the Establishment of Protected Forest Cardamom for Watershed and Biodiversity Conservation) | ៧៧. ៣០-០៧-២០០២ | រដ្ឋាភិបាល |
| ១១ | ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (On the Preparation and On-going Activities of ក្រសួងកសិកម្ម) | ១៧. ០៧-០៤-២០០០ | រដ្ឋាភិបាល |
| ១២ | ស្តីពីការគ្រប់គ្រងដីសម្បទាន (On Forest Concession Management) | ០៥. '០៧-០២-២០០០ | រដ្ឋាភិបាល |
| ១៣ | ស្តីពីការគ្រប់គ្រងធនធានធម្មជាតិសម្រាប់តំបន់ព្រែកទឹកសាប ក្នុងក្រុងព្រះសីហនុ (On Natural Resource Management for Preak Tueksap Area, Sihanouk Ville Municipality) | ៧៦. ២០-១១-១៩៩៧ | រដ្ឋាភិបាល |
| ១៤ | ស្តីពីវិសោធនកម្មលើការគ្រប់គ្រងធម្មជាតិសម្រាប់តំបន់ព្រែកទឹកសាប ក្នុងក្រុងព្រះសីហនុ (On the Amendment of Natural Resource Management for Preak Tueksap Area, Sihanouk Ville Municipality) | ៧០. ២៩-១០-១៩៩៨ | រដ្ឋាភិបាល |
| ១៥ | ស្តីពីការបង្កើតគណកម្មការជាតិដើម្បីគ្រប់គ្រង និងអនុវត្តគោលនយោបាយគ្រប់គ្រងព្រៃឈើ (On the Establishment of the National Committee to Manage | ៣៣. '០៣-០៧-១៩៩៦ | រដ្ឋាភិបាល |

| | | | |
|---|---|---|---|
| | and Execute Forest Management Policy) | | |
| ១៦ | ស្តីពីការដេញថ្លៃព្រៃដើម្បីប្រមូលផល (On Forest Coupe Bidding for Harvesting) | ១១. ២០-០៥-១៩៩១ | ទីស្តីការគណរដ្ឋមន្ត្រី |
| | **ប្រកាស** | | |
| ១ | ស្តីពីការប្រកាសឲ្យប្រើប្រាស់លិខិតអនុញ្ញាតនៅក្នុងរដ្ឋបាលព្រៃឈើ (On the Promulgation of permission letters in FA) | ៣៦៧. ០៣/១២/២០០៤ | ក្រសួងកសិកម្ម |
| ២ | ស្តីពីការបង្កើតប្រភពផ្តល់ពូជស្រល់ និងតាត្រាវ នៅខេត្តកំពង់ធំ (On the establishment of Sroal and Tatrav seed sources area at Kampong Thom Province) | ៣៣៣. ១៨/១០/២០០៤ | ក្រសួងកសិកម្ម |
| ៣ | ស្តីពីការបង្កើតក្រហាំង និងថងនៅខេត្តសៀមរាប (On the Establishment of Kronhung and Thorng at Seam Reap Province) | ៣៣៤. ១៨/១០/២០០៤ | ក្រសួងកសិកម្ម |
| ៤ | ស្តីពីនីតិវិធីធ្វើការងាររបស់ប៉ូលីសយុត្តិធម៌ (On the working procedures of police of justice) | ២៧. ១១/០៦/២០០៤ | ក្រសួងយុត្តិធម៌ |
| ៥ | ស្តីពីការប្រកាសឲ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងចំណូលពីព្រៃឈើ (On the promulgation of forest revenue management system) | ៦០៩. ៩៧២ ២៨/០៨/០៣ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម |
| ៦ | ស្តីពីការពន្យាពេលការកាប់ឈើហ៊ុបនៅក្នុងព្រៃសម្បទាន (On the Postponement of Logging in Coupes of Forest Concessions) | ៥៧២១. ១៣-១២-២០០១ | ក្រសួងកសិកម្ម |
| ៧ | ស្តីពីការបង្កើតតំបន់អភិរក្សជីវសាស្ត្រចម្រុះសីមា ក្នុងព្រៃសម្បទានសំលីង ក្នុងខេត្តមណ្ឌលគិរី និងក្រចេះ (On the Establishment of Seima Biodiversity Conservation Area in Samling Forest Concession in Mondul Kiri and Kratie Provinces) | ២៦០. ១២-០៨-២០០២ | ក្រសួងកសិកម្ម |

| | | | |
|---|---|---|---|
| ៨ | ស្តីពីការពន្យាពេលការដឹកជញ្ជូនឈើដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនសម្បទាន (On the Postponement of Log Transportation Belonging to Concession Companies) | ១៥៥. ២១-០៥-២០០២ | ក្រសួងកសិកម្ម |
| ៩ | ស្តីពីការបង្កើតប្រភពគ្រាប់ឈើនៅក្នុងប្លុក ៨ គូប IV-១២ អនុតំបន់ IV ព្រៃសម្បទានកូឡិចស៊ីម ឃុំទម្រឹង ស្រុកសណ្តាន់ ខេត្តកំពង់ធំ (On the Establishment of Seed Source in Block 8, Coupe IV-12, Sub-Region IV, Colexim Forest Concession, Toumring Commune, Sandan District, Kampong Thom Province) | ១០២. ២៦-០៣-២០០២ | ក្រសួងកសិកម្ម |
| ១០ | ស្តីពដែនកំណត់នៃទម្ងន់អតិបរមារបស់យានយន្តដឹកជញ្ជូនផលិតផលព្រៃឈើនៅតាមដងផ្លូវក្នុងព្រះរាជាណាចក្រកម្ពុជា (On the Limitation of the Maximum Weight of Vehicles with Forest Products Transported along Roads in the Kingdom of Cambodia) | ៥២៧. ២៨-១២-២០០១ | ក្រសួងកសិកម្ម |
| ១១ | ស្តីពីការបង្កើតប្រភពពូជសម្រាប់ដើម Dalbergia bariensis នៅឃុំប៉ាលហាល ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ (On the Establishment of Seed Source for Dalbergia bariensis in Palhal Commune, Tbeng Meanchey District, Preah Vihear Province) | ៤៨៩. ០៥-១២-២០០១ | ក្រសួងកសិកម្ម |
| ១២ | ស្តីពីការហាមឃាត់ការប្រមូលផល បេះ និងកែច្នៃវល្លិ៍លឿង (On the Prohibition of Yellow Vine Harvesting, Collection and Processing) | ១៨០. ១៣-០៥-២០០១ | ក្រសួងកសិកម្ម |
| ១៣ | ស្តីពីការហាមឃាត់ពាណិជ្ជកម្មព្រៃឈើ ការប្រមូលផលព្រៃឈើ ការទន្ទ្រានព្រៃ និងការប្រមាញ់សត្វព្រៃនៅក្នុងតំបន់ភ្នំក្រវាញកណ្តាល (On the Prohibition of Forest Trade, Forest Harvesting, Forestland Encroachment and Wildlife Hunting in the Central Cardamom Region) | ០២២/ ២២. ២២-០១-២០០១ | ក្រសួងកសិកម្ម |
| ១៤ | ស្តីពីការគ្រប់គ្រង និងការទប់ស្កាត់ការប្រើប្រាស់ម៉ាស៊ីន | ៥៤០. ១៨-០៩- | |

| | | | |
|---|---|---|---|
| | អារឈើ ឧបករណ៍ និងគ្រឿងចក្រនៅក្នុងសកម្មភាពប្រមូលផលព្រៃឈើ (On the Management and Control of the Use of Chainsaws, Equipment and Machinery in Forest Harvesting Activities) | ២០០០ | ក្រសួងកសិកម្ម |
| ១៥ | ស្តីពីវិធានការដើម្បីបង្ក្រាបសកម្មភាពទន្ទ្រានដីអាណាធិបតេយ្យ (On the Measures to Suppress Anarchic Activities for Land Encroachment) | ០៦. ២៧-០៩-១៩៩៩ | រដ្ឋាភិបាល |
| ១៦ | ស្តីពីការប្រើប្រាស់ក្រមព្រៃឈើកម្ពុជាជាផ្លូវការ ក្នុងការអនុវត្តប្រមូលផលព្រៃឈើ (On the Official Use of the Cambodian Forestry Code of Practice for Forest Harvesting) | ៥៣០. ២៦-០៧-១៩៩៩ | ក្រសួងកសិកម្ម |
| ១៧ | ស្តីពីការបង្កើតស្ថានីយ៍ដាំដើមឈើអង្គរជ័យ ក្នុងខេត្តកំពត (On the Establishment of Angkor Chey Tree Planting Station in Kampot Province) | ២៤៥. ១៩-០៤-១៩៩៩ | ក្រសួងកសិកម្ម |
| ១៨ | ស្តីពីវិធានការដើម្បីទប់ស្កាត់ និងបង្ក្រាបសកម្មភាពអាណាធិបតេយ្យក្នុងវិស័យព្រៃឈើ (On the Measures to Control and Suppress Anarchic Activities in the Forestry Sector) | ០១. ២៥-០១-១៩៩៩ | រដ្ឋាភិបាល |
| ១៩ | ស្តីពីបទបញ្ជារបស់រាជរដ្ឋាភិបាល (On the order of Royal Government) | ០២. ០៦-០១-១៩៩៩ | រដ្ឋាភិបាល |
| ២០ | ស្តីពីការប្រើប្រាស់ បទដ្ឋានលិខិតសម្រាប់មន្ត្រីព្រៃឈើ (On the use of Standard letter for forestry officer) | ០០៧១. ១១-០៩-១៩៨៩ | អន្តរក្រសួង |
| ២១ | ស្តីពីការបង្កើតស្ថានីយ៍ដាំឈើ មានក ក្នុងខេត្តកំពង់ឆ្នាំង (On the Establishment of Mear Nork Tree Planting Station in Kampong Chhnang Province) | ១៨៦. ០៨-០៥-១៩៩៧ | ក្រសួងកសិកម្ម |
| ២២ | ស្តីពីការហាមឃាត់ការនាំចេញឈើមូល និងឈើអារពីព្រះរាជាណាចក្រកម្ពុជា (On the prohibition of Export of Round logs and Sawn Wood from the Kingdom of | ០២. ២៦-១២-១៩៩៦ | រដ្ឋាភិបាល |

| | | | |
|---|---|---|---|
| | Camboidia) | | |
| ២៣ | ស្តីពីការកាប់ឈើ និងនាំចេញឈើខុសច្បាប់ (On Illegal Loogging and Export) | ០១. ២៩-១០-១៩៩៦ | រដ្ឋាភិបាល |
| ២៤ | ស្តីពីការបង្កើតស្ថានីយ៍ដាំឈើទឹកឆាក្នុងខេត្តកំពង់ចាម (On the Establishment of Tuek Chhar Tree Planting Station in Kampong Cham Province) | ៩៩១. ២៦-០៧-១៩៩៦ | ក្រសួងកសិកម្ម |
| ២៥ | ស្តីពីការបង្កើតសួនសត្វភ្នំតាម៉ៅ ក្នុងខេត្តតាកែវ (On the Establishment of Phnom Tamao Zoo in Takeo Province) | ៣១៣. ២២-០៥-១៩៩៦ | ក្រសួងកសិកម្ម |
| ២៦ | ស្តីពីប្រាក់ពន្ធ និងតម្លៃឈើសម្រាប់ការទិញ និងលក់នៅច្រកព្រំដែន (On Royalties and Log Prices for Buying and Selling at Export Check Points) | ១០០. ២៧-០២-១៩៩៦ | អន្តរក្រសួង |
| ២៧ | ស្តីពីគោលនយោបាយព្រៃឈើ (On Forest Policy) | ០៣. ២៨-០៩-១៩៩៥ | រដ្ឋាភិបាល |
| ២៨ | ស្តីពីការបង្កើតឯកសណ្ឋាន និងរូបសញ្ញារបស់ DFW (On the Establishment of Uniform and logo of DFW) | ៣៥៧. ១០-១១-១៩៩៤ | ក្រសួងកសិកម្ម |
| ២៩ | ស្តីពីការបង្កើតស្ថានីយ៍ដាំឈើភ្នំតាម៉ៅ ក្នុងខេត្តតាកែវ (On the Establishment of Phnom Tamao Tree Planting Station in Takao Province) | ៣០៨. ១៩-១០-១៩៩៤ | ក្រសួងកសិកម្ម |
| ៣០ | ស្តីពីពូជសត្វព្រៃដែលត្រូវហាមឃាត់មិនឲ្យបរបាញ់ (On Wildlife Species to be Prohibited for Hunting) | ៣៥៩. '០១-០៨-១៩៩៤ | ក្រសួងកសិកម្ម |
| ៣១ | ស្តីពីពូជឈើដែលត្រូវហាមឃាត់មិនឲ្យកាប់ (On Tree Species to be Prohibited for Cutting) | ០៣២. '០៩-០២-១៩៩៣ | ក្រសួងកសិកម្ម |
| ៣២ | ស្តីពីវិធានក្នុងការដេញថ្លៃឈើសម្រាប់ប្រមូលផល (On the Rules of Forest Coupe Bidding for Harvesting) | ២៨៨. '០៣-០៧-១៩៩១ | ក្រសួងកសិកម្ម |
| ៣៣ | ស្តីពីការបង្កើត និងការគ្រប់គ្រងរោងម៉ាស៊ីនអារឈើ រោងចក្រកែច្នៃឈើ រោងជាង និងសិប្បកម្ម ដែលប្រើប្រាស់វត្ថុធាតុដើមព្រៃឈើ ឡធ្យូង និងដេប៉ូលក់ផលិតផលព្រៃឈើដែលជាកម្មសិទ្ធិរបស់អង្គភាពរដ្ឋ រដ្ឋ-ឯកជន និង | ០០៩២. ១១-១០-១៩៨៩ | ក្រសួងកសិកម្ម |

| | | | |
|---|---|---|---|
| | ឯកជន (On the Establishment and Management of Sawmills, Wood Processing Factories, Workshops and Handicrafts Using Raw Materials of Forest Products, Charcoal Kilns, and Depots for Forest Product Trade Belonging to the State, State-Private and Private Entities) | | |
| ៣៤ | ស្តីពីការបង្ក្រាបការបំផ្លាញសត្វព្រៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា (On the Suppression of Wildlife Destruction in the Kingdom of Cambodia) | ១៥៦៣. ២០-០៩-១៩៩៦ | អន្តរក្រសួង |
| ៣៥ | ស្តីពីការបង្កើតឯកសណ្ឋាន និងអាំងស៊ីញសម្រាប់មន្ត្រីព្រៃឈើ (On the Establishment of the Uniform and Insignia of Forestry Officers) | ០០៧២.១១-០៩-១៩៨៩ | ក្រសួងកសិកម្ម |
| ៣៦ | ស្តីពីការចាត់ចែងមន្ត្រី (On the assignmentof officers) | ០៨៩. ០២-០៣-០៤ | ក្រសួងកសិកម្ម |
| ៣៧ | ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់រដ្ឋបាលព្រៃឈើ (On the Organization and functioning of Forestry Administration) | ៥០៩.១៧-០៩-២០០៣ | ក្រសួងកសិកម្ម |

## សេចក្តីសម្រេច

| | | | |
|---|---|---|---|
| ១ | ស្តីពីការបង្កើតគណកម្មការជាតិដើម្បីបង្ក្រាប លុបបំបាត់ និងចាត់វិធានការលើការកាប់ ការដុត ការឈូសឆាយ និងការកាន់កាប់លើដីព្រៃ។ (On the establishment of the nationalcommittee for suppressing eliminating and cracking down the forest cutting, burning, clering and occupying foret estate) | ៣២. ០២-០៦-០៤ | រដ្ឋាភិបាល |
| ២ | ស្តីពីរោងចក្រអារឈើខ្នាតធំ និងខ្នាតតូច ដែលត្រូវលុបចោលនៅទូទាំងប្រទេស (on Large and Small Scale Sawmills to be Cancelled throughout the Country) | ៥០. ០២-០៧-១៩៩៩ | រដ្ឋាភិបាល |
| ៣ | ស្តីពីផលិតផលព្រៃឈើដែលត្រូវហាមឃាត់ និងអនុញ្ញាតិ | ១៧. ២៩-០៤-១៩៩៧ | |

| | | | |
|---|---|---|---|
| | ឲ្យនាំចេញ និងការកំណត់ច្រកនាំចេញ។ (on Forest Products to be Prohibited and Allowed for Export, and the Identification of Export Checkpoint) | | រដ្ឋាភិបាល |
| ៤ | ស្តីពីការលុបចោលនីតិវិធីស្តីពកូតាចាស់សម្រាប់ការនាំចេញឈើ (on the Cancellation Procedure of Old Quotas for Log Exports) | ៦៥. ១៨-០៦-១៩៩៤ | រដ្ឋាភិបាល |
| ៥ | ស្តីពីវិសោធនកម្មលើការរៀបចំរបស់ DFW (On the Amendment of Organization of DFW) | ៩១២. ០២-០៩-១៩៩២ | ក្រសួងកសិកម្ម |
| ៦ | ស្តីពីការប្រកាសឲ្យប្រើប្រាស់លិខិតផ្លូវការ និងឯកសារដទៃទៀតរបស់ DFW (On the promulgation of Official Letters and Other Documents of DFW) | ០០៧៧. ១៧-១០-១៩៨៨ | ក្រសួងកសិកម្ម |
| ៧ | ស្តីពីចំណូលព្រៃឈើសម្រាប់ការការពារ និងការថែទាំព្រៃឈើ (On Forest Revenues for Forest Protection and Maintenance) | ៣៩. ០៤-០៣-១៩៩១ | ទីស្តីការគណរដ្ឋមន្ត្រី |
| ៨ | ស្តីពីចំណូលព្រៃឈើសម្រាប់ការការពារ និងការថែទាំព្រៃឈើ (On Forest Revenues for Forest Protection and Maintenance) | ០៣៩. ០៤-០៣-១៩៩១ | ក្រសួងកសិកម្ម |
| ៩ | ស្តីពីរុក្ខទិវា (On Arbor Day) | ០៨. ១២-០១-១៩៩០ | ទីស្តីការគណរដ្ឋមន្ត្រី |
| ១០ | ស្តីពីការនាំចេញ-នាំចូលផលិតផលពីព្រៃឈើ (On Export-Import of Forest Products) | ២៧៤. ០២-១២-១៩៨៨ | ទីស្តីការគណរដ្ឋមន្ត្រី |
| ១១ | ស្តីពីបទបញ្ជាបច្ចេកទេសសម្រាប់ការទាញយកផលសម្រាប់ពាណិជ្ជកម្ម (On Technical Order of Commencing Exploitation) | ០០៣១. ៣០-០៥-១៩៨៨ | ក្រសួងកសិកម្ម |
| ១២ | ស្តីពីវិធានបច្ចេកទេសក្រោយពេលការប្រមូលផលដើម្បីរក្សាអនាម័យព្រៃឈើ (On the Technical Rules of Post-Harvesting for Forest Hygiene) | ០០៣៥. ៣០-០៥-១៩៨៨ | ក្រសួងកសិកម្ម |
| ១៣ | ស្តីពីវិធានបច្ចេកទេសមុនការប្រមូលផល (On the | ០០៣៦. ៣០-០៥- | ក្រសួង |

| | | | |
|---|---|---|---|
| | Technical Rules of Pre-Harvesting) | ១៩៨៨ | កសិកម្ម |
| ១៤ | ស្តីពីការប្រើប្រាស់ត្រាកម្ពុជារូបព្រៃឈើ និងញញួរដែក ដើម្បីសំគាល់ឈើដែលមានសញ្ញាផ្លូវការ (On the Use of the Cambodian Forestry Steel Hammer Stamp to Officially Mark Logs) | ០៥៩. ២៤-១០-១៩៨៦ | ក្រសួងកសិកម្ម |
| ១៥ | ស្តីពីវិធានកិច្ចសហការសម្រាប់ការប្រមូលផលឈើនៅក្នុងសាធារណរដ្ឋប្រជាមានិតកម្ពុជា (On the Rules of Cooperation for Forest Harvesting in the Peoples' Republic of Cambodia) | ០៤៩. ១២-០៩-១៩៨៦ | ក្រសួងកសិកម្ម |
| ១៦ | ស្តីពីការចាត់ចំណាត់ថ្នាក់ពូជឈើ និងទំហំអប្បបរមាដែលអនុញ្ញាតឲ្យកាប់ (On the Classification of Tree Species and the Minimum Size to be Allowed for Cutting) | ០៥០. ១២-០៩-១៩៨៦ | ក្រសួងកសិកម្ម |
| ១៧ | ស្តីពីកាតព្វកិច្ច មុខងារ និងការរៀបចំរបស់ DFW (On the Duty, Function and Organization of DFW) | ៦០៨. ២១-០៧-១៩៨៦ | ក្រសួងកសិកម្ម |
| ១៨ | ស្តីពីកាតព្វកិច្ចផ្នែកនីតិវិធីរបស់ថ្នាក់ដឹកនាំរដ្ឋបាលព្រៃឈើ (On the duty procedured of FA leader) | ៣៦៥. ០៤-០២-២០០៤ | រដ្ឋបាលព្រៃឈើ |
| ១៩ | ស្តីពីលទ្ធផលកិច្ចប្រជុំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលព្រៃឈើមូលដ្ឋាន នៃថ្ងៃទី ២៨/១០/០៤ (On the result of the meeting on the emplementing duty of local FA on 28/10/04) | ១៩៥០. ១៤-០៦-២០០៤ | រដ្ឋបាលព្រៃឈើ |
| ២០ | សេចក្តីណែនាំស្តីពីការប្រើប្រាស់ត្រាសញ្ញារូបព្រៃឈើ និងញញួរដែករបស់កម្ពុជា (Instruction on the Use of the Cambodia Forest Steel Hammer Stamp) | ០០១. ១៩-០២-១៩៨៧ | ក្រសួងកសិកម្ម |
| | **សារាចរណ៍** | | |
| ១ | ស្តីពីការបង្ក្រាប និងការចាត់វិធានការលើការដឹកជញ្ជូន និងការជួញដូរដើមត្នោត (On the suppression and mesurement of the transportation and trading of palm trees) | ៤៨១. ០៥-០៩-០៣ | ក្រសួងកសិកម្ម |

| | | | |
|---|---|---|---|
| ២ | ស្តីពីការដឹកជញ្ជូនឈើ ឧបករណ៍ និងទំនិញគ្រប់ប្រភេទតាមផ្លូវថ្នល់នានាក្នុងព្រះរាជាណាចក្រកម្ពុជា (On the Transportation of All Types of Wood, Equipment and Goods along Roads in the Kingdom of Cambodia) | ០៥. ៣០-០៨-២០០១ | រដ្ឋាភិបាល |
| ៣ | ស្តីពីការបង់ប្រាក់សម្រាប់ការការពារ និងការថែទាំព្រៃឈើ (On the Payment for Forest Protection and Maintenance) | ០០៤/១៥១. ២២-០៤-១៩៩១ | អន្តរក្រសួង |
| ៤ | ស្តីពីការបង់ប្រាក់សម្រាប់ការការពារ និងការថែទាំព្រៃឈើ (On the Payment for Forest Protection and Maintenance) | ០០៧/៣៣៩.'០២-០៦-២០០០ | អន្តរក្រសួង |
| ៥ | ស្តីពីតម្លៃផលិតផលព្រៃឈើ (On Prices of Forest Products) | ៤៣០. ១៩-០៧-២០០០ | ក្រសួងកសិកម្ម |
| | **សេចក្តីណែនាំ និងសេចក្តីប្រកាសព័ត៌មាន** | | |
| ១ | ស្តីពីវិធានការដើម្បីការពារស្ពានគីសូណាពីការដឹកជញ្ជូនផលិតផលព្រៃឈើ (On the Measures to Protect Kizuna Bridge from Forest Product Transportation) | ៣១៦. ៣០-០៩-២០០២ | ក្រសួងកសិកម្ម |
| ២ | សេចក្តីប្រកាសព័ត៌មានស្តីពីការហាមឃាត់ការជួញដូរសត្វព្រៃ (Announcement on the Prohibited Wildlife Trade) | ៣៨៣៧. ១៤-០៨-២០០១ | ក្រសួងកសិកម្ម |
| ៣ | សេចក្តីណែនាំស្តីពីការផ្គត់ផ្គង់ផលិតផលឈើសម្រាប់ការប្រើប្រាស់ក្នុងស្រុក (Instruction on the Supply of Timber Products for Local Consumption) | ១៤២. ១៤-០១-២០០០ | DFW |
| ៤ | សេចក្តីប្រកាសព័ត៌មានស្តីពីសេចក្តីណែនាំឲ្យអនុវត្តប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ ០០៩២/ប្រ.ក/ក.ស.ម ចុះថ្ងៃទី ១១-១០-១៩៨៩ (Announcement on the Instruction to Implement Declaration of MAFF No 0092/ProKor/ KorSorKorMor Dated 11-10-1989 on the Establishment and | ១៨១៧. ៣០-០៤-១៩៩១ | ក្រសួងកសិកម្ម |

| | | | |
|---|---|---|---|
| | Management of All Sawmills, Wood Processing Factories, Workshops and Handicrafts Using Raw Materials of Forest Products) | | |
| ៥ | ស្តីពីការបង្ក្រាបបទល្មើសព្រៃឈើ និងនេសាទ (On the Suppression of Forestry and Fishery Offenses) | ១៥. ១៨-១០-១៩៩៣ | រដ្ឋាភិបាល |
| ៦ | សេចក្តីណែនាំស្តីពីការប្រើប្រាស់ត្រាសញ្ញារូបព្រៃឈើ និងញញួរដែករបស់កម្ពុជា (Instruction on the Use of the Cambodian Forestry Steel Hammer Stamp) | ១៩-០២-១៩៨៧ | ក្រសួងកសិកម្ម |
| | បទបញ្ញត្តិ (Regulation) | | |
| ១ | ស្តីពីការបង្ក្រាប និងការលុបបំបាត់ការកាប់ ការកាប់ការដុត ការឈូសឆាយ និងការកាន់កាប់លើដីព្រៃ (On the suppresion and eliminating the forest cuting, burning, cleaning and occupying forest estate) | ០១. ០៦-០៦-០៤ | រដ្ឋាភិបាល |

ប្រភពទិន្នន័យ៖ ការិយាល័យច្បាប់ និងនីតិកម្ម របស់រដ្ឋបាលព្រៃឈើ

ចំណងជើងភាសាអង់គ្លេសជាការបកប្រែក្រៅផ្លូវការ។

ទិន្នន័យគិតមកត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៩។

# អនុសញ្ញាដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន

| អនុសញ្ញា |
|---|
| អនុសញ្ញាលេខ ២៩ ៖ អនុសញ្ញាស្តីពីការងារពេលយប់សម្រាប់មនុស្សវ័យក្មេង (ឧស្សាហកម្ម) ឆ្នាំ ១៩១៩ (ល. ៦) ២៤.០២.១៩៦៩ |
| អនុសញ្ញាលេខ ២៩៖ អនុសញ្ញាស្តីពីការងារដោយបង្ខំ ឆ្នាំ ១៩៣០ (ល. ២៩) ២៤.០២.១៩៦៩ |
| អនុសញ្ញាលេខ ៨៧៖ អនុសញ្ញាស្តីពីសេរីភាពនៃសមាគម និងការការពារសិទ្ធិនៃការបង្កើតសមាគម ឆ្នាំ ១៩៤៨ (ល. ៨៧) ២៣.០៨.១៩៩៩ |
| អនុសញ្ញាលេខ ៩៨៖ អនុសញ្ញាស្តីពីសិទ្ធិបង្កើតសមាគ និងសិទ្ធិនៃការចរចាជាសមូហភាព ឆ្នាំ ១៩៤៩ (ល. ៩៨) ២៣.០៨.១៩៩៩ |
| អនុសញ្ញាលេខ ១០០៖ អនុសញ្ញាសញ្ញាស្តីពីប្រាក់ឈ្នួលស្មើគ្នា ឆ្នាំ ១៩៥១ (ល. ១០០) ២៣.០៨.១៩៩៩ |
| អនុសញ្ញាលេខ ១០៥៖ អនុសញ្ញាស្តីពីការលុបបំបាត់ការងារដោយបង្ខំ ឆ្នាំ ១៩៥៧ (ល. ១០៥) ២៣.០៨.១៩៩៩ |
| អនុសញ្ញាលេខ ១១១៖ អនុសញ្ញាស្តីពីការរើសអើងក្នុងការងារ និងមុខរបរ ឆ្នាំ ១៩៥៨ (ល. ១១១) ២៣.០៨.១៩៩៩ |
| អនុសញ្ញាលេខ ១២២៖ អនុសញ្ញាស្តីពីគោលនយោបាយមុខរបរ ឆ្នាំ ១៩៦៤ (ល. ១២២) ២៨.០៩.១៩៧១ |
| អនុសញ្ញាលេខ ១៣៨៖ អនុសញ្ញាស្តីពីការកំរិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការងារ ឆ្នាំ ១៩៧៣ (ល. ១៣៨); អាយុអប្បបរមាដែលត្រូវបានកំណត់៖ ១៤ ឆ្នាំ ២៣.០៨.១៩៩៩ |
| អនុសញ្ញាលេខ ១៥០៖ អនុសញ្ញាស្តីពីរដ្ឋបាលការងារ ឆ្នាំ ១៩៧៨ (ល. ១៥០) ២៣.០៨.១៩៩៩ |
| អនុសញ្ញាលេខ ១៨២៖ អនុសញ្ញាស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃការងារកុមារ ឆ្នាំ ១៩៩៩ (ល. ១៨២) ១៤.០៣.២០០៦ |
| អនុសញ្ញាលេខ ៦៖ អនុសញ្ញាស្តីពីការងារពេលយប់សម្រាប់កុមារ (ឧស្សាហកម្ម) ឆ្នាំ ១៩១៩ (No. ៦) ២៤.០២.១៩៦៩ |
| អនុសញ្ញាស្តីពីការជួញដូរពូជសត្វព្រៃ និងរុក្ខជាតិជិតផុតពូជជាអន្តរជាតិ (Convention on |

| |
|---|
| International Trade of Endangered Species of Wild Fauna and Flora) |
| អនុសញ្ញាស្តីពីតំបន់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិ ជាពិសេសសម្រាប់ជាជម្រកសត្វបក្សីទឹក (Convention on Wetlands of International Importance Especially as Waterfowl Habitat) |
| អនុសញ្ញាអង្គការពលកម្មអន្តរជាតិ (ប្រទេសចិនមិនមែនជាហត្ថលេខីពេញលេញ) |
| កិច្ចព្រមព្រៀងអន្តរជាតិស្តីពីឈើត្រូពិច |
| សហាជីពអន្តរជាតិដើម្បីការពារពូជរុក្ខជាតិថ្មីៗ<br>អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រយុទ្ធប្រឆាំងនឹងការប្រែក្លាយជាវាលខ្សាច់ (United Nations Convention to Combat Desertification) |
| អនុសញ្ញាក្របខ័ណ្ឌការងារអង្គការសហប្រជាតិស្តីពីបំរែបំរួលអាកាសធាតុ |
| អនុសញ្ញាស្តីពីភាពចម្រុះផ្នែកជីវសាស្រ្ត |
| អនុសញ្ញាទីក្រុងវៀនស្តីពីការការពារស្រទាប់អូហ្សូន |
| |
| អនុសញ្ញាលេខ ២៩៖ អនុសញ្ញាស្តីពីការងារដោយបង្ខំ ឆ្នាំ ១៩៣០ (ល. ២៩) ២៥.០២.១៩៦៩ |
| អនុសញ្ញាលេខ ៨៧៖ អនុសញ្ញាស្តីពីសេរីភាពនៃសមាគម និងការការពារសិទ្ធិនៃការបង្កើតសមាគម ឆ្នាំ ១៩៤៨ (ល. ៨៧) ២៣.០៨.១៩៩៩ |
| អនុសញ្ញាលេខ ៩៨៖ អនុសញ្ញាស្តីពីសិទ្ធិបង្កើតសមាគ និងសិទ្ធិនៃការចរចាជាសមូហភាព ឆ្នាំ ១៩៤៩ (ល. ៩៨) ២៣.០៨.១៩៩៩ |
| អនុសញ្ញាលេខ ១០០៖ អនុសញ្ញាសញ្ញាស្តីពីប្រាក់ឈ្នួលស្មើគ្នា ឆ្នាំ ១៩៥១ (ល. ១០០) ២៣.០៨.១៩៩៩ |
| អនុសញ្ញាលេខ ១០៥ អនុសញ្ញាស្តីពីការលុបបំបាត់ការងារដោយបង្ខំ ឆ្នាំ ១៩៥៧ (ល. ១០៥) ២៣.០៨.១៩៩៩ |
| អនុសញ្ញាលេខ ១១១ អនុសញ្ញាស្តីពីការរើសអើងក្នុងការងារ និងមុខរបរ ឆ្នាំ ១៩៥៨ (ល. ១១១) ២៣.០៨.១៩៩៩ |
| អនុសញ្ញាលេខ ១២២៖ អនុសញ្ញាស្តីពីគោលនយោបាយមុខរបរ ឆ្នាំ ១៩៦៤ (ល. ១២២) ២៨.០៩.១៩៧១ |
| អនុសញ្ញាស្តីពីការជួញដូរពូជសត្វព្រៃ និងរុក្ខជាតិជិតផុតពូជជាអន្តរជាតិ (Convention on International Trade of Endangered Species of Wild Fauna and Flora) |

| |
|---|
| កិច្ចព្រមព្រៀងអន្តរជាតិស្តីពីឈើត្រូពិច |
| សហាជីពអន្តរជាតិដើម្បីការពារពូជរុក្ខជាតិថ្មីៗ<br>អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រយុទ្ធប្រឆាំងនឹងការប្រែក្លាយជាវាលខ្សាច់ (United Nations Convention to Combat Desertification) |
| អនុសញ្ញាក្របខ័ណ្ឌការងារអង្គការសហប្រជាតិស្តីពីបំរែបំរួលអាកាសធាតុ |
| អនុសញ្ញាស្តីពីភាពចម្រុះផ្នែកជីវសាស្រ្ត |
| អនុសញ្ញាទីក្រុងវៀនស្តីពីការការពារស្រទាប់អូហ្សូន |

# ឧបសម្ព័ន្ធទី ៣៖ បញ្ជីប្រភេទពូជដែលជិតផុតពូជ និងប្រភេទពូជកម្រ

បញ្ជីទាំងនេះមាននៅ៖

http៖//cambodia.panda.org/wwf_in_cambodia/endangered_species/